ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ក្តីសង្ឃឹមជាទម្រង់នៃការតស៊ូ
- ការទទួលបានមកវិញនូវប្រវត្តិសាស្ត្រអន្លង់វែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៩៦ ខែមេសា ឆ្នាំ២០១៦

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៩៦ ខែមេសា ឆ្នាំ២០១៦

## មាតិកា


◆ ក្ដីសង្ឃឹមជាទម្រង់នៃការតស៊ូ ........................................ ១

**ផ្នែកឯកសារ**

◆ ទី សារ៉េត និងផែនការក្បត់អង្គការ ........................................ ៤

◆ ម៉ែន កឿន ប្រធានស្ថិតិតំបន់ពាយ័ព្យ ........................................ ៦

◆ ដំណឹងយុវជន-យុវនារីបដិវត្តន៍ ........................................ ១៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ខ្ញុំជឿជាក់លើអំពើល្អ ........................................ ២២

◆ បោះជំហានទៅកាន់ទឹកដីនៃការផ្សះផ្សា និងអប់រំអន្លង់វែង ........................................ ២៦

◆ ពូខ្ញុំស្លាប់ដោយសារតែមកលេងស្រុក ........................................ ២៨

◆ ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហំ បាលី ........................................ ៣១

◆ អាថ៌កំបាំងរបស់ ប៉ុល ពត ........................................ ៣៩

**ផ្នែកច្បាប់**

◆ ការជួបជាមួយ នួន ជា នៅតុលាការកាត់ទោសមេដឹកនាំ ........................................ ៤៥

**វេទិកាពិភាក្សាសាធារណៈ**

◆ ការទទួលបានមកវិញនូវប្រវត្តិសាស្ត្រអន្លង់វែង ........................................ ៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ រសាត់តាមខ្យល់ ........................................ ៥៥




ប្រជាជនវិលត្រឡប់មកស្រុកកំណើតវិញក្រោយរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩


រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ ៖** កែវ សុភី, ហូ ថុនា, សុខ វណ្ណៈ, ស៊ាង ចិន្ដា, អេង កុកថាយ, ទេព ម៉េងឃាន, សើ សាយ្យាណា, លី សុខឃាង, ប៉ុក ប៉ុនសូម៉ាដ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុន្និទ្ធ **អ្នកបកប្រែ ៖** ស៊ាង ចិន្ដា **និពន្ធនាយកទូទៅ ៖** ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វ៉េង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ក្តីសង្ឃឹមជាទម្រង់នៃការតស៊ូ

មិនមានហេតុការណ៍ប្រវត្តិសាស្ត្រណាមួយដែលមិនជាប់ពាក់ព័ន្ធនឹងគ្នានោះទេ ។ យើងសិក្សាស្វែងយល់ពីអតីតកាល តាមរយៈខ្សែសង្វាក់ព្រឹត្តិការណ៍ និងការសម្រេចចិត្ត បណ្តាលឲ្យមានវិបត្តិជនភៀសខ្លួន ដែលយើងអាចឃើញនៅតំបន់អឺរ៉ុបនាពេលបច្ចុប្បន្ននេះ ខណៈដែលយើងបានចាកឆ្ងាយពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ឬអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តទៅលើជនជាតិអាមេនី កាលពីជាង១០០ឆ្នាំមុន ។

មេរៀនសំខាន់មួយទៀតដែលខ្ញុំគិតថាយើងគួរតែពិចារណានាពេលបច្ចុប្បន្ននេះ គឺជាមេរៀននៃក្តីសង្ឃឹម ។ ក្តីសង្ឃឹមជាទម្រង់នៃការតស៊ូប្រឆាំងមួយ ។ ក្តីសង្ឃឹមជ្រួតជ្រាបពាសពេញអ្វីគ្រប់យ៉ាងដែលយើងធ្វើ ព្រោះក្តីសង្ឃឹមជាសរសៃឈាមនៃអរិយធម៌ ហើយនេះក្តីសង្ឃឹមក៏ជាសមាសធាតុដំបូងនៃភាពជាជនរងគ្រោះ ។ មិនមានបញ្ហាចោទទៅលើរយៈកាល, វប្បធម៌ ឬ បទឧក្រិដ្ឋ, ក្តីសង្ឃឹម ជាទិដ្ឋភាពដំបូងមួយរបស់មនុស្សជាតិ ដែលត្រូវបានកសាងឡើងវិញទេ ។ យើងត្រូវតែសាងក្តីសង្ឃឹមទាំងក្នុងកម្រិតសមូហភាព និងឯកត្តភាព តាមរយៈការប្រព្រឹត្តសាមញ្ញនៃសេចក្តីសប្បុរស, សេចក្តីគោរព ឬ ការចិញ្ចឹមបីបាច់, ឬការប្រព្រឹត្តសមូហភាពនៃការទទួលស្គាល់សេចក្តីថ្លៃថ្នូរ, អំពើហិង្សា និងអំពើប្រល័យពូជសាសន៍ ដែលមនុស្សជាតិបានជម្នះ ហើយទីបំផុត យើងអាចយកសកម្មភាពទាំងនេះបោះជំហានទៅរកការកសាងក្តីសង្ឃឹម និងស្រោចស្រង់មនុស្សជាតិ ដែលបានបាត់បង់ ។

ប៉ុន្តែយើងមិនអាចជំនួសអ្វីគ្រប់យ៉ាងដែលត្រូវបានបាត់បង់ទៅហើយនោះទេ ។ មិនមានបញ្ហាថាតើយើងពុះពារខ្លាំងប៉ុណ្ណាដើម្បីធ្វើអំពើល្អ និងស្រោចស្រង់មនុស្សជាតិនៃភាពជាជនរងគ្រោះ, យើងនឹងក្លាយជាមានបញ្ញាត្រិះរិះដឹងថា នៅក្នុងសង្គមក្រោយជម្លោះ យើងត្រូវចំណាយពេលច្រើនជំនាន់ដើម្បីព្យាបាលរបួសនេះ បើសិនមនុស្សជំនាន់ក្រោយៗទាំងនោះពិតជាធ្វើ ។ អស់រយៈកាល ៤១ឆ្នាំ នៅក្នុងខែមេសា ២០១៦ នេះ គឺនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច និងអស់រយៈពេលជិត៤ឆ្នាំ ប្រជាជនកម្ពុជា២លាននាក់ត្រូវបានសម្លាប់ បង្អត់អាហារ ឬស្លាប់ដោយសារជំងឺ ឬការអស់



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ជួបជាមួយលោក អេដវើដ ណាលបានឌីន រដ្ឋមន្ត្រីការបរទេស ប្រទេសអាមេនី។ ក្នុងឱកាសនោះ លោក ឆាំង យុ បានស្នើរដ្ឋាភិបាលប្រទេសអាមេនី ដាក់បញ្ចូលកម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍ក្នុងកម្មវិធីអប់រំរបស់រដ្ឋ ។



លោក ឆាំង យុ និង លោក ចច ក្លូនី តារាហូលីវូដដ៏ល្បី និងជាអ្នកធ្វើការងារពាក់ព័ន្ធផ្នែកមនុស្សធម៌ ធ្វើទស្សនកិច្ចនៅសារមន្ទីរប្រល័យពូជសាសន៍ ប្រទេសអាមេនី ក្នុងឱកាសចូលរួមកិច្ចប្រជុំស្តីពី "ការទប់ស្កាត់អំពើប្រល័យពូជសាសន៍" នៅរដ្ឋធានីយ៉េរ៉េវ៉ាន់ ។

កម្លាំង ។

គ្រួសាររបស់ខ្ញុំជាគ្រួសារមួយនៃគ្រួសារកម្ពុជាទាំងនេះ ។ ដោយសារតែការជម្លៀសដោយបង្ខំពីភ្នំពេញ យើងបានតាំងទីលំនៅនៅក្នុងភូមិកំណើតរបស់ម្តាយយើងនៅក្នុងខេត្តតាកែវ ។ នៅឆ្នាំ១៩៧៥ មានពាក្យចចាមអារ៉ាមថា យើងនឹងអាចវិលត្រឡប់ទៅផ្ទះរបស់យើងនៅភ្នំពេញវិញបាន ។ ថ្ងៃមួយ ខ្មែរក្រហមបានមកប្រាប់យើងឲ្យខ្ចប់របស់របរ និងទៅកន្លែងផ្សេង ។ យើងសង្ឃឹមថាដំណើរវិលត្រឡប់ទៅផ្ទះវិញនៅពេលនេះបានចាប់ផ្តើមហើយ ។

យើងត្រូវបានដឹកតាមរថភ្លើង ។ មានមនុស្សច្រើនណាស់នៅលើរថភ្លើង រហូតដល់យើងមិនអាចសូម្បីតែអង្គុយ ។ បងស្រីរបស់ខ្ញុំម្នាក់ទើបតែសម្រាលបានកូនស្រីម្នាក់ ដែលមានអាយុតែ ៣-៤ខែ តែប៉ុណ្ណោះ ។ យើងទាំងអស់គ្នាព្រួយបារម្ភអំពីអ្វីដែលនឹងត្រូវកើតបន្ទាប់ ។ យប់មួយ ឪពុកមារបស់ខ្ញុំ (កែវ ឈឿន) មើលផ្កាយ ហើយគាត់បានរំឭកយើងពីផ្កាយក្រពើ ។

ផ្កាយក្រពើ គឺជារឿងនិទាន ដែលយើងបានដឹងតាំងពីកុមារភាព ។ វាជារឿងចាស់ និយាយអំពីសត្វក្រពើមួយក្បាល ដែលបានធ្វើអំពើល្អ ហើយជាលទ្ធផល ក្រពើនោះបានក្លាយជាផ្កាយនៅលើ



ភ្ញៀវទេសចរណ៍ និងអ្នកចូលរួមកិច្ចប្រជុំស្តីពី "ការទប់ស្កាត់អំពើប្រល័យពូជសាសន៍" ទស្សនកិច្ចសារមន្ទីរប្រល័យពូជសាសន៍នៅរដ្ឋធានីយ៉េរ៉េវ៉ាន់ ប្រទេសអាមេនី



សារមន្ទីរប្រល័យពូជសាសន៍ នៅរដ្ឋធានីយេរ៉េវ៉ាន់ ប្រទេសអាមេនី

មេឃ ។ ផ្កាយក្រពើតែងតែត្រូវបានគេយល់ឃើញថា ជាពន្លឺនៃក្តីសង្ឃឹម, ការនាំទិស និងអ្វីដែលល្អៗ ។ មនុស្សអាចមើលបានតាមរយៈការរះឡើងរបស់ផ្កាយនៅភាគឦសាន និងអាចប្រទះឃើញផ្កាយក្រពើដែលនឹងបង្ហាញផ្លូវដល់ខ្លួន ។

ខណៈជិះនៅក្នុងរថភ្លើង នៅក្នុងភាពងងឹតនៃយប់នោះ ឪពុករបស់ខ្ញុំបានរកមើលផ្កាយក្រពើ និងបានចង្អុលប្រាប់យើង ។ គាត់បានប្រាប់យើងថា យើងកំពុងតែធ្វើដំណើរតាមទិសទៅកាន់ភ្នំពេញទៅផ្ទះរបស់យើង ។ យើងមានអារម្មណ៍រំភើបនិងសប្បាយចិត្តខ្លាំងណាស់ ពីព្រោះយើងជឿថា យើងពិតជាកំពុងតែធ្វើដំណើរទៅផ្ទះវិញ ។ យើងបានបន្តដំណើរទៅមុខទាំងថ្ងៃទាំងយប់ ហើយបានឈប់នៅកន្លែងផ្សេងគ្នា ប៉ុន្តែមិនមានអ្វីចោទជាបញ្ហានោះទេ បើសិនយើងកំពុងទៅតាមទិសត្រឹមត្រូវ ។ រំពេចនោះ ការពិតបានលេចឡើង ។ ពេលដល់ខេត្តពោធិ៍សាត់ មនុស្សជាច្រើនត្រូវបានឲ្យចាកចេញពីរថភ្លើង ។ អ្នកដំណើរសេសសល់នៅលើរទេះភ្លើងបានបន្តដំណើរទៅមុខទៀតទៅ ។ ការធ្វើដំណើររបស់យើងមិនបានបញ្ចប់ ហើយវាគ្រាន់តែជាការចាប់ផ្តើមតែប៉ុណ្ណោះ ។

ខ្ញុំតែងតែគិតពីផ្កាយក្រពើ ។ ខ្ញុំនៅតែគិតពីវានាពេលបច្ចុប្បន្ននេះ ។ សម្រាប់រយៈកាលខ្លី ផ្កាយក្រពើបានផ្តល់ឲ្យយើងនូវក្តីសង្ឃឹម និងសុភមង្គល បើទោះបីជានៅទីបំផុត វាគ្រាន់តែជាសុបិនមួយតែប៉ុណ្ណោះ ។ គ្រួសារខ្ញុំបានបែកបាក់ ហើយយើងធ្លាក់ចូលដល់ជីវិតថ្មីមួយនៃភាពអត់ឃ្លាន ការធ្វើការហួសកម្លាំង និងអំពើប្រល័យពូជសាសន៍ ។ ខ្ញុំមានអារម្មណ៍ថា មានសំណាងដែលបានរួចផុតជីវិតពីរយៈកាលយ៉ាងវេទនានោះ ។ សមាជិកក្រុមគ្រួសារជាច្រើន រួមទាំងកូនរបស់បងស្រីខ្ញុំ និងឪពុករបស់ខ្ញុំ មិនបានរួចផុតជីវិតពីរយៈកាលនោះទេ ។

ខ្ញុំនិយាយប្រាប់រឿងរ៉ាវជីវិតនេះ ពីព្រោះផ្កាយនៃក្តីសង្ឃឹមបានរក្សាទុកអារម្មណ៍កុមារភាពរបស់ខ្ញុំឲ្យនៅមានជីវិតជានិច្ច ទោះបីគ្រាន់តែជារយៈពេលខ្លីមួយ ។ ប៉ុន្តែខ្ញុំនឹងមិនគិតពីផ្កាយក្រពើដូចក្នុងរឿងនិទានទៀតទេ ។

យើងប្រហែលជាមិនអាចធ្វើឲ្យជនរងគ្រោះ, បុគ្គលម្នាក់, សហគមន៍ និងសង្គម រួបរួមពេញលេញនោះទេ ប៉ុន្តែយើងអាចខិតខំធ្វើល្អ ហើយរាល់ទង្វើល្អតិចតួចជាការបង្ហាញពីមនុស្សជាតិរួបរួមរបស់យើង និងជាពន្លឺសម្រាប់មនុស្សជំនាន់ក្រោយ ។

***សុន្ទរកថា លោក ឆាំង យុ នៅប្រទេសអាមេនី ក្នុងកិច្ចប្រជុំពិភពលោកស្តីពីការប្រឆាំងអំពើប្រល័យពូជសាសន៍ ដែលបានកើតនៅប្រទេសអាមេនី១០០ឆ្នាំកន្លងមកហើយ ។***

# ទី សារ៉េត និងផែនការក្បត់អង្គការ

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព D០០៣៦៨*

ខ្ញុំឈ្មោះ ទី សារ៉េត អាយុ២៧ឆ្នាំ នាទីនយោបាយអនុសេនាធំទី១ វរសេនាតូច៧០៦ កងពល៧០៣ ។ កើតនៅភូមិខ្វែងអណ្តូង ឃុំពោធិ៍បាន ស្រុក១៨ តំបន់២៥ ។ ដល់ឆ្នាំ១៩៦៤ ខ្ញុំចូលរៀននៅវត្តក្តីតាឡង់ ឃុំពោធិ៍បាន ខ្ញុំរៀនដល់ថ្នាក់ទី១០ "ចាស់" ។ ឆ្នាំ១៩៦៦ ខ្ញុំឈប់រៀនមកជួយរកស៊ីឪពុកម្តាយវិញ ។ រហូតដល់ខែមេសា ឆ្នាំ១៩៧០ ខ្ញុំចូលបដិវត្តន៍តាមរយៈឈ្មោះ ចាន់ ស៊ីថន នាទីគាត់ប្រធានយោធាស្រុក១៨ ។ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧១ ឈ្មោះ ចាន់ ស៊ីថន និង ហម មាន បានអប់រំខ្ញុំឲ្យចូលជាសមាជិកបក្សពលករកម្ពុជា ក្រោមការដឹកនាំរបស់វៀតណាម ដែលមានឈ្មោះ ណាំ យូរ និង ទី ហ៊ីង នៅភូមិក្បាលដំរី ឃុំកំពង់កុង ស្រុក១៨ តំបន់២៥ ។ អ្នកបញ្ចូលខ្ញុំគឺ ចាន់ ស៊ីថន ហើយអ្នកទទួលឈ្មោះ ណាំ យូរ ។ ពេលនោះខ្ញុំជាយុទ្ធជន



ជនរងគ្រោះដែលជាប់ឃុំឃាំងនៅអតីតមន្ទីរសន្តិសុខស-២១ (បច្ចុប្បន្ន សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង)

ក្នុងយោធាស្រុក១៨ គឺគាត់មានការរាប់អានជិតស្និទ្ធខ្ញុំ និង យុន ជាងគេ ហើយមិនឲ្យពួកខ្ញុំចូលក្នុងអង្គភាពខាងមុខវាយខ្លាំងទេ គឺនៅក្នុងមន្ទីរជាមួយគាត់ ។ គាត់ឲ្យលុយចាយជាបន្តបន្ទាប់ គាត់មិនដែលកសាងខ្ញុំទេ ធ្វើឲ្យខ្ញុំដើរហើរសេរីទៅលេងផ្ទះតាមចិត្ត ហើយខោអាវមិនដែលបើកឲ្យចាស់ទាន់ទេ គឺបើកថ្មីៗភ្លាម ។ ចំពោះខ្ញុំគឺមានការជឿទៅលើគាត់កាន់តែខ្លាំងឡើង គាត់ឲ្យធ្វើអ្វី ខ្ញុំធ្វើតាមគាត់ទាំងអស់ ។

ក្រោយមក គាត់អប់រំឲ្យខ្ញុំខំធ្វើការដែលគាត់ប្រគល់ឲ្យ ទៅថ្ងៃមុខមិនឥតប្រយោជន៍ទេ គឺគាត់មានការទទួលខុសត្រូវ និងមានភារកិច្ចប្រគល់ឲ្យក្នុងការដឹកនាំកងទ័ព និងប្រជាជន ។ ពេលគាត់និយាយដូច្នេះ ខ្ញុំក៏សុខចិត្តធ្វើតាម ។

នៅចុងឆ្នាំ១៩៧១ គាត់បានចាត់តាំងរូបខ្ញុំ និង យុន ធ្វើការឃោសនាបន្តទៅទៀត គាត់បានណែនាំឲ្យស្គាល់មនុស្សដែលគាត់អប់រំដូចរូបខ្ញុំដែរ ដែលមានភារកិច្ចឃោសនាប្រឆាំងនឹងអង្គការខ្មែរក្រហម ។ ខាងក្រោមជាឈ្មោះអ្នកដែល ចាន់ ស៊ីថន ណែនាំឲ្យស្គាល់ ៖

១) ឈ្មោះ ប៉េង ពីមុនមុខនាទីជាកងអនុសេនាតូចនៅក្នុងស្រុក១៨ បច្ចុប្បន្ននៅអង្គភាពកង០៨ ក្នុងកងពល៧០៣ ។

២) ឈ្មោះ ឡោត នាទីពីមុនកាលនៅស្រុក១៨ ជាប្រធានក្រុមស៊ើបអង្កេតការណ៍ បច្ចុប្បន្ននៅកងពិការក្នុងកងពល៥០២ ។

៣) ឈ្មោះ ជៀវ ពីមុនជាយុវជន (ពលីនៅចុងឆ្នាំ១៩៧៤) ។

៤) ឈ្មោះ ប៊ុនរឿង ពីមុនជានីរសាររបស់ ចាន់ ស៊ីថន បច្ចុប្បន្នជាប្រជាជននៅក្នុងភូមិខ្វែងអណ្តូង ឃុំពោធិ៍បាន ស្រុក១៨ តំបន់២៥ ។

ក្រោយមកគាត់បានចាត់តាំងឲ្យពួកខ្ញុំចុះទៅបង្កប់ធ្វើសកម្មភាពអស់ហើយ អង្គការចាត់តាំងគាត់ទៅធ្វើការក្នុងមូលដ្ឋានវិញ គឺ ស្រុក១៨ តំបន់២៥ ។ ឆ្នាំ១៩៧២ អង្គការបានរៀបចំកងវរសេនាតូច១១២ ប្រចាំភូមិភាគពិសេស ។ ពួកខ្ញុំក៏បានចូលទៅនៅក្នុងអង្គភាពនេះដែរ ព្រោះពេលដែលរៀបចំយុទ្ធជននៅក្នុងមន្ទីរសេនាធិការតំបន់១៥ អង្គការដកយកទៅឲ្យចូលក្នុងកងវរសេនាតូច១១២ទាំងអស់ ក្នុងពេលនោះពួកខ្ញុំដែលត្រូវបាន ចាន់ ស៊ីថន អប់រំពីមុននោះ គាត់បានដាក់ផែនការឲ្យពួកខ្ញុំធ្វើសកម្មភាពក្នុងកងទ័ព ៖ ទី១) បំផ្លាញសម្ភាររបស់កងទ័ព ។ ទី២) ក្តាប់អាវុធ និងកម្លាំងប្រយុទ្ធកងណាខ្លាំងជាងគេ ។ ទី៣) លួចក្តាប់ការដឹកនាំក្នុងកងទ័ពខ្លាំង ឬខ្សោយ ពេលក្តាប់បានហើយគឺត្រូវរាយការណ៍ឲ្យគាត់ ។ ចំពោះផែនការនេះគឺធ្វើយូរផ្អែង ធ្វើយ៉ាងណាកុំឲ្យបែកការណ៍ ។ ចុងឆ្នាំ១៩៧២ ឈ្មោះ យុន បានធ្វើសកម្មភាពបំផ្លាញសម្ភារយោធានៅក្នុងសមរភូមិ ។

ឆ្នាំ១៩៧៣ អាប៉ាង ដក ខ្ញុំឲ្យធ្វើជាប្រធានសេដ្ឋកិច្ច កងវរសេនាតូច១១២ ។ ពេលនោះ ខ្ញុំកសាងកម្លាំងបានពីរនាក់ ឈ្មោះ រោ រ៉េម និង យ៉េង ដែលជាយុទ្ធជនសេដ្ឋកិច្ច ។ នៅចុងឆ្នាំ១៩៧៣នេះ សកម្មភាពរបស់ក្រុមខ្ញុំ គឺបង្កទំនាស់ក្នុងមូលដ្ឋាន ហើយបំផុសឲ្យប្រជាជនប្រឆាំង និងការរៀបចំរបស់បក្ស ។

ឆ្នាំ១៩៧៤ ខ្ញុំទាក់ទង និងទទួលផែនការជាប់ជាមួយ ចាន់ ស៊ីថន ធ្វើសកម្មភាពដូចកាលឆ្នាំ១៩៧៣ដែរ ។ ចុងឆ្នាំ១៩៧៤ ខ្ញុំត្រូវដាច់ពីឈ្មោះ ប៉ាង ហើយពេលនោះ ប៉ាង មកនៅវរសេនាធំ២៦៩ ចំណែកខ្ញុំផ្លាស់មកនៅក្នុងកង១២ ដោយមាននាទីនយោបាយកងហ ។

ក្រោយរំដោះ ខ្ញុំមកទទួលកងរយក្នុងវរៈ៣១៣ វរសេនាធំ៣១ កងពល៧០៣ ។ ពេលនោះ ខ្ញុំកសាងកម្លាំងបានមានឈ្មោះ សែន នាទីកងរយ និងឈ្មោះ នុង កងរយនៅ៣១៣ ។ សកម្មភាពខ្ញុំនៅឆ្នាំ១៩៧៦ គឺបំភ្លៃមាគ៌ារបស់បក្ស បំផ្លាញសម្ភាររបស់អង្គការតាមរូបភាពមិនទទួលខុសត្រូវលើការងារ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ ខ្ញុំកសាងកម្លាំងបានមួយចំនួនធំ ហើយបានធ្វើសកម្មភាពគឺបង្កទំនាស់ និងធ្វើឲ្យស្មុគស្មាញក្នុងអង្គភាព ។

ដើមឆ្នាំ១៩៧៧ ខ្ញុំមកនៅវរសេនាតូច៧០៦ កងពល៧០៣ មានមុខនាទីអ្នកនយោបាយ និងបានធ្វើសកម្មភាពប្រឆាំងនឹងអង្គការ ។

ចុងឆ្នាំ១៩៧៧ ខ្ញុំទាក់ទងជាមួយ ហ៊ឺន ហើយបានរួមសកម្មភាពបំផ្លាញសម្ភាររបស់បក្ស បង្កទំនាស់ក្នុងអង្គភាព និងបំផ្លាញការបង្កបង្កើនផលរបស់បក្សជាបន្តបន្ទាប់រហូតដល់ អង្គការចាប់ខ្លួន ថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៧ ។

**កែវ សុភី**

# ម៉ែន ភឿន ប្រធានស្ថិតិតំបន់ពាយ័ព្យ

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព J០០៧៦៦*

ឈ្មោះ មែន ភឿន អាយុ៣៧ឆ្នាំ ភេទប្រុស អតីតសាស្ត្រាចារ្យសាលារៀននេតយ៉ង់ (បាត់ដំបង) មានស្រុកកំណើតនៅភូមិពានី ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ក្នុងឆ្នាំ១៩៥៦ ភឿន បានចូលរៀននៅសាលាវត្តពានីអស់រយៈពេលបីឆ្នាំ រហូតដល់ថ្នាក់ទី១០ បន្ទាប់មកបានទៅបន្តការសិក្សានៅសាលាច្ចុតដ្ឋដល់ថ្នាក់ទី៧ ។ ឆ្នាំ១៩៦២ ភឿន បានប្រឡងជាប់ថ្នាក់ទី៦ ហើយបានចូលរៀននៅអនុវិទ្យាល័យសុភាម្រិត ខេត្តកំពង់ឆ្នាំង ។ ឆ្នាំ១៩៦៥ ភឿន បានប្រឡងជាប់ឌីប្លូម នៅចុងឆ្នាំ១៩៦៧ សាលាសុភាម្រិតមានការរៀបចំពិធីជប់លៀងគ្រូ និងសាស្ត្រាចារ្យ ពេលនោះអនុរក្សបានបញ្ជាឲ្យសិស្សថ្នាក់ទី១ ទាំងអស់ជញ្ជូនកៅអីដើម្បីរៀបចំកន្លែងពិធីជប់លៀង ស្រាប់តែមានបាតុភាពផ្ទុះឡើង គឺ កូនសិស្សមិនបានគោរពតាមបទបញ្ជារបស់អនុរក្សនោះទេ ហើយនាំគ្នាទៅផ្ទះអស់នៅ សល់តែ៤ទៅ៥នាក់ប៉ុណ្ណោះដែលបានជញ្ជូនកៅអី ។ ទំនាស់ពេលនោះមិនមែនជាទំនាស់ខាងផ្នែកនយោបាយទេ គឺកូនសិស្សភាគច្រើនមិនចូលចិត្តអនុរក្សឈ្មោះ អ៊ូ សរិត ប៉ុន្តែឈ្មោះ វង់ តាំងសេង (សិក្សាធិរក្សវិទ្យាល័យសុភាម្រិត) គាត់បែរជាចាប់អារម្មណ៍ និងភ័យខ្លាចពីចលនាខ្មែរក្រហម ដែលបានផ្ទុះឡើងដូចជានៅកំពង់ត្រឡាចលើ បាត់ដំបង កំពង់ធំ និងកំពង់ចាម សូម្បីតែនៅក្នុងសាលារៀនក៏មានផ្ទុះដែរ ដូចជា បាតុកម្មដុតឡាននៅអនុវិទ្យាល័យព្រៃទទឹង ។ បន្ទាប់មក វង់ តាំងសេង បានប្រមូលសិស្សថ្នាក់ទី១ ទាំងបីថ្នាក់មកអប់រំហើយបំភ័យ ដោយលើកយកព្រឹត្តិការណ៍ខ្មែរក្រហមដែលផ្ទុះឡើងនៅស្រុកខ្មែរ ។ រំលងបានប៉ុន្មានថ្ងៃ វង់ តាំងសេង បានប្រមូលសិស្សសំខាន់ៗយកទៅអប់រំស្ងាត់ៗ សិស្សទាំងនោះមានឈ្មោះដូចខាងក្រោមៈ

១) ម៉ែន ភឿន

២) ជៀប ជោត (នារី)

៣) គីម ពុត

៤) កោះ សេង

៥) សំ អៀង

៦) ហែម ហែ

៧) ហែម ហួត

៨) សោម វ៉ាន់ណាល់

៩) លឹម យ៉េន

ខ្លឹមសារអប់រំដូចជា វាយកុម្មុយនីស្តជាពិសេសសភាពការណ៍ចលនាកុម្មុយនីស្តនៅកម្ពុជា ដោយវិភាគឃើញថាសង្គមកម្ពុជាជាស្រុកសម្បូរសប្បាយ មិនចាំបាច់យកលទ្ធិកុម្មុយនីស្តមកអនុវត្តនោះទេ ហើយបានលើកឡើងមួយចំណុចទៀតថា សាសនាទំនៀមទម្លាប់ខ្មែរមិនចុះសម្រុងនឹងលទ្ធិនេះទេ ។ ដូច្នេះការធ្វើលទ្ធិកុម្មុយនីស្តនៅកម្ពុជាគឺជាការដុតបំផ្លាញកម្ពុជា បន្ថែមពីលើនេះ វង់ តាំងសេង បានលើកពីការលំបាកវេទនាសព្វបែបយ៉ាង ដោយលើកយកឧទាហរណ៍មកនិយាយថា នៅស្រុកចិនប្រជាជនបានរត់មកហុងកុង ដោយសារការខ្វះខាតស្បៀងអាហារ ការបំបិទសិទ្ធិសេរីភាពប្រជាជនរបស់លទ្ធិកុម្មុយនីស្ត ហើយទន្ទឹមនឹងនេះបានលើកយកពីសិទ្ធិសេរីភាព ជាពិសេសប្រទេសអាមេរិកតែម្តង ។ ក្រោយមកទៀត វង់ តាំងសេង បានធ្វើពិធីចាត់តាំងសិស្សទាំងអស់នេះជាសមាជិក សេ.អ៊ី.អា ពេលនោះ វង់ តាំងសេង បានប្រគល់ភារកិច្ច ដូចជា ពង្រីកកម្លាំងបន្ថែមទៀត ហើយប្រឆាំងនឹងចលនាកុម្មុយនីស្ត ។ ភឿន កសាងកម្លាំងបានម្នាក់ឈ្មោះ មេសុវឿន ឈ្មោះម្នាក់នេះគឺមិនបានចាត់តាំងជាសមាជិក សេ.អ៊ី.អា ទេ ។ ចុងឆ្នាំ១៩៦៧ ភឿន បានប្រឡងជាប់មធ្យមសិក្សាបត្រភាគ ១ ហើយជាប់ជាគ្រូផងក៏ត្រូវមករៀននៅភ្នំពេញ ។ ដូច្នេះ បានដាច់ខ្សែរយៈចាស់ ហើយអ្នកដែលបានទាក់ទងជាប់រហូតមកគឺមានតែឈ្មោះ សោម វ៉ាន់ណាល់ ព្រោះប្រឡងជាប់គ្រូដូច ភឿន ដែរ ។ ការទាក់ទងទាំងនេះគឺក្នុងការអនុវត្តផែនការ ដែលទទួលបានមកពី

កំពង់ឆ្នាំងរួចមកហើយ ។ ក្រៅពីនេះ ភឿន បានទាក់ទងគិញម្នាក់ឈ្មោះ ជៀវ ហើយ ភឿន បានរាយការណ៍ឲ្យគិញម្នាក់នេះឲ្យចាប់ខ្មែរក្រហម បានម្នាក់ឈ្មោះ សាន ហើយ ភឿន បានកសាងកម្លាំងបានម្នាក់ទៀតឈ្មោះ ព្រំ ហៀក ជាសិស្សថ្នាក់ទី៣ ។ ក្រោយពេលកន្លងផុតបានប្រហែលមួយខែ វង់ តាំងសេង បានហៅសមាជិកទាំងអស់មកប្រជុំ ហើយលើកផែនការដូចជា ៈ ស្រាវជ្រាវខ្សែរយៈខ្មែរក្រហម ទាំងក្នុងវិទ្យាល័យ និងក្រៅវិទ្យាល័យ ប្រសិនបើនៅក្នុងវិទ្យល័យឲ្យត្រួតពិនិត្យគ្រប់ចលនា និងគ្រប់សកម្មភាពទាំងអស់ ហើយម្យ៉ាងទៀតត្រូវឃោសនាប្រឆាំងនឹងកុម្មុយនីស្តតាមគ្រប់រូបភាព ជាពិសេសលើកតែពីចំណុចខ្សោយរបស់កុម្មុយនីស្ត ។ ចំពោះការអនុវត្តផែនការ ភឿន បានបំផុសប្រឆាំងនឹងចលនាពេទ្យទាហានរបស់ លន់ នល់ រហូតភៀសខ្លួនទៅស្រុកលាវ ។

ឆ្នាំ១៩៦៨ ភឿន បានចេញទៅបង្រៀននៅសាលាបឋមសិក្សាខ្នាឆ្មារ ដែលស្ថិតនៅក្នុងឃុំខ្នាឆ្មារ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង នៅទីនោះ ភឿន បានទាក់ទងឈ្មោះ ត្រាក ប៉ូ ជាគ្រូបង្រៀននៅខ្នាឆ្មារ និងម្នាក់ទៀតឈ្មោះ ជ័យ សោម ជានាយកសាលារៀនខ្នាឆ្មារ ។ ភឿន ហ៊ានទាក់ទងឈ្មោះទាំងពីរនាក់នេះដោយសារតែ ភឿន ក្តាប់បាតុភាពរបស់គាត់បានគឺប្រឆាំងខ្មែរក្រហមដាច់ខាត ព្រមស្លាប់ជាមួយស្តេចសីហនុមិនចូលខ្មែរក្រហមម្យ៉ាងវិញទៀតហ៊ានវាយប្រហារជេរប្រមាថមើលងាយខ្មែរក្រហមទៀតផង ។ ក្រោយមកទៀត ភឿន, ត្រាក, ប៉ូ និង ជ័យ សោម បានឃោសនាអប់រំប្រជាជន និងសិស្សឲ្យស្អប់ខ្មែរក្រហម ជាពិសេសខ្មែរក្រហមដែលកំពុងមានចលនានៅក្នុងខេត្តកំពង់ស្ពឺ និងទល់ដែនកំពង់ស្ពឺ-កំពង់ឆ្នាំង ។

ក្នុងឆ្នាំ១៩៧០ ភឿន បានបំផុស និងចូលរួមយ៉ាងសកម្មក្នុងចលនាបាតុកម្មរដ្ឋប្រហារ១៨មីនា ។ ក្រោយរដ្ឋប្រហារបានប្រហែលមួយអាទិត្យ ភឿន ព្រមទាំងមាននិស្សិត និងសាស្ត្រាចារ្យទាំងអស់បានចូលរៀនផ្នែកនយោបាយ នៅមហាវិទ្យាល័យគរុកោសល្យ អ្នកបង្រៀនកាលនោះមានឈ្មោះ ដូចជា អឹង ក្រពុំផ្កា, ស្រី សាម៉ន និង ត្រឹង ងា ។ ខ្លឹមសារដែលបង្រៀនគឺវាយកុម្មុយនីស្តលើកពីគ្រោះថ្នាក់នៃចលនាកុម្មុយនីស្តនៅកម្ពុជា ហើយបង្ហាញពីចំណុចខ្លាំងនៃរដ្ឋប្រហារ ពេលបង្រៀនចប់អ្នកអប់រំម្នាក់ៗ បាន


អតីតមន្ទីរសន្តិសុខស-២១ (បច្ចុប្បន្ន សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង)

ប្រគល់ភារកិច្ចឲ្យចុះទៅស្រុកកំណើតរៀងៗខ្លួន ដើម្បីឃោសនាអប់រំប្រជាជនឲ្យយល់ពីព្រឹត្តិការណ៍នៅកម្ពុជា ។ ភឿន ក៏បានចុះទៅស្រុកកំណើតអស់រយៈពេលមួយអាទិត្យ ហើយបានធ្វើការអប់រំយ៉ាងសកម្មតាមរយៈមនុស្សសំខាន់ៗ ហើយទិសដៅសំខាន់បំផុតគឺពន្យល់អំពីគ្រោះថ្នាក់របស់កុម្មុយនីស្តនៅកម្ពុជា និងទប់ទល់កុំឲ្យមានចលនាបាតុកម្ម ដូចជា នៅខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តតាកែវ ។

ចុងឆ្នាំ១៩៧០ ភឿន បានជាប់ទាក់ទងខ្សែរយៈឡើងវិញជាមួយនឹងឈ្មោះ វង់ តាំងសេង និង នុត ឈឿន ហើយគាត់ទាំងពីរនាក់នេះតែងតែពង្រឹង និងរំឭក ភឿន ពីផែនការចាស់ និងដាក់ផែនការថ្មីទៀត គឺឲ្យចុះទៅស្រុកកំណើតដើម្បីឃោសនាប្រជាជនកុំឲ្យគាំទ្រកុម្មុយនីស្ត ប្រសិនបើជាយុវនារីវិញត្រូវផ្គូផ្គងឲ្យរៀបការ យុវជន និងជំទង់ឲ្យបួសជាសង្ឃ រីឯកម្លាំងប្រុសដែលនៅសល់គឺឲ្យចូលធ្វើស្វ័យត្រាណ ធ្វើកុម្ម៉ង់ដូយាមភូមិ និងធ្វើទាហាន ។ ក្នុងមជ្ឈដ្ឋានសិស្ស ឬនិស្សិត លោកសង្ឃ កម្មករតូចតាច កម្មកររោងចក្រ ក៏ឲ្យបំផុសដូចគ្នាដើម្បីប្រមូលកម្លាំងទាំងនយោបាយ ទាំងយោធាទប់ទល់នឹងកុម្មុយនីស្តនៅកម្ពុជា ។ ដោយឡែកក្នុងមជ្ឈដ្ឋានសិស្ស ឬនិស្សិតឲ្យបំផុសជាចលនារៀនភាសាអង់គ្លេសតាមវិទ្យាស្ថានភាសាអង់គ្លេស ដែលត្រូវពង្រីកនៅតាមទីរួមខេត្ត ជាពិសេសនៅភ្នំពេញតែម្តង ។ ក្នុងការអនុវត្តផែនការ ភឿន និងបក្ខពួកបានអនុវត្តនៅតាមមជ្ឈដ្ឋានរៀងៗខ្លួនពេលនោះ ភឿន បានណែនាំលោកសង្ឃឲ្យធ្វើទាហានបាន៣នាក់ និងប្រជាជនដែលរស់នៅភូមិជាមួយគ្នាបាន៤នាក់បន្ថែមទៀត ។ ក្រោយមកទៀត ភឿន ត្រូវចេញទៅរស់នៅក្នុងខេត្តបាត់ដំបង មុននឹងចេញទៅ ភឿន បានទៅជួបទាក់ទងជាមួយឈ្មោះ វង់ តាំងសេង ពេលនោះគាត់បានណែនាំឲ្យ ភឿន ទាក់ទងជាមួយឈ្មោះ ប៉ុន សម្ភាជ ពីព្រោះឈ្មោះ ប៉ុន សម្ភាជ ជាខ្សែ សេ.អ៊ី.អា ។ ពេលដែល ភឿន បានទៅដល់ខេត្តបាត់ដំបង ហើយបានស្នាក់នៅជាមួយឈ្មោះ យន់ ភីន (ជំនួយការស្ថិតិនៅស្រុកមោងឫស្សី តំបន់៤) ។ ឆ្នាំ១៩៧១ ភឿន បានទាក់ទងជាមួយទាហានការិយាល័យទី២ឈ្មោះ ព្រំ ជី ដែលធ្លាប់រៀនជាមួយគ្នា ពេលនោះ ភឿន ក៏បានរាយការណ៍បន្តពីសេចក្តីរាយការណ៍របស់ឈ្មោះ យន់ ភីន ដើម្បីឲ្យចាប់ខ្មែរក្រហមម្នាក់នៅសង្កាត់ឈើទាល ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ក្នុងឆ្នាំ១៩៧២ ប៉ុន សម្ភាជ បានបង្កើតសមាគមស្រាវជ្រាវឯកសារ ភឿន ក៏បានចូលជាសមាជិកហើយបានទាក់ទងជាមួយឈ្មោះ ប៉ុន សម្ភាជ រហូតមកពីបញ្ហាសមាគម ហើយមួយទៀតទាក់ទងខាងផ្នែកនយោបាយ ។ ប៉ុន្តែនាពេលភ្លាមៗនេះ ភឿន មិនបានបង្ហាញពីនិន្នាការនយោបាយរបស់ខ្លួននោះទេ ជារឿយៗ ភឿន តែងតែលើកពីសង្គ្រាមនៅកម្ពុជា ជាពិសេសសភាពដ៏ឃោរឃៅរបស់លទ្ធិកុម្មុយនីស្ត និងពុទ្ធសាសនានៅកម្ពុជា ។ ចំណុចទាំងអស់ដែល ភឿន បានលើកឡើង ឈ្មោះ ប៉ុន សម្ភាជ បានចាប់អារម្មណ៍យ៉ាងខ្លាំង ហើយធ្លាយបាតុភាពប្រឆាំងកុម្មុយនីស្តដាច់ខាតពេលនោះ ភឿន បានបង្ហាញពីខ្សែរយៈរបស់ខ្លួនហើយរាយការណ៍ពីបទខុទ្ទេសនាមពីភ្នំពេញទៅ ហើយឈ្មោះ ប៉ុន សម្ភាជ ក៏បានបញ្ឈាក់បង្ហាញពីខ្សែ សេ.អ៊ី.អា ក្នុងវង្វង់សមាគមស្រាវជ្រាវឯកសារមានឈ្មោះដូចជា សោម សំអុន, ឡោក ឆ្លូត, កុល យឿត និង ហង់ សុធីរទ្ធិ ។ ឆ្នាំ១៩៧៣ ប៉ុន សម្ភាជ បានលើកយកផែនការមួយ គឺបំផុសការចរចាផ្អាកសង្គ្រាមនៅកម្ពុជា ការចរចានេះគឺធ្វើឡើងសម្រាប់ពន្យាពេលដើម្បីឆក់ឱកាសក្នុងពេលកំពុងចរចា គឺបំផុសឃោសនាប្រមូលកម្លាំង ទាំងទាហាន និងកុម្ម៉ង់ដូ ហើយធ្វើនយោបាយរៀបចំសេដ្ឋកិច្ច យុទ្ធវិធីនេះអាចបន្តសង្គ្រាម នៅកម្ពុជាបានយូរតទៅទៀត ប្រសិនបើកុម្មុយនីស្តមិនព្រមចរចា ត្រូវឈ្លាតយកឱកាសវៃកុម្មុយនីស្តតាមគោលនយោបាយ ។ ក្នុងការអនុវត្តផែនការនេះ ភឿន និងបក្ខពួកបានជំរុញការឃោសនានេះយ៉ាងសកម្ម តាមរូបភាពផ្ទាល់មាត់ និងបាចត្រាក់ឃោសនា បានធ្វើគ្រប់មជ្ឈដ្ឋានយ៉ាងផុសផុល ដូចជានៅក្នុងអនុវិទ្យាល័យ វិទ្យាល័យ កម្មករកសិករ និងលោកសង្ឃ ជាពិសេសបំផុសសិស្សនៅតាមជនបទឲ្យជឿលើការចរចាដើម្បីសន្តិភាពហើយរត់កិច្ចពីកុម្មុយនីស្ត ។ ឆ្នាំ១៩៧៤ ភឿន កសាងកម្លាំងបានពីរនាក់ឈ្មោះ ជិន តៃហេង អតីតសាស្ត្រាចារ្យវិទ្យាល័យអ៊ាបឃុត និង ប៉ែន សម្បត្តិ ជាសិស្សថ្នាក់ទី១ នៅវិទ្យាល័យនេតយ៉ង់ ចំពោះសកម្មភាពដោយឈ្មោះ ប៉ែន សម្បត្តិ ជាសិស្សកុម្ម៉ង់ដូ វិទ្យាល័យនេតយ៉ង់ ភឿន បានដាក់ផែនការឲ្យពង្រីង និងជំរុញឲ្យធ្វើទាហាន សិស្សធម្មតា ជំរុញឲ្យទៅជាកុម្ម៉ង់ដូ ហើយឲ្យបង្កើតក្លឹបប្រដាល់ និងយូដូនៅក្នុង

វិទ្យាល័យ ដើម្បីជាចំណេះមួយក្នុងការធ្វើសង្គ្រាមចំពោះឈ្មោះ ជិន តៃហេង ភឿន បានណែនាំឲ្យប្រមូលកម្លាំងនយោបាយក្នុងចំណោមមជ្ឈដ្ឋាន ដែលរស់នៅជាវណ្ណៈខ្ពង់ខ្ពស់ដើម្បីជំរុញការងារនយោបាយប្រឆាំងកុម្មុយនីស្ត ។

ឆ្នាំ១៩៧៥ កុម្មុយនីស្តបានវាយនៅខេត្តបាត់ដំបងយ៉ាងខ្លាំង ហើយព័ទ្ធជុំវិញក្រុងទាំងមូលពេលនោះឈ្មោះ ប៉ុន សម្មាជ ក៏បានប្រមូលបក្ខពួកមកប្រជុំ ខ្លឹមសារនៃការប្រជុំគឺផ្សាយពីផែនការចំពោះមុខដែលត្រូវទប់ទល់ជាមួយកុម្មុយនីស្ត ដែលវាយជុំវិញក្រុងបាត់ដំបង ទី១) បំផុសការចរចាជាមួយខ្មែរក្រហមដើម្បីរកសន្តិភាព ទី២) ក្នុងករណីខ្មែរក្រហមមិនព្រមចរចា ត្រូវរកវិធីបង្កប់ខ្លួនក្នុងជួរខ្មែរក្រហម ចំពោះផែនការបង្កប់ខ្លួនក្នុងជួរបដិវត្តន៍នេះ គឺដើម្បីអនុវត្តផែនការរួមនៅទូទាំងប្រទេស ប្រសិនបើខ្មែរក្រហមដណ្តើមបានជ័យជម្នះ គឺត្រូវផ្ទុះអាវុធវាយខ្មែរក្រហមពីក្រោយខ្នង ។ ក្នុងការប្រជុំនេះសមាជិកទាំងអស់បានឯកភាពគ្នាលើគម្រោងផែនការទាំងអស់ ហើយភ្លាមៗនោះក៏បានចេញសេចក្តីអំពាវនាវមួយ គឺសេចក្តីអំពាវនាវរបស់ ប៉ុន សម្មាជ ជាមេគណៈខេត្តបាត់ដំបង សូមឲ្យអ្នកកាន់អាវុធទាំងអស់ទម្លាក់អាវុធដើម្បីចរចារកសន្តិភាព ។ សេចក្តីអំពាវនាវនេះបានផ្សព្វផ្សាយទូទាំងខេត្តបាត់ដំបង ព្រមជាមួយគ្នានោះសមាជិកក្រុមទាំងអស់ បានយកសេចក្តីអំពាវនាវរបស់ ប៉ុន សម្មាជ ទៅបំផុសនៅក្នុងវិទ្យាល័យទាំងអស់ក្នុងក្រុងបាត់ដំបង ដើម្បីឲ្យគ្រូ សាស្ត្រាចារ្យ និងសិស្សនិស្សិតធ្វើសេចក្តីគាំទ្រ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តបានវាយឈ្នះទូទាំងប្រទេស ឈ្មោះ ហឿន ក៏បានវិលត្រឡប់មកបាត់ដំបងដើម្បីក្តាប់សភាពការណ៍ ចំពោះ ភឿន ព្រមទាំងសិស្ស និងបក្ខពួកមួយចំនួនក៏វិលត្រឡប់មកដែរ ពេលមកដល់បាត់ដំបង ហឿន បានចាត់តាំង កុល យឿត និង សោម សំអុន ឲ្យនៅបាត់ដំបង ឯឈ្មោះ ភឿនដាវ វើងស្រ៊ី ជិន តៃហេង និងសិស្សមួយចំនួនឲ្យទៅនៅតំបន់៥ ។ មុនចេញទៅ ឈ្មោះ ហឿន បានបញ្ជាក់ប្រាប់ថាឈ្មោះ ហឹង លេខាតំបន់៥ ជាខ្មែរ សេ.អ៊ី.អា ដែរ ពេលទៅដល់តំបន់៥ ឈ្មោះ ហឹង, ហឿន, ដាវ វើងស្រ៊ី, ជិន តៃហេង និង ភឿន បានប្រជុំនៅសាលាស្រុក ហើយឈ្មោះ ហឿន ក៏បានប្រគល់ ភឿន និងបក្ខពួកឲ្យទៅឈ្មោះ ហឹង ។ ក្រោយមកទៀត ភឿន បានស្នើសុំឈ្មោះ ម៉ម ចន្ទណា មកជួយធ្វើការពេលនោះ ហឹង បានបញ្ជាក់ប្រាប់ថាឈ្មោះ ម៉ម ចន្ទណា ជាខ្មែរ សេ.អ៊ី.អា ដែរត្រូវជាក្មួយឈ្មោះ អ៊ិន តាំ ហើយបានធ្វើការទាក់ទងប្រឆាំងបដិវត្តនៅតំបន់រំដោះជាប់រហូតមក ។

រំលងបានប្រហែលមួយអាទិត្យ ហឹង បានហៅ ភឿន និង ម៉ម ចន្ទណា ទៅប្រជុំពិភាក្សានៅក្រុងសេរីសោភ័ណ ខ្លឹមសារគឺលើកយកផែនការវាយកុម្មុយនីស្ត ទាំងផែនការចំពោះមុខ និងផែនការយោធាផែនការនេះគឺវាយទូទាំងប្រទេស ។ នៅតំបន់៥ នេះ កម្លាំងខាងក្នុងត្រូវប្រមូលទាំងអស់ ដូច្នេះកម្លាំងដែលត្រូវផ្ទុះ គឺមានតែយោធាជាខ្មែរប្រឆាំងបដិវត្តន៍ និងកងទ័ពសេរីកម្លាំងទាំងពីរនេះត្រូវតែសហការគ្នា ។ ក្នុងផែនការប្រមូលកម្លាំងប្រឆាំងបដិវត្តន៍ ម៉ម ចន្ទណា បានបញ្ជាក់បន្ថែមទៀតថា កម្លាំងដែលច្បាស់លាស់ពិតប្រាកដទុកចិត្តបាននៅមានតិចតួចនៅឡើយ ប៉ុន្តែនៅមានកម្លាំងមួយចំនួនទៀត ដែលអាចយកមកប្រើហើយកសាងបានបណ្តើរៗ ។ ក្រោយពីពេលប្រជុំចប់ ហឹង បានចាត់តាំង ភឿន ឲ្យរៀបចំធ្វើស្រែដោយប្រមូលកម្មករ ដែលចេះភ្ជួរត្រាក់ទ័រ រៀបចំទីកន្លែងធ្វើការដោយបង្កើតទីស្នាក់ការគណៈកម្មាធិការនៅទីនោះ ម្យ៉ាងទៀត ហឹង បានចាត់តាំង ភឿន ឲ្យរៀបចំកម្មករនៅក្នុងក្រុងសេរីសោភ័ណ គ្រប់ផ្នែកទាំងអស់តាំងពីកម្មករកិនស្រូវ ទឹកកក ជួសជុលកង់-ម៉ូតូ ជាងភ្លើង ជាងឈើ ជាងដែក ជាងត្រាក់ទ័រ ជាងនាឡិកា ជាងជ្រលក់ពណ៌ខោអាវ ជាងកាត់ដេរ ជាងគំនូរ -ល- ។ ក្នុងការរៀបចំ ភឿន បានធ្វើតាមផែនការដែលគ្រោងទុក ព្រមទាំងដំណើរការបានយ៉ាងរលូនក្នុងពេលនោះ ភឿនកសាងបានឈ្មោះ ងិន សាង៉ាល់ (អតីតសាស្ត្រាចារ្យ វិទ្យាល័យស៊ីសុផុន បច្ចុប្បន្នជំនួយការងារពាណិជ្ជកម្មតំបន់៥) និងម្នាក់ទៀតឈ្មោះ អ៊ី ណាយ ។ ក្រោយមកទៀត ភឿន បានចាត់តាំងឈ្មោះ ងិន សាង៉ាល់ ជាអ្នកប្រមូល និងក្តាប់ស្ថិតិស្រិន សាង៉ាល់ (អតីតសាស្ត្រាចារ្យវិទ្យាល័យស៊ីសុផុន បច្ចុប្បន្នជំនួយការងារពាណិជ្ជកម្មតំបន់៥) និងម្នាក់ទៀតឈ្មោះ អ៊ី ណាយ ។

ក្រោយមកទៀត ភឿន បាន ចាត់តាំងឈ្មោះ ងិន សាង៉ាល់ ជាអ្នកប្រមូល និងក្តាប់ស្ថិតិ ស្រិន សាង៉ាល់ (អតីតសាស្ត្រាចារ្យ

វិទ្យាល័យស៊ីសុផុន បច្ចុប្បន្នជំនួយការផារពាណិជ្ជកម្មតំបន់៥) និងម្នាក់ទៀតឈ្មោះ អ៊ី ណយ ។ ក្រោយមកទៀត ភឿន បានចាត់តាំងឈ្មោះ ងិន សាង៉ាល់ ជាអ្នកប្រមូល និងក្តាប់ស្ថិតិស្រូវព្រមទាំងឲ្យបំផ្លាញស្រូវ និងលាក់ស្ថិតិស្រូវ-អង្ករនៅក្នុងក្រុងសេរីសោភ័ណ ហើយបានធ្វើឲ្យខូចខាតស្រូវរាប់ពាន់បាវ ដោយពន្យារពេលប្រមូលផល ដាក់កម្លាំងបន្តិចបន្តួចដើម្បីឲ្យកណ្តៀរ ឬកណ្តុរស៊ី ព្រមទាំងត្រូវទឹកភ្លៀងពុកផុយខូចខាតស្រូវអស់ទាំងបាវ ។ ឯម្នាក់ទៀត ភឿន បានចាត់តាំងឲ្យបង្កប់ក្នុងមន្ទីរពេទ្យ ផ្នែកកាន់ឃ្លាំងដើម្បីលាក់ថ្នាំល្អៗដើម្បីបម្រើផែនការក្បត់ និងធ្វើឲ្យរអាក់រអួលនៅក្នុងការផ្តល់ថ្នាំទៅខាងមន្ទីរពេទ្យ ។ ក្រោយមកក្នុងពេលសម្រុកធ្វើស្រែចម្ការ ប្រជាជនបានឈឺជាច្រើននាក់ ។ ពេលនោះ ភឿន និង អ៊ី ណយ បានលាក់ថ្នាំមួយឃ្លាំង ហើយបានផ្លាស់ទីតាំងមន្ទីរពេទ្យ ដើម្បីឲ្យស្ទះដល់ការព្យាបាលប្រជាជន ។ ភ្លាមៗនោះដែរ ភឿន បានដាក់ផែនការឲ្យឈ្មោះ អេង (ប្រធានជាងដែក) ប្រមូលកម្លាំងប្រឆាំងបដិវត្តន៍ និងបំផ្លាញសម្ភារដើម្បីឲ្យស្ទះដល់ចលនាបដិវត្តន៍ ។

ស្របពេលនោះ ភឿន បានចាត់តាំងឈ្មោះ ងិន សាង៉ាល់ និង ផាវ វើងស្រ៊ី ប្រមូលកម្មករភ្ជួររាស់ហើយបានដាក់ផែនការបំផ្លាញ ។ ក្នុងរយៈការភ្ជួររាស់ ភឿន និង ផាវ វើងស្រ៊ី បានបំផ្លាញត្រាក់ទ័រអស់ជាងពាក់កណ្តាល ចំពោះត្រាក់ទ័រដែលមាន៧០គ្រឿង ស្រូវពូជប្រហែល៥០០បាវ ភ្ជួរដីចោលប្រហែល៥០០ហិចតា ក្រៅពីនេះបានបំផ្លាញសម្ភារផ្សេងៗជាច្រើនទៀត ។ ក្នុងការអនុវត្តផែនការ ក្រុមបក្សពួកទាំងអស់បានធ្វើឲ្យស្ទះដល់ចលនាដឹកស្រូវ និងអង្ករទៅចែកប្រជាជន (ប្រជាជនចាស់ និងប្រជាចាស់ថ្មីពីភ្នំពេញ) ដែលខ្វះខាតខ្លាំងនៅស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ ដើម្បីឲ្យស្ទះដល់ការប្រមូលស្រូវពីមូលដ្ឋាន ស្តុកចោលក្នុងឃ្លាំង មិនបញ្ចេញទៅឲ្យប្រជាជនប្រើ មានដូចជា ថ្នាំពេទ្យ ខោអាវ ក្រណាត់ចានឆ្នាំង ផាល និងសម្ភារសំខាន់ជាច្រើនទៀត ។ ក្រណាត់មួយចំនួនធំបានត្រូវទឹកភ្លៀងពុកផុយរហូតសត្វកណ្តៀស៊ី ហើយបានបំផ្លាញត្រាក់ទ័រ ឡានដឹកជញ្ជូនធំៗ សម្ភារមួយចំនួនធំ ដើម្បីឲ្យស្ទះដល់ចលនាដឹកជញ្ជូន ។ នៅដើមឆ្នាំ១៩៧៦ ឈ្មោះ ហ៊ីង បានណែនាំ ភឿន ឲ្យប្រមូលទាហាន ប៉ូលីស គិញ គយ និងអ្នករដ្ឋការទាំងអស់ឲ្យរក្សាកម្លាំងដើម្បីកសាងប្រឆាំងបដិវត្តន៍ហើយឈ្មោះ ហ៊ីង បានឲ្យ ភឿន ទាក់ទងជាមួយឈ្មោះ គង់ (លេខាសម្ងាត់ប្រាសាទ ស្រុកព្រះនេត្រព្រះ តំបន់៥) ដើម្បីទទួលលាក់កម្លាំង ។ បន្ទាប់មក ភឿន ប្រមូលកម្លាំងបានប្រហែល៣០០នាក់ ជាលើកដំបូងនៅស្រុកព្រះនេត្រព្រះបានបញ្ជូនទៅឲ្យឈ្មោះ គង់ លើកទី២ បានប្រហែល២០០នាក់ទៀត ។ នៅស្រុកភ្នំស្រុកប្រមូលបានប្រហែល៨០០នាក់ ហើយនៅស្រុកផ្សេងៗទៀត ដូចជា ស្រុកសេរីសោភ័ណ និងស្រុកថ្មពួកប្រមូលបានជាច្រើនរយនាក់ទៀត ក្រោយមកទៀត ភឿន បានទៅជួបទាក់ទងជាមួយ គង់ ហើយបានណែនាំឲ្យកសាងកម្លាំងទាំងអស់នេះប្រឆាំងបដិវត្តន៍ដើម្បីឧបត្ថម្ភដល់កម្លាំងទាំងអស់នេះ ហ៊ីង និង ភឿន បានបញ្ជូនស្បៀងនិងសម្ភារជាច្រើនផ្តល់ទៅឲ្យបក្សពួកទាំងនោះ ជាពិសេស បានផ្តល់ឧបករណ៍កសិកម្ម ដូចជា ត្រាក់ទ័រជាច្រើនគ្រឿង ។ នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ភឿន កសាងកម្លាំងបានដែលមានឈ្មោះដូចជា ផាណា, ឆន, ស្រ៊ាម ឈាង, ឡាម, លឹមគ្រី និង ឈ្មោះ ហេង

ក្រោយមក ភឿន បានណែនាំឈ្មោះ លឹមគ្រី និង ហេង ដែលនៅក្នុងអង្គភាពចម្ការបន្លែធ្វើឲ្យស្ទះក្នុងរដូវប្រមូលកាត់ (ស្ទះពីការខ្វះបន្លែ និងស្ទះពីការគ្រោះដោយបន្លែផង) ស្របពេលនេះដែរ ភឿន បានប្រមូលកម្លាំងប្រឆាំងបដិវត្តទាំងអស់ឲ្យបង្កប់នៅការដ្ឋានទំពាំងថ្មដើម្បីបំផុសបំផុល ។ យប់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ ភឿន បានទាក់ទងឈ្មោះ វ៉ាល់ ដើម្បីបញ្ចេញកងចល័ត១០នាក់នៅថៃ និងកម្លាំងមួយចំនួនទៀតតាមស្រុក និងអង្គភាព នៅចុងខែមេសា ក្នុងឆ្នាំដដែល ភឿន និង ផាវ វើងស្រ៊ី បានធ្វើឲ្យស្ទះចលនាស្រែដើមដៃ នៅគោករំចេក ដោយធ្វើឲ្យខូចម៉ាស៊ីនបូមទឹកដាក់ស្រែ ហើយកម្លាំង២០០នាក់ទៀត ស្ទូងមួយថ្ងៃបាន២ហិចតាតែប៉ុណ្ណោះ ដោយសារស្ទះសំណាប ដែលអង្គការផ្តល់ឲ្យបានខូចអស់ជាច្រើន និងសល់សំណាបយ៉ាងសន្ធឹកសន្ធាប់ ហើយ ភឿន និងបក្សពួកបានធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍យ៉ាងសកម្មជាច្រើនរហូតដល់អង្គការចាប់ខ្លួន ម៉ែន ភឿន បាននៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៧ ។

**ហូ ថុនា**

# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសារ ចាប់ពីខែមេសា ដល់ ខែធ្នូ ឆ្នាំ២០១៦
















*កាលបរិច្ឆេទបញ្ចាំងៈ រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង១០ៈ០០ព្រឹក និង ម៉ោង៥ៈ១៥ រសៀល*

*ទីតាំងៈ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ*

លោក ម៉ែន ពិចិត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជា

ទូរសព្ទលេខ ០២៣ ២១៨ ០០៩

អ៊ីម៉ែលៈ truthmpechet@dccam.org

គេហទំព័រៈ www.dccam.org l www.cambodiasri.org

**ខែមេសា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ១៥ ៖ ១៥ រសៀល បញ្ចាំងរឿង «គុកឥតជញ្ជាំង» ដោយទូរទស្សន៍ជាតិកម្ពុជា (៩៥ នាទី)

◆ ថ្ងៃទី៨ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង «ការងារសម្ងាត់នៅមន្ទីរស-២១» ដោយ ដេវីត អូកូហ្វូណា (David Okuefuna) (៣០ នាទី)

◆ ថ្ងៃទី២២ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង «ឋាននរក៩ជាន់» ដោយ Cinema Dept. FPD ក្នុងឆ្នាំ១៩៨៧ (១៣១.២៨នាទី)

◆ ថ្ងៃទី២៩ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង «ប្រាសាទអង្គរវត្តដែលកំបាំង» ដោយ Discover Magazine ក្នុងឆ្នាំ១៩៩៩ (៣០.១៥ នាទី)

**ខែឧសភា ឆ្នាំ២០១៦**

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង «កម្ពុជា ៖ ការស្លាប់ និង ការចាប់កំណើត» ដោយ Germany ក្នុងឆ្នាំ១៩៨០ (៩០ នាទី)

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង «អង្គការ» ដោយ Germany ក្នុងឆ្នាំ ១៩៨១ (៩០ នាទី)

**ខែមិថុនា ឆ្នាំ២០១៦**

◆ ថ្ងៃទី៣ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង «សង្គ្រាមក្នុងព្រៃ» ដោយ Germany ក្នុងឆ្នាំ ១៩៨៣ (៩០ នាទី)

◆ ថ្ងៃទី១០ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង «រវាងសន្តិភាព និងយុត្តិធម៌ ៖ រឿងកន្ទួលហួសទៅសូមឲ្យកន្ទួលហួសទៅចុះ» ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) ក្នុងឆ្នាំ១៩៩៩ (៣៧ នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង «ជីវិ២ (ជីវិជនភៀសខ្លួន)» ដោយ រិទ្ធី ប៉ាន់ ក្នុងឆ្នាំ១៩៨៩ (៦០ នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលា ម៉ោង ១០ ព្រឹក និង ម៉ោង ៥ ៖ ១៥ រសៀល បញ្ចាំងរឿង «ប៉ុល ពត ៖ ការសម្លាប់» ដោយ ភីធើ ហើខំ (Peter Hercombe) (៥១ នាទី)

**ខែកក្កដា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែកក្កដា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «សាក្សីកម្ពុជា» បណ្ណសាររបស់ ដេវីត ហក (David Hawk Archives) (១១១.២នាទី)

◆ ថ្ងៃទី៨ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «សកម្មភាពគោរពវិញ្ញាណក្ខន្ធនៅបូជនីយដ្ឋានជើងឯក» ដោយ FPD ក្នុងឆ្នាំ១៩៩៨

◆ ថ្ងៃទី១៥ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «ព្រះអាទិទេពចុងក្រោយ» ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១១៨នាទី)

◆ ថ្ងៃទី២២ ខែកក្កដា វេលាម៉ោង១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «តំបន់អន្លង់វែង (តាម៉ុក)» ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១៧៤.៥៧នាទី)

◆ ថ្ងៃទី២៩ ខែកក្កដា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «កម្ពុជា ៣បូក៤ ឆ្នាំទីសូន្យ និងឆ្នាំទី១» ក្នុងឆ្នាំ១៩៧៩ (១៥៦នាទី)

**ខែសីហា ឆ្នាំ២០១៦**

◆ ថ្ងៃទី៥ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ស្រមោលអតីតកាល : រឿងចំនួនបួនដែលនិយាយអំពីការផ្សះផ្សា» ដោយ Express TV (១២០នាទី)

◆ ថ្ងៃទី១២ ខែសីហា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ :១៥ រសៀល បញ្ចាំងរឿង «ស្រមោលរបស់ ប៉ុល ពត» ដោយ អាមេនដា ផៃក (Amanda Pike) ក្នុងឆ្នាំ២០០២ (២៥នាទី)

◆ ថ្ងៃទី១៩ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «ក្តីសង្ឃឹមដ៏តិចតួចចេញពីវាលពិឃាត» ដោយ ធារ៉ា ដេលហ្គាដូ (Tiara Delgado) (៣៨នាទី)

◆ ថ្ងៃទី២៦ ខែសីហា វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ទម្លាយភាពស្ងប់ស្ងាត់» ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា (៦៩នាទី)

**ខែកញ្ញា ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែកញ្ញា វេលាម៉ោង១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «បទសម្ភាសន៍ជាមួយ ប៉ុល ពត» ដោយ ភីធើ ហ្វ្រូបឺក (Peter Froberg) ក្នុងឆ្នាំ២០០៤ (៥១នាទី)

◆ ថ្ងៃទី៩ ខែកញ្ញា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «ប៉ុល ពត : ដំណើរទៅកាន់វាលពិឃាត» ដោយ ជេន ចនស្តុន (Jane Johnston) (៥០នាទី)

◆ ថ្ងៃទី១៦ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «យុត្តិធម៌ដែលបានពន្យាពេល និងយុត្តិធម៌ដែលបានបដិសេធ (ការកាត់ទោសមេដឹកនាំខ្មែរក្រហម)» ក្នុងឆ្នាំ២០០៥ (៥៤.២៤នាទី)

◆ ថ្ងៃទី២៣ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «រឿងរ៉ាវពីទឹកដីកម្ពុជាក្រោម» (៧០នាទី)

**ខែតុលា ឆ្នាំ២០១៦**

◆ ថ្ងៃទី៧ ខែតុលា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "នៅក្រោយជញ្ជាំងមន្ទីរស-២១" ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៧ (៣០ នាទី)

◆ ថ្ងៃទី១៤ ខែតុលា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ដំណើរទៅកាន់វាលពិឃាត" ដោយ ជេន ចនស្តុន (Jane Jonhston) (៥០ នាទី)

◆ ថ្ងៃទី២១ ខែតុលា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ដល់ពេលស្វែងរកយុត្តិធម៌" ដោយ KMF Films ក្នុងឆ្នាំ២០០៧ (៤០ នាទី)

◆ ថ្ងៃទី២៨ ខែតុលា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "មើលទៅមុខ មើលទៅក្រោយ" ដោយ DMC ក្នុងឆ្នាំ២០០៧ (៥២.៣០ នាទី)

**ខែវិច្ឆិកា ឆ្នាំ២០១៦**

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ការរាំទៅរកការស្លាប់ : សត្តស្មា មន្តអាគម និងភាពរិលវល់របស់កម្ពុជា" ដោយ ចេនេត ហ្កាតនើ (Janet Gardner) ក្នុងឆ្នាំ២០១០ (៥៦ នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ការកាត់ទោស ប៉ុល ពត នៅអន្លង់វែង នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧" ដោយ ឡុង សារិន ក្នុងឆ្នាំ ១៩៩៧ (៤៣.៣០ នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "៣ឆ្នាំ ៨ខែ ២០ថ្ងៃ" ដោយ រ៉ូសេន សេដណាតា (Roshane Saidnattar) ក្នុងឆ្នាំ២០០៩ (៩៨.០៦ នាទី)

◆ ថ្ងៃទី២៥ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ក្មេងសម្រាប់ដាក់លក់" ដោយ NBC TV ក្នុងឆ្នាំ២០០៤ (៤៣ នាទី)

**ខែធ្នូ ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "វិប្បដិសារី" ក្នុងឆ្នាំ២០០៨ (Royal Archives)

◆ ថ្ងៃទី៩ ខែធ្នូ វេលាម៉ោង១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "កងទ័ពខ្មែរក្រហម" ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) និង សេន មេត្តា (Sien Meta) ក្នុងឆ្នាំ ២០០៧ (៩៥ នាទី)

◆ ថ្ងៃទី១៦ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ពេលព្រះអាទិត្យអស្តង្គត" ដោយ ព្រះបាទ នរោត្តម សីហនុ

◆ ថ្ងៃទី២៣ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "កុំស្មានបងភ្លេច : ខ្មែរបាត់បង់តន្ត្រីរ៉ក់" ដោយ ចន ពីរ៉ូស៊ី (Jonh Pirozzi) (១០៧ នាទី)

◆ ថ្ងៃទី៣០ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ក្បូនទឹកទន្លេ" ដោយ កល្យាណី ម៉ម ក្នុងឆ្នាំ២០១២ (៨៣ នាទី)

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ភាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិន សុធីតា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truththida.s@dccam.org* ។




















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬកា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល : truthmpechet@dccam.org ។

**◆ ទីកន្លែង : អគារ “ក” ជាន់លើ ◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# គេហទំព័រទស្សនាវដ្តីស្វែងរកការពិតជាភាសាខ្មែរ
# www.truthcambodia.com

ទស្សនាវដ្តីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។

គេហរទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្តីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្រ្តខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។

គេហទំព័រ www.truthcambodia.com បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្រ្ត ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។

អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើង ដោយស្ទេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្រ្តនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្រ្តខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្រ្តនេះឲ្យមានភាពកាន់តែសុក្រឹតទ្បើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្តល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្តិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យ ដើម្បីសេចក្តីសុខក្នុងខ្លួនជាអមតៈដែរ ។

សរុបសេចក្តីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ធ្វើសេចក្តីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទ មុនការចេញផ្សាយ ។

គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *www.cambodiatribunal.org* គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *www.cambodiatribunal.org* ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូ សវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការ និងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់ សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរ ការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញ និងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Join Criminal Enterprise*" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Common Criminal Plan*" ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេ ដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។ **វ៉ាន់ថាន់ ពៅដារ៉ា**

# ដំណើងយុវជន-យុវនារីបដិវត្តន៍

*ដកស្រង់ចេញពីឯកសារយុវជន និងយុវនារីបដិវត្តន៍លេខ១០ ខែតុលា ឆ្នាំ១៩៧៥ D២១៣៨៤*

### ១) លោកទស្សនៈបដិវត្តន៍ថ្មីរបស់យុវជន-យុវនារីកម្ពុជាយើង ចំពោះចំណេះវិជ្ជា

កាលនៅក្នុងសង្គមចាស់ ដែលជាសង្គមអាណានិគមពាក់កណ្តាលសក្តិភូមិ យុវជន-យុវនារីកម្ពុជាយើង ស្ថិតនៅក្រោមឥទ្ធិពលនៃមនោគមវិជ្ជា និងការឃោសនាអប់រំរបស់ចក្រពត្តិសក្តិភូមិនាយទុន ពួកចក្រពត្តិ សក្តិភូមិ នាយទុន ដែលជាវណ្ណៈជិះជាន់ ហុតឈាម អង្កៀមឆ្អឹងប្រជាជនក្រីក្រ ជាវណ្ណៈពុករលួយ និងប្រតិកិរិយាផុតលេខ វាបានពន្លក់ បំពុល និងឃោសនាអប់ យុវជន-យុវនារីកម្ពុជាយើង ឲ្យស្រឡាញ់ ឲ្យគោរព ឲ្យមានជំនឿផ្តេសផ្តាស់ យកខ្មៅជាស យកអាក្រក់មកជាល្អ ដើម្បីពួកវាងាយស្រួយកែកាឡៃយុវជន-យុវនារីកម្ពុជាយើង ឲ្យទៅជាឧបករណ៍បម្រើការជិះជាន់ការលោភលន់ និងអំពើពុករលួយ ពាលាអាវ៉ាសែរបស់ពួកវា ។ ម៉្លោះហើយ យុវជន-យុវនារីកម្ពុជាយើងមួយភាគធំ មានការវង្វេង មានការភាន់ច្រឡំទៅតាមលោកទស្សនៈរបស់វណ្ណៈជិះជាន់ ។ យុវជន-យុវនារីកម្ពុជាយើង កាលនៅក្នុងសង្គមចាស់និយមរៀនរាំបារាំង រៀនផឹកស្រាបារាំង ស្រាឡាបីយែរ រៀនបោកចំបាប់វាយតប់គ្នា បែបហ្វាស៊ីសជប៉ុន បែបអាយ៉ងតៃវ៉ាន់ បែបអាយ៉ងសេអ៊ូល (កូរ៉េខាងត្បូង) ដែលមានឈ្មោះថា ហ៊្សុយដូ ការ៉ាតេ តៃក្វាន់ដូ ។ល ។ គេទាំងឡាយមានមោទកភាព និងបានចេះដឹងនូវវិជ្ជាពាលាអាវ៉ាសែបែបនេះ ។

ក្រោយរំដោះទូទាំងប្រទេស បក្សបានឃោសនាអប់រំឲ្យយុវជន-យុវនារីកម្ពុជាយើង ចេះស្រឡាញ់ជាតិ ស្រឡាញ់ទឹកដី



កម្មករកោងចក្រតម្បាញ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-៧៩) កំពុងពិនិត្យមើលអំបោះ

ស្រឡាញ់ប្រជាជន ហើយបំផុសគេទាំងឡាយ ឲ្យចូលរួមប្រាស្រ័យក្នុងមហាចលនាបង្កបង្កើនផល ដើម្បីការពារប្រទេស និងកសាងប្រទេសឲ្យបានឆាប់រហ័ស ។ យុវជន-យុវនារីកម្ពុជាយើង ក៏បានចូលក្នុងមហាចលនាបង្កបង្កើនផលនេះគ្រប់ៗគ្នា ។ ម្យ៉ាងដោយមានបក្សឃោសនាអប់រំ បំពាក់បំប៉នជាប់ទាំងខាងទស្សនៈ គោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ តែម្យ៉ាងទៀតដោយបានរួមរស់នៅជាប់ជិតស្និទ្ធជាមួយនឹងប្រជាជនកម្មករកសិករ ហើយបានចូលរួមប្រឡូកដោយផ្ទាល់ធ្វើពលកម្មបង្កបង្កើនផលទៀត លោកទស្សនៈរបស់យុវជន-យុវនារីកម្ពុជាយើង ក៏បានកែប្រែយ៉ាងឆាប់រហ័ស ។ សព្វថ្ងៃនេះ យុវជន-យុវនារីកម្ពុជាយើងបានឃើញច្បាស់ថា ចំណេះវិជ្ជាធំ និងខ្ពង់ខ្ពស់ជាងគេបំផុតនៅក្នុងលោកនេះ គឺចំណេះវិជ្ជាខាងបង្កបង្កើនផល ។ បើអ្នកណាចេះវិជ្ជាបង្កបង្កើនផលនេះ ទើបរស់ ទើបមានកិត្តិយសថ្លៃថ្នូរ ។ ដូច្នេះ យុវជនយុវនារីកម្ពុជាយើង ក៏បានយកចិត្តទុកដាក់ខិតខំរៀនធ្វើស្រែ រៀនភ្ជួររាស់ដកស្ទូងប្រូតកាត់ រៀនឃ្វាលគោក្របី ចូលរួមប្រាស្រ័យក្នុងចលនាលើកទំនប់ ជីកប្រឡាយ លើកភ្លឺ ដើម្បីដោះស្រាយបញ្ហាបង្កបង្កើនផលយ៉ាងសស្រោកសស្រាំទាំងយប់ទាំងថ្ងៃ ។ គេទាំងឡាយមានមោទកភាពបដិវត្តន៍យ៉ាងសមរម្យ ចំពោះចំណេះវិជ្ជាបង្កបង្កើនផលនេះ ។ ហើយគេទាំងឡាយ ក៏បានឃើញច្បាស់ថា មានចំណេះវិជ្ជាបង្កបង្កើនផល ទើបគេទាំងឡាយ មានតួនាទីរួមចំណែកការពារប្រទេស កសាងប្រទេស ព្រមទាំងកែប្រែកសាងសង្គមកម្ពុជាថ្មីឲ្យបានរីកចម្រើនល្អតលាស់ លោតផ្លោះទៅមុខ យ៉ាងឆាប់រហ័ស និងធ្វើឲ្យប្រទេសកម្ពុជា ប្រជាជាតិ និងប្រជាជនកម្ពុជា មានកិត្តិនាម កិត្តិស័ព្ទល្បីល្បាញ ថ្កុំថ្កើង រុងរឿង នៅលើសកលលោក ។

នេះជាលោកទស្សនៈបដិវត្តន៍ថ្មីរបស់យុវជន-យុវនារីកម្ពុជា ចំពោះចំណេះវិជ្ជា នៅក្នុងសង្គម ដែលគេទាំងឡាយត្រូវរៀនសូត្រ ។

## ២) វីរភាពរបស់កងផលិតចល័ត នៅភូមិភាគពាយ័ព្យ

សព្វថ្ងៃនៅគ្រប់តំបន់ ក្នុងភូមិភាគពាយ័ព្យ ពិសេសក្នុងខេត្តបាត់ដំបង មានចាត់តាំងកងចល័តជាច្រើនក្រុម ដែលជាកងផលិតស្រួចសម្រាប់ចល័តចុះឡើង វាយសម្រុកបង្កបង្កើនផល នៅគ្រប់ទីកន្លែងណា ដែលមានលក្ខណៈសម្បត្តិល្អហើយ តែខ្វះកម្លាំងពលកម្ម ។ សមាជិកនៃកងចល័តនេះសុទ្ធសឹងជាយុវជន-យុវនារី ដែលកំពុងពេញកម្លាំងធ្វើការ ។ គេចាត់តាំងកងកងចល័តនេះ ជាកងអនុសេនាធំ (មានសមាជិកពី១០០ ទៅជាង១០០នាក់) និងជាកងវរសេនាតូច (មានសមាជិកពី៣០០ ទៅជាង៣០០នាក់) ។ កងចល័តនេះ វាដើរវាយសម្រុកធ្វើការងារគ្រប់បែបយ៉ាង ដើម្បីជំរុញចលនាបង្កបង្កើនផលឲ្យបានផុសផុលខ្លាំងក្លា និងលឿនឆាប់រហ័សទាន់ពេលវេលា ។ ឲ្យតែកន្លែងណាត្រូវការចាំបាច់ កងនេះនាំគ្នាទៅបោះជំរំនៅកន្លែងនោះ ហើយវាយសម្រុកធ្វើការងារទាំងយប់ទាំងថ្ងៃរហូតទាល់តែបានហើយស្រេច ទើបវាចល័តទៅធ្វើកន្លែងផ្សេងទៀត ។ ក្រុមនេះមានភារកិច្ចពីរយ៉ាង ម្យ៉ាងគឺបង្កបង្កើនផលនៅលើកសិដ្ឋានរបស់ខ្លួន ហើយម្យ៉ាងទៀតមានភារកិច្ចដើរចល័តទៅជួយលើកដៃធ្វើការងារបង្កបង្កើនផលជាមួយសហករណ៍នានា ។

ជាដំបូង កងចល័តនេះត្រូវប្រយុទ្ធបង្កបង្កើនផលនៅលើដីស្រែជាកសិដ្ឋានរបស់ខ្លួន ឲ្យបានហើយស្រេចដោយឯករាជ្យ ម្ចាស់ការ និងឆាប់រហ័ស ។ រួចហើយទើបដកកម្លាំងចេញទៅជួយវាយសម្រុកជំរុញចលនាបង្កបង្កើនផល នៅតាមសហករណ៍នានាទៀត ។ តែក្នុងពេលដែលកងនេះកំពុងធ្វើស្រែខ្លួនក៏ដោយ បើសហករណ៍នានា មានការចាំបាច់ជាបន្ទាន់ ក៏កងចល័តនេះ វាចាត់ចែងកម្លាំងរបស់វាមួយផ្នែកធំ ឲ្យទៅជួយខាងសហករណ៍នានាសិនដែរ ។

ភារកិច្ចវាក្នុងពេលដែលចល័តទៅជួយតាមសហករណ៍នានា មានដូចតទៅៈ

◆ កាប់រានឆ្ការ ហែកស្រែថ្មី ចំពោះសហករណ៍ណាដែលខ្វះដី ឬមានដីតិច

◆ ជួយភ្ជួររាស់ដកស្ទូង ចំពោះសហករណ៍ណា ដែលមានទឹកមុខគេ ហើយខ្វះកម្លាំងវាយសម្រុកធ្វើឲ្យទាន់ទឹក ។

◆ ជួយលើកទំនប់ ជីកប្រឡាយ បង្ហូរទឹកពីស្ទឹងទៅវាលស្រែ ចំពោះតំបន់ណាដែលខ្វះទឹក ឬដែលមានភ្លៀងធ្លាក់មិនគ្រប់គ្រាន់ ។

◆ ជួយកាប់រំលាយភ្លឺស្រែតូចៗពីសង្គមចាស់ ហើយជួយលើកជាប្រព័ន្ធភ្លឺស្រែថ្មី ខ្វាត់ខ្វែងជាក្រឡាឈើគ្រន់ ដើម្បីទប់ទឹកភ្លៀងឲ្យដក់ជាប់នៅក្នុងស្រែ ចំពោះកន្លែងណាដែលមានភ្លៀងធ្លាក់គ្រប់គ្រាន់ តែពុំទាន់មានពិសោធធ្វើប្រព័ន្ធភ្លឺថ្មីដើម្បីប្រើប្រាស់ទឹកភ្លៀងនេះឲ្យបានពេញទំហឹង ។

◆ ជួយប្រូតកាត់ឲ្យបានទាន់ពេលវេលា កុំឲ្យស្រូវទុំ ត្រូវភ្លៀង

ខូច ឬកុំឲ្យស្រូវទុំបាក់កខូចទាន់ ចំពោះក្រុមសហករណ៍ណា ឬតំបន់ណាដែលមានស្រូវទុំច្រើនមុនគេ ហើយកម្លាំងក្នុងសហករណ៍នោះសម្រុកប្រូតកាត់មិនទាន់ ។ល ។

យុវជន-យុវនារីនៃកងផលិតចល័តទាំងនេះ បានវាយសម្រុកបំពេញភារកិច្ចទាំងប៉ុន្មានខាងលើនេះ យ៉ាងសស្រោកសស្រាំទាំងយប់ទាំងថ្ងៃ ដោយពុះពារនូវគ្រប់ឧបសគ្គ ទ្រាំទ្រការលំបាក ហត់នឿយ ក្ដៅ រងារ ភ្លៀង ខ្យល់ ត្រាំទឹកត្រាំភក់ ដេកនៅតែក្នុងជំរំកៅស៊ូតាមព្រៃគម្ពោត ។ល ។ តែបងប្អូនរីករាយ ជ្រះថ្លា និងសុទិដ្ឋិនិយមបដិវត្តន៍ជានិច្ច គិតតែពីធ្វើយ៉ាងណា សម្រេចភារកិច្ចរបស់ខ្លួនខាងលើនេះ ឲ្យបានជោគជ័យទាំងស្រុង ។ ដូច្នេះហើយ បានតែកងផលិតចល័តនេះ ចេញទៅធ្វើសកម្មភាពនៅត្រង់ណាហើយ នៅកន្លែងនោះ គឺប្រាកដជារបើករបាញ ធុះធ្លាយទាំងអស់គ្មានកិច្ចការអ្វីដែលថាមិនកើត គ្មានបញ្ហាស្មុគស្មាញអ្វី ដែលថាដោះស្រាយមិនបាននោះឡើយ ។

ដូច្នេះ ចាប់តាំងពីពេលដែលកងផលិតចល័តនេះត្រូវបានបង្កើតឡើង ម្យ៉ាងកងចល័តនេះបានរួមចំណែកយ៉ាងសកម្ម និងស័ក្តិសិទ្ធបំផុត ក្នុងការបំផុសបំផុល និងជំរុញចលនាបង្កបង្កើនផលក៏ដូចក្នុងការដោះស្រាយបញ្ហាស្មុគស្មាញ ដែលចោទមានឡើងនៅក្នុងចលនាបង្កបង្កើនផល នៅក្នុងភូមិភាគពាយ័ព្យដែរ ម្យ៉ាងទៀតកងផលិតចល័តនេះ វាមានតួនាទីឃោសនាអប់រំផង និងផ្សព្វផ្សាយនូវពិសោធបច្ចេកទេសបង្កបង្កើនផលផ្សេងៗ ដែលថ្មីល្អពីសហករណ៍មួយ ពីតំបន់មួយទៅតំបន់មួយ ។ ម្យ៉ាងទៀត ដោយវាមានការចាត់តាំងច្បាស់លាស់ និងខ្ពស់ មានអង្គការវិន័យហ្មត់ចត់ ត្រឹមត្រូវរបៀបជាយោធាទាំងក្នុងការរស់នៅ ទាំងក្នុងពេលធ្វើការងារ កងផលិតចល័តនេះ បានទៅជាគំរូប្រយុទ្ធស្រួចនឹងធម្មជាតិ ក៏ដូចប្រយុទ្ធដោះស្រាយទំនាស់ និងការស្មុគស្មាញក្នុងចលនាបង្កបង្កើនផលជាគំរូក្នុងការទ្រាំទ្រលំបាក ហត់នឿយ សព្វបែបយ៉ាង មិនដែលរាថយមិនដែលត្អូញត្អែរមួយម៉ាត់ឡើយ ។ វាក៏ជាគំរូលះបង់ខ្ពស់គ្មានគិតផលប្រយោជន៍ស្លួនតួ របស់បុគ្គលខ្លួន ក៏ដូចជារបស់អង្គភាពខ្លួន ធ្វើយ៉ាងណាឲ្យតែផលប្រយោជន៍រួមរបស់ប្រជាជន របស់សហករណ៍ និងរបស់ប្រទេសជាតិ បានចម្រើនលូតលាស់ ។ ដូច្នេះ វាធ្វើជាគំរូឲ្យដល់សហករណ៍នានា ក្នុងការគិតគូរផលប្រយោជន៍ សមូហភាពធំទូលាយខ្ពស់បំផុត ។

## ២) ស្មារតីប្រយុទ្ធធ្វើការងារបដិវត្តន៍របស់យុទ្ធជនពិការយើង នៅស្រុកពញ្ញាក្រែក ខេត្តកំពង់ចាម

នៅក្នុងមន្ទីរស្រុកពញ្ញាក្រែក ខេត្តកំពង់ចាមសព្វថ្ងៃ មានបងប្អូនយុទ្ធជនពិការ កាលពីសម័យសង្គ្រាមបដិវត្តន៍មួយចំនួន បងប្អូនទាំងនេះ សុទ្ធតែបានទទួលការទំនុកបម្រុង ថែបំប៉នគ្រប់បែបយ៉ាងអំពីបក្ស មានតាំងពីថ្នាំសង្កូវ ផ្ទះសម្បែង សម្លៀកបំពាក់រហូតដល់សតិអារម្មណ៍នយោបាយទៀត ។ ទោះបីជាយ៉ាងនេះក៏ដោយក៏បងប្អូនយើង មិនចេះនៅទំនេរដៃដែរ ។ បងប្អូនខ្លះបានចុះជួយបង្ហាត់បង្រៀនអក្សរ និងលេខ ឲ្យដល់ក្មួយៗកុមារនៅតាមមូលដ្ឋានភូមិ-ឃុំ ។ បងប្អូនខ្លះ ចុះប្រឡូកបង្កបង្កើនផលជាមួយបងប្អូនឯទៀតៗ នៅក្នុងមន្ទីរ ឬជាមួយប្រជាជននៅក្នុងសហករណ៍ បងប្អូនខ្លះចុះប្រឡូកភ្ជួររាស់ ដកស្ទូង និងដាំដំណាំយុទ្ធសាស្ត្របន្ទាប់បន្សំផ្សេងទៀតមានដំឡូង ចេក ដូង អំពៅជាដើម នៅក្នុងមន្ទីរ ឬនៅក្រោមន្ទីរ គ្មានទុកដីឲ្យសល់ទំនេរឡើយ ។ បងប្អូនខ្លះ ទៅជួយឃ្វាលគោ សេះ ជួយថែបំប៉នគោ ក្របី សេះ បោសសំអាតក្រោល កើបអាចម៍វាយកទៅដាក់ក្នុងរណ្ដៅជី ។ ទន្ទឹមគ្នានេះ បងប្អូនក៏នៅបានខំចិញ្ចឹមសត្វមាន ជ្រូក មាន់ ទា ជាដើម យកសាច់ឧបត្ថម្ភមន្ទីរខ្លួន ដោយស្មារតីឯករាជ្យ ម្ចាស់ការខ្លួនឧបត្ថម្ភខ្លួនកម្រិតខ្ពស់ ។ បងប្អូនខ្លះ បិតប្ញស្សី ឬផ្ដៅ ធ្វើល្អី កញ្ជើ បង្គី ទុកប្រើប្រាស់នៅក្នុងមន្ទីរផង និងឧបត្ថម្ភសហករណ៍ផ្សេងៗផងក្នុងពេលដែលបងប្អូនសហករណ៍ ជាប់ដៃលើកទំនប់ ។

ធ្វើលប ធ្វើទ្រូ យកទៅដាក់ក្នុងទឹកទំនប់ស៊ីងបាក់អាយដ៏ធំល្វឹងល្វើយ ដើម្បីរកត្រីហូប ។ បងប្អូនខ្លះទៀតដែលមានបច្ចេកទេសជួយជួសជុលរហាត់ទឹក ផាលនង្គ័ល រនាស់ រទេះគោ ឬរទេះសេះរបស់សហករណ៍ ឬមន្ទីរនានា ។ ជួយសង់ផ្ទះ សង់សាលារៀនឲ្យកុមារ ឬធ្វើឃ្លាំងទុកសម្ភាររបស់អង្គការ ។ល ។

ក្នុងឋានៈជាយុទ្ធជនពិការ បងប្អូនមានសុភមង្គលណាស់ ដោយបានប្រយុទ្ធបំពេញភារកិច្ចបដិវត្តន៍ បង្កបង្កើនផលជាមួយប្រជាជនកសិករយើង និងយុទ្ធជន-យុទ្ធនារីយើងឯទៀតៗ ដើម្បីរួមចំណែកការពារ និងកសាងប្រទេស ទៅតាមទិសដៅរបស់បក្សឲ្យបានឆាប់រហ័សបំផុត ។

**ឆេង ម៉េង**

# ខ្ញុំជឿជាក់លើអំពើល្អ



ហុង ស៊ីងអេង

នៅពេលដែលប្រជាជនខ្មែរគ្រប់គ្នារំពុកដល់ថ្ងៃ១៧ មេសា ១៩៧៥ គឺមិនមែនរំពុកពីភាពរីករាយពីការជួបជុំគ្រួសារក្រោយថ្ងៃចូលឆ្នាំខ្មែរ ប្រពៃណីជាតិដូចនាពេលបច្ចុប្បន្ននោះទេ ។ ផ្ទុយមកវិញ គឺជាថ្ងៃដែលរំពុកដល់ការឈឺចាប់ ព្រាត់ប្រាសគ្រួសារ មនុស្សជាទីស្រឡាញ់ និងចាកឆ្ងាយពីផ្ទះសម្បែង ដែលប្រព្រឹត្តដោយខ្មែរក្រហម ។ ក្រោយជ័យជម្នះ ខ្មែរក្រហមបានជម្លៀសប្រជាជននៅក្នុងទីក្រុងភ្នំពេញទាំងអស់ដោយបង្ខំឲ្យទៅធ្វើការជាទម្ងន់នៅទីជនបទចុងកាត់មាត់ញក ។

អ្នកដែលមានវាសនារស់រានពីរបបយង់ឃ្នងមួយនេះត្រូវបានចាត់ទុកថា ជាអ្នកដែលមានសំណាង ។ មកដល់បច្ចុប្បន្ន ទោះបីជាអ្នករស់រានទាំងនេះ មានក្តីរីករាយជាមួយនឹងគ្រួសារ និងជីវភាពថ្មីក៏ដោយ ប៉ុន្តែគាត់នៅតែលាក់បង្កប់នូវសេចក្តីទុក្ខព្រួយដោយសារការបាត់បង់នូវសមាជិកម្នាក់ៗ ។

កំពុងតែអង្គុយស្តាប់មិត្តរួមការងារសម្ភាសអ៊ំស្រីម្នាក់ពីបទពិសោធន៍ជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហមយ៉ាងយកចិត្តទុកដាក់ ។ មីងម្នាក់ជិះកង់ផលិតនៅប្រទេសជប៉ុន មកឈប់ក្បែរខ្ញុំ ហើយញញឹមយ៉ាងរួសរាយមកកាន់ខ្ញុំ និងសួរខ្ញុំថា "ក្មួយកំពុងធ្វើអ្វី?" ។ ខ្ញុំបានឆ្លើយទៅគាត់វិញថា "ខ្ញុំទាំងពីរកំពុងសម្ភាសអ៊ំស្រីពីជីវិតគាត់ក្នុងរបបខ្មែរក្រហម" ។ គាត់ក៏តបមកខ្ញុំវិញដោយញញឹមថា "គាត់ក៏ធ្លាប់ឆ្លងកាត់របបនោះដែរ" ។ ឆ្លៀតឱកាសនេះ ខ្ញុំក៏សួរទៅគាត់វិញថា "តើខ្ញុំអាចសម្ភាសពីបទពិសោធន៍ជីវិតមីងនៅរបបខ្មែរក្រហមបានទេ?" ។ ពេលនោះ ស្នាមញញឹមរបស់គាត់ប្រែជាស្រពោនមួយរំពេចបន្ទាប់ពីឮសំណួររបស់ខ្ញុំ ។ គាត់ហាក់ដូចជាចង់រារែកមិនចង់និយាយពីជីវិតគាត់នៅរបបខ្មែរក្រហមនេះទេ ។ ចម្លើយតបជាមួយនឹងភាពស្រងូតស្រងាត់មកកាន់ខ្ញុំ គាត់និយាយថា បើខ្ញុំចង់ដឹង គាត់នឹងរៀបរាប់ប្រាប់ពីកុមារភាព និងការតស៊ូរបស់គាត់នៅរបបខ្មែរក្រហមដល់ខ្ញុំ ។ សញ្ជឹងគិតមួយសន្ទុះ ទើបគាត់រៀបរាប់ពីប្រវត្តិរបស់គាត់ដូចខាងក្រោមថា ៈ

### គ្រួសារ និងការជម្លៀសដោយបង្ខំ

គាត់ឈ្មោះ ហុង ស៊ីងអេង ជាកូនទីពីរក្នុងចំណោមបងប្អូនប្រុសស្រី៤នាក់ (ស្រីបីនាក់) ដែលមានឪពុកធ្វើជាគ្រូបង្រៀន និងម្តាយជាមេផ្ទះ ។ ស៊ីងអេង និងគ្រួសាររស់នៅម្តុំផ្សារដើមថ្កូវ (ក្នុងសង្កាត់បឹងត្របែក) ។ ជាកុមារីម្នាក់ដែលបានរៀនត្រឹមថ្នាក់ទី១២ (សង្គមចាស់) គាត់មិនអាចចងចាំបាននូវព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ទេ ។ ប៉ុន្តែគាត់នៅចាំបានចំពោះហេតុការណ៍ដែលបានកើតមានឡើងនៅថ្ងៃទី១៧ មេសា ១៩៧៥ ដែលជាថ្ងៃជ័យជម្នះរបស់កងទ័ពបដិវត្តន៍កម្ពុជា ឬកងទ័ពខ្មែរក្រហម ។ គាត់បានឃើញទាហានខ្មែរក្រហមស្លៀកខោអាវខ្មៅ និងមានអាវុធគ្រប់ដៃ បានដើរប្រាប់ និងបញ្ជាឲ្យប្រជាជនចាកចេញពីផ្ទះមួយរយៈសិន ។

គ្រួសាររបស់ ស៊ីងអេង និង ពូ-មីង (ត្រូវជាប្អូនម្តាយរបស់គាត់) ពីរនាក់ទៀត បានចាកចេញពីផ្ទះតាមបញ្ជារបស់យោធាខ្មែរក្រហម នៅថ្ងៃទី១៧ មេសា ។ គ្រួសារគាត់បាននាំគ្នាធ្វើដំណើរទៅកាន់ស្រុកកំណើតនៅឯភូមិព្រែកតាដួង ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ព្រោះយាយតារបស់គាត់រស់នៅទីនោះស្រាប់ ។ នៅតាមផ្លូវធ្វើដំណើរជាមួយនឹងហ្វូងមនុស្សយ៉ាងច្រើនកុះករ ស៊ីងអេង បានឃើញសាកសពប្របមាត់ផ្លូវ និងយោធាខ្មែរក្រហមកំពុងតែឈរបញ្ជាអ្នកដំណើរឲ្យខំស្រូតដំណើរទៅតាមទិសដែលអង្គការកំណត់ ។

ដោយសារតែមនុស្សណែនណាន់តាន់តាប់ គ្រួសាររបស់ ស៊ីងអេង ត្រូវចំណាយពេលមួយយប់ មួយថ្ងៃ ទើបទៅដល់ភូមិព្រែក

តាដួង ។ ទៅដល់ភូមិ គ្រួសាររបស់គាត់បានទៅរស់នៅជួបជុំនឹងយាយតាតែម្តង ព្រោះគាត់ទាំងពីរជាអ្នកមូលដ្ឋាន ។ ជីតារបស់ ស៊ីងអេង គឺជាអតីតអ្នកមានមុខមាត់ម្នាក់នៅក្នុងភូមិ ព្រោះគាត់ជាអ្នកជំនួញរកស៊ីដូរញដូរជាមួយវៀតណាម ។ ផ្ទះយាយតា ដែល ស៊ីងអេង រស់នៅជាមួយធំទូលាយ ហើយតាមគាត់ចាំ មានទទឹងប្រហែល៨ម៉ែត្រ និងបណ្តោយ១៨ម៉ែត្រ ។

ពេលទៅដល់ដំបូង អង្គការមិនទាន់បែងចែកការងារឲ្យអ្នកជម្លៀសទាំងអស់ធ្វើទេ គឺឲ្យទៅរស់នៅតាមផ្ទះប្រជាជនមូលដ្ឋានចាស់ ហើយអ្នកដែលមានបងប្អូនរស់នៅទីនោះស្រាប់ ដូច ស៊ីងអេង គឺអាចរស់នៅជួបជុំគ្នាបាន ។ ការរស់នៅភូមិព្រែកតាដួងរបស់គ្រួសារគាត់ គឺមានរយៈពេលខ្លីប៉ុណ្ណោះ ។ អង្គការបានប្រកាសឲ្យប្រជាជនថ្មីទាំងអស់ត្រៀមចាកចេញទៅរស់នៅខេត្តពោធិ៍សាត់វិញ លើកលែងតែអ្នកគ្មានប្រពន្ធកូនទើបមិនអនុញ្ញាតឲ្យទៅ ។ ចំពោះ ពូ និងមីងរបស់គាត់ មិនត្រូវបានជម្លៀសចេញទេ ព្រោះគាត់ទាំងពីរនាក់នៅលីវ ។

## ជម្លៀសលើកទីពីរ

មុនពេលជម្លៀស ស៊ីងអេង បានឲ្យដឹងថា អង្គការបានប្រកាសថា អ្នកជម្លៀសទាំងអស់ត្រូវជម្លៀសបន្ត ដោយមិនអនុញ្ញាតឲ្យរស់នៅជាមួយប្រជាជនមូលដ្ឋានទេ គឺត្រូវទៅរស់នៅកន្លែងណាដែលមិនសូវមានមនុស្សរស់នៅ ព្រោះនៅមូលដ្ឋានមានប្រជាជនរស់នៅច្រើនហើយ ។ បន្ទាប់មក អង្គការបានយកឡានមកដឹកប្រជាជនជម្លៀសទាំងអស់ មកកាន់ចំណតរថភ្លើងនៅភ្នំពេញ ។ ទៅដល់ចំណតរថភ្លើង ស៊ីងអេង បានឃើញមនុស្សម្នាយ៉ាងច្រើន (មកពីតំបន់ផ្សេងៗ) កំពុងតែរង់ចាំចេញដំណើរដែរ ។ ស៊ីងអេង និងគ្រួសារត្រូវធ្វើដំណើរជាច្រើនយប់ទើបទៅដល់ខេត្តពោធិ៍សាត់ ហើយនៅតាមផ្លូវធ្វើដំណើរ រថភ្លើងបានឈប់សម្រាកតាមចំណតមួយចំនួនដើម្បីឲ្យអ្នកជម្លៀសដាំបាយហូប និងបន្ទោរបង់ ។ អង្គការបានចែកត្រីប្រម៉ាឲ្យអ្នកដំណើរទាំងអស់ ដោយក្នុងមួយគ្រួសារបានត្រីមួយក្បាលដើម្បីធ្វើម្ហូប ។ ស៊ីងអេង បន្តថា ការឈប់សម្រាកនេះមានរយៈពេលខ្លីប៉ុណ្ណោះ ហើយបើនរណាហូបបាយមិនទាន់ នឹងត្រូវរថភ្លើងចេញដំណើរចោលមិនខាន ។



រូបពីឆ្វេង ៖ ហុង ស៊ីងអេង ផ្តល់បទសម្ភាសន៍ពីរឿងរ៉ាវនៅក្នុងសម័យខ្មែរក្រហម ដល់ ទាវ សារមុនិន្ទ អ្នកសរសេរទស្សនាវដ្តីស្វែងរកការពិត នៅសាលាបណ្តុះបណ្តាលគរុកោសល្យ និងវិក្រិតការ ភូមិភាគខេត្តកណ្តាល

### មកដល់ពោធិ៍សាត់

មកដល់ពោធិ៍សាត់ អង្គការបានប្រមូលអ្នកជម្លៀសទាំងអស់យកទៅដាក់នៅវត្តមួយឈ្មោះ វត្តពោធិ៍វង្ស ។ បន្ទាប់មក ក៏មានរទេះគោមកដឹកអ្នកជម្លៀសបន្តទៅកាន់កន្លែងរស់នៅ ។ ពេលនោះ ឪពុក ម្តាយរបស់ ស៊ឹងអេង បានដើរសួរអ្នកបររទេះនីមួយៗថា គាត់ចង់ទៅរស់នៅតំបន់ណាដែលមានទឹក ព្រោះអ្នកជម្លៀសអាចមានសិទ្ធិរើសកន្លែងដែលខ្លួនចង់ទៅដែលស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ។ ចំណែកអង្គការនៅពេលនោះ ក៏មិនទាន់តឹងរ៉ឹងពេកដែរ ហើយក៏មិនបានកំណត់ថា អ្នកណាទៅរស់នៅឯណាដែរ ។

ក្រោយពេលដែលឪពុកម្តាយរបស់គាត់ ដើរស៊ើបសួរពីតំបន់ណាដែលមានទឹករួចហើយ អ្នកបររទេះគោក៏ដឹក ស៊ឹងអេង និងគ្រួសារទៅដល់សហករណ៍ក្បាលឈើពុក ដែលមានទីតាំងនៅក្បែរស្ទឹងពោធិ៍សាត់ក្នុងភូមិក្បាលឈើពុក ស្រុកកណ្តៀង ។ នៅសហករណ៍នេះ ស៊ឹងអេង ត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅកងកុមារ ដូចជា ដើររើសអាចម៍គោ និងសម្អាតសហករណ៍ ។ ចំណែកឯឪពុកម្តាយរបស់គាត់ត្រូវបានចាត់តាំងឲ្យធ្វើការនៅកងចល័តក្បែរៗភូមិ និងនៅឆ្ងាយពីភូមិបន្ទាប់ពីការងារនៅក្នុងភូមិរួចរាល់ ។ ពេលដែលឪពុកម្តាយទៅធ្វើការចល័តនៅឆ្ងាយ ស៊ឹងអេង ត្រូវមាននាទីរកម្ហូបអាហារសម្រាប់ហូប ។ គាត់ត្រូវទៅរកត្រី និងដកព្រលិត គឺជារឿងមួយដែលប្រថុយគ្រោះថ្នាក់ និងភ័យខ្លាចបំផុត ព្រោះក្នុងទឹកសម្បូរទៅដោយឈ្លើងកន្ធាស់ ហើយបើយើងមិនប្រុងប្រយ័ត្ន ឈ្លើងនឹងអាចចូលក្នុងប្រដាប់ភេទ ឬធ្វើឲ្យយើងស្លាប់ភ្លាម ។

ទោះបីជាពេលនោះ ប្រជាជនត្រូវហូបបាយនៅរោងបាយរួមក៏ដោយ តែអង្គការមិនបានបំបែកឲ្យរស់នៅបែកគ្នាទេ គឺអង្គការបានចែកផ្ទះតូចៗសង់ខ្ពស់ពីដីដែលមានកាំជណ្តើរបីកាំឲ្យស្នាក់នៅ ។ ហេតុដូច្នេះ ប្រជាជនខ្លះអាចលបលួចទៅរកអាហារបន្ថែមហូបនៅផ្ទះបាន ។

### ប្តូរការងារ

ដោយ ស៊ឹងអេង ជាមនុស្សរួសរាយ មានអំណោយទាន គួរជាទីរាប់អាន ក្រោយមក គាត់បានរាប់អានជាមួយក្មួយរបស់ប្រធានសហករណ៍ក្បាលឈើពុក ។ ដោយសារតែ ស៊ឹងអេង ជាមនុស្សខ្សប្រាហ៍ធ្វើការងារ ទើបប្រធានសហករណ៍បានឲ្យ ស៊ឹងអេង ទៅរស់នៅបម្រើឪពុកក្មេកជរារបស់គាត់ ។ ការងារដែល ស៊ឹងអេង ធ្វើនៅពេលនោះ គឺមើលថែទាំឪពុកក្មេកជរារបស់ប្រធានសហករណ៍ ។ រៀងរាល់ថ្ងៃ ស៊ឹងអេង ត្រូវក្រោកទៅរែកទឹកចំនួនដប់អំរែក និងពេលល្ងាចគាត់ត្រូវរែកដប់អំរែកទៀតមកស្រោចអំពៅ បន្លែ ហើយសល់ពេល គឺគាត់មើលថែកូនតូចៗពីរនាក់របស់ប្រធានសហករណ៍ ។

### ជឿជាក់លើអំពើល្អ

ដោយឃើញ ស៊ឹងអេង ជាមនុស្សមិនសូវចេះមាត់ក ស្មោះត្រង់ និងខ្សប្រាហ៍ព្យាយាមធ្វើការ ប្រធានសហករណ៍ពេញចិត្ត និងអាណិតស្រឡាញ់គ្រួសារគាត់យ៉ាងខ្លាំង ។ ប្រធានសហករណ៍បានជួយជីវិតឪពុកមាគាត់ម្នាក់ និងចាត់តាំងឲ្យគ្រួសារ ស៊ឹងអេង ធ្វើការងារស្រាលៗ ។ ជាក់ស្តែង ឪពុករបស់គាត់ត្រូវប្រធានសហករណ៍ចាត់តាំងឲ្យធ្វើការរោងសិប្បកម្ម ។ ក្រោយក៏ប្តូរឲ្យមកធ្វើនៅខាងចុងភៅវិញ ។ ស៊ឹង អេង ពោលមកកាន់ខ្ញុំជាមួយនឹងស្នាមញញឹមផងថា «ធ្វើចុងភៅសម័យខ្មែរក្រហម ហាក់ដូចជាធ្វើគយនៅសម័យនេះអ៊ីចឹង» ។ ពីមុន ឪពុកម្តាយរបស់គាត់ ត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅកងចល័តដែលត្រូវធ្វើការជាទម្ងន់ និងទទួលបានរបបអាហារបន្តិចបន្តួច ។ គាត់បានបន្តទៀតថា «គាត់ជឿជាក់លើអំពើល្អ និងភាពខ្សប្រាហ៍របស់គាត់ ទើបអាចធ្វើឲ្យប្រធានសហករណ៍អាណិតស្រឡាញ់ និងជួយគ្រួសាររបស់គាត់» ។

ចំពោះការហូបចុកសម្រាប់គ្រួសារ ស៊ឹងអេង គឺមិនខ្វះខាតទេ ដោយសារតែប្រធានសហករណ៍ តែងតែអនុញ្ញាតឲ្យគាត់យកម្ហូបអាហារមកផ្ញើគ្រួសារជាញឹកញយ ។ គាត់ប្រាប់ខ្ញុំលាយឡំនឹងសំណើចថា «ពេលខ្លះខ្មែរក្រហមមានមនោសញ្ចេតនា និងការស្រឡាញ់ដែរ ប្រធានសហករណ៍នោះ តែងតែអាណិតស្រឡាញ់គាត់និងគ្រួសារជានិច្ច ទោះបីជាគាត់មើលទៅប្រធានសហករណ៍ជាមនុស្សម្នាក់គួរឲ្យខ្លាចក៏ដោយ ព្រោះគាត់មានភ្នែកក្រហម និងមុខមាំ ។ រៀងរាល់ថ្ងៃគាត់តែងតែសំលៀងកាំបិតផ្គាក់ ហើយនៅម៉ោងប្រហែល ៨ ឬ៩យប់ គាត់លីកាំបិតផ្គាក់ចេញទៅ ក្រោរហូតដល់ទៀបភ្លឺទើបគាត់ត្រឡប់មកវិញ ។ ស៊ឹងអេង បញ្ជាក់ថា មិនដឹងជាគាត់ទៅធ្វើអ្វីនៅទីណានោះទេ ហើយគាត់ក៏មិនហ៊ានសួរដែរ» ។

ស៊ឹងអេង បម្រើនៅផ្ទះប្រធានសហករណ៍ រហូតដល់ថ្ងៃដែលកងទ័ពវៀតណាមមករំដោះ នៅអំឡុងថ្ងៃ២០ មករា ឆ្នាំ១៩៧៩

ព្រោះពេលនោះ ភ្នំពេញត្រូវបានរំដោះមុន ហើយខេត្តមួយចំនួនត្រូវបានរំដោះជាបន្តបន្ទាប់ ។

## វត្តមានរបស់កងទ័ពរំដោះវៀតណាម

នៅពេលដែលកងទ័ពរំដោះវៀតណាមមកកាន់តែជិត ប្រធានសហករណ៍ និងគ្រួសារបានរៀបចំដើម្បីភៀសខ្លួន ។ ប្រធានសហករណ៍នោះ បានហៅ ស៊ីងអេង ទៅជួប និងបានឲ្យមាសយ៉ាងច្រើនមកគាត់ទៀតផង ប៉ុន្តែ ស៊ីងអេង បដិសេធមិនយកមាសទាំងនោះ ។ ប្រជាជនមួយចំនួននៅពេលនោះ ត្រូវខ្មែរក្រហមគៀរឡើងលើភ្នំសំសាន ។ ចំណែក ស៊ីងអេង និងគ្រួសារមិនត្រូវបានប្រធានសហករណ៍ហៅទៅជាមួយនោះទេ គឺគ្រាន់តែហៅមកជួប និងប្រគល់មាសឲ្យ រួចក៏ចាកចេញទៅភ្នំសំសាន បាត់ទៅ ។

ពេលកងទ័ពវៀតណាមចូលមកដល់ ក៏បានប្រកាសតាមមេក្រូឲ្យប្រជាជននៅភូមិទាំងអស់នាំគ្នាត្រឡប់មកវិញ (ឡើងលើ) ។ ស៊ីងអេង និយាយទាំងសំណើចមកកាន់ខ្ញុំថា "ពេលនោះប្រជាជន ឮវៀតណាមថាឲ្យឡើងមកលើស្រាប់តែមិនមែននាំគ្នាឡើងមកទីរួមខេត្ត បែរជានាំគ្នាឡើងលើដំបូលផ្ទះទៅវិញ ព្រោះនឹកស្មានតែវៀតណាមប្រកាសអាសន្ន និងឲ្យប្រុងប្រយ័ត្ន ។ ក្រោយមកវៀតណាមប្រកាសថា អត់ទេ! (មិនប្រកាសអាសន្ន) គឺឲ្យប្រមូលប្រជាជនទៅទីរួមខេត្តទាំងអស់" ។

នៅតាមផ្លូវធ្វើដំណើរមកកាន់ទីរួមខេត្តពោធិ៍សាត់ មានថ្ងៃខ្លះ ខ្មែរក្រហមក៏បានមកស្ទាក់ផ្លូវ និងគៀរប្រជាជនទៅវិញ តែជាសំណាង គ្រួសាររបស់ ស៊ីងអេង បានធ្វើដំណើរមកដល់ទីរួមខេត្ត ដោយសុវត្ថិភាព ។ គ្រួសាររបស់គាត់បានមកសង់ខ្ទមរស់នៅលើកូនកោះមួយ ដែលបច្ចុប្បន្នគេហៅថា កោះសំពៅ ។ ឪពុករបស់គាត់ត្រូវបានជ្រើសតាំងឲ្យធ្វើជាប្រធានភូមិ ។ ដោយភាពស្មោះត្រង់របស់គ្រួសារគាត់ធ្វើឲ្យវៀតណាមពេញចិត្ត និងអាណិតស្រឡាញ់ ។ ក្រោយមកម្តាយរបស់គាត់បានសម្រាលកូនម្នាក់ទៀត ហើយកងទ័ពវៀតណាមតែងតែយកទឹកដោះគោ សាប៊ូ ប្រាក់ ខោអាវមកឲ្យ ។ ស៊ីងអេង នៅតែជឿជាក់លើអំពើល្អរបស់ខ្លួន និងគ្រួសារ ព្រោះថាគ្រួសាររបស់គាត់ទៅដល់ទីណាកន្លែងណា តែងតែមានអ្នកអាណិតស្រឡាញ់ជានិច្ច ។

## រឿងដ៏ខ្លោចផ្សាមួយ

ទោះបីជារបបខ្មែរក្រហមបរាជ័យក៏ដោយ ប៉ុន្តែនៅក្នុងខេត្តពោធិ៍សាត់ នៅតែជាតំបន់ប្រទាញប្រទង់រវាងកងទ័ពវៀតណាម និងខ្មែរក្រហមដដែល ។ នៅផ្ទះរបស់ ស៊ីងអេង និងគ្រួសារដទៃទៀត ត្រូវមានលេណដ្ឋានដើម្បីលាក់ខ្លួនពីការប្រយុទ្ធគ្នារវាងកងទ័ពទាំងពីរ ។ គាត់នៅចងចាំរឿងដ៏ខ្លោចផ្សាមួយ គឺខ្មែរក្រហមបានវាយសន្ទាប់ចូលមក ហើយប្រជាជនមួយចំនួន ក្នុងនោះក៏មានគ្រួសារ ស៊ីងអេង ដែរ បាននាំគ្នារត់នៅពួននៅក្រោមស្ពានមួយជិតវត្តចេតិយ ។ ស្ពានមួយនេះ គឺជាសមរភូមិក្តៅរវាងកងទ័ពទាំងពីរ ព្រោះពេលនោះ កងទ័ពវៀតណាមឈរជើងនៅក្នុងវត្តចេតិយ ។

កងទ័ពទាំងពីរបានប្រយុទ្ធគ្នានៅម្តុំស្ពាន ស្របពេលនោះ គ្រួសារមួយដែលមានកូនតូចលាក់ខ្លួនក្រោម ស្ពានជាមួយនឹងគ្រួសារ ស៊ីងអេង ដែរ ។ ដោយសារឮសំឡេងគ្រាប់កាំភ្លើងខ្លាំងៗពេក ធ្វើឲ្យក្មេងតូចនោះយំយ៉ាងខ្លាំង ។ ប្រសិនជាខ្មែរក្រហមដឹងថាមានមនុស្សនៅក្រោមស្ពានអាចនឹងត្រូវស្លាប់ទាំងអស់គ្នាមិនខាន ។ ហេតុនេះហើយ ពេលដែលក្មេងតូចនោះយំម្តងៗ ឪពុករបស់ក្មេងនោះបានចាប់កូនច្រមុជទឹកកុំឲ្យវាយំឮ ។ នៅព្រឹកឡើង បន្ទាប់ពីការប្រយុទ្ធគ្នាបានបញ្ចប់ ក្មេងតូចដ៏កំសត់នោះ បានឈ្លក់ទឹកស្លាប់ទៅហើយ ម្នាក់ៗបានត្រឹមសោកស្តាយប៉ុណ្ណោះ ។

## ត្រឡប់មកស្រុកកំណើត និងសាងជីវិតថ្មី

ក្រោយរបបខ្មែរក្រហមដួលរលំ ស៊ីងអេង បានបាត់បង់ប្អូនប្រុសម្នាក់ ព្រោះតែឈឺគ្មានថ្នាំព្យាបាលត្រឹមត្រូវ ។ ប៉ុន្មានខែក្រោយមក ឪពុករបស់គាត់បានលាឈប់ពីមេភូមិ និងបាននាំគ្រួសារត្រឡប់មកស្រុកកំណើតនៅឯកោះធំវិញ ។ គ្រួសាររបស់ ស៊ីងអេង ធ្វើដំណើរដោយថ្មើរជើងអស់រយៈពេល២៨ថ្ងៃ ទើបមកដល់កោះធំ ។

ឪពុករបស់គាត់បានចូលធ្វើជាគ្រូបង្រៀន ដែលជាជំនាញរបស់គាត់តាំងពីដើមមក ហើយម្តាយរបស់គាត់ប្រកបរបរលក់គ្រឿងទេស និងនំបញ្ចុក ។ ចំណែក ស៊ីងអេង បានចូលរៀនបន្តទៀត និងបានបញ្ចប់ថ្នាក់បាក់ឌុបនៅឆ្នាំ១៩៨៧ ។ សព្វថ្ងៃរស់នៅក្រុងតាខ្មៅ ខេត្តកណ្តាល ។ គាត់មានគ្រួសារ និងកូនប្រុសម្នាក់ ។ បច្ចុប្បន្ន ស៊ីងអេង ជាគ្រូបង្រៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល ។

**ឆាយ សារះមុនិន្ទ**

# បោះជំហានទៅកាន់ទឹកដីនៃការផ្សះផ្សា និងអប់រំអន្លង់វែង

ជាផ្នែកមួយនៃការចងចាំ យុត្តិធម៌ និងការផ្សះផ្សា នៅថ្ងៃទី ៨-១១ ខែមីនា ឆ្នាំ២០១៦ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានដឹកនាំកម្មវិធីសន្តិភាពជាលើកទី២ របស់ខ្លួន ដោយមានការចូលរួមពីក្រុមនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសិស្សវិទ្យាល័យអន្លង់វែងបួននាក់ផ្សេងទៀត ទៅកាន់ទីតាំងចុងក្រោយខ្មែរក្រហមអន្លង់វែង ដើម្បីលើកកម្ពស់ការយល់ដឹងប្រវត្តិសាស្ត្រខ្មែរក្រហមកាន់តែប្រសើរ ។

ដើមឆ្នាំ១៩៧៩ បានបង្ហាញពីការដួលរលំនៃរបបខ្មែរក្រហម ដែលបណ្តាលឲ្យប្រជាជនកម្ពុជាជិត២លាននាក់ត្រូវបានស្លាប់បាត់បង់ជីវិត ។ ក្នុងអំឡុងពេលគួរឲ្យភ័យខ្លាចនេះ ប្រជាជនកម្ពុជាត្រូវដៅលក្ខណៈជាប្រព័ន្ធ ដោយហេតុផលមនោគមវិជ្ជា នយោបាយ និងជាតិសាសន៍ ។ អន្លង់វែងគឺទីតាំងចុងក្រោយ ដែលបានជួយសម្រួលដល់ការតស៊ូប្រឆាំងនឹងកងទ័ពវៀតណាម ។ អន្លង់វែងបានប្រែក្លាយខ្លួនទៅជាទីតាំងប្រវត្តិសាស្ត្រ ដែលបានបន្សល់ទុកភស្តុតាងប្រវត្តិសាស្ត្រជាច្រើនពីរបបខ្មែរក្រហម ។

គោលបំណងនៃដំណើរទស្សនកិច្ចសិក្សាសន្តិភាពនេះ ត្រូវបានដាក់បញ្ចូលធាតុផ្សំពាសំខាន់ៗ ដើម្បីបង្កើនគំនិតត្រិះរិះពិចារណា និងការយល់ដឹងពីអតីតកាល ជាពិសេសនៅទីបញ្ចប់នៃការតស៊ូចលនាខ្មែរក្រហម ទី១) សិស្ស-និស្សិត អាចស្វែងយល់ការពិតប្រវត្តិសាស្ត្រ តាមរយៈការធ្វើបទបង្ហាញរបស់អ្នកជំនាញនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីផ្សារភ្ជាប់ខ្លួនជាមួយបរិបទប្រវត្តិសាស្ត្រ និងស្វែងយល់បន្ថែមពីរឿងរ៉ាវជីវិតរបស់ជនរងគ្រោះរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ និងអតីតកងទ័ពខ្មែរក្រហម ។ ទី២) សិស្ស និស្សិត ផ្តោតសំខាន់ទៅលើការយល់ដឹងរបស់ខ្លួនពីទីតាំងប្រវត្តិសាស្ត្រ មានដូចជាៈ ផ្ទះតាម៉ុក កន្លែងបូជាសពប៉ុល ពត រួមទាំងទីតាំងប្រវត្តិសាស្ត្រផ្សេងទៀត ។ ទី៣) សិស្ស-និស្សិត ក៏មានឱកាសទទួលបាន



សិស្ស-និស្សិត ស្តាប់ការធ្វើបទបង្ហាញពីក្រុមការងារគម្រោងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង ដែលរៀបចំឡើងនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលដើម្បីការអភិវឌ្ឍន៍ជានិរន្តរភាព ស្ថិតនៅភូមិអូរគគីកណ្តាល ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មុននឹងចេញទៅទស្សនកិច្ចទីតាំងប្រវត្តិសាស្ត្រក្នុងស្រុកអន្លង់វែងផ្ទាល់

បទពិសោធន៍ពីការតាំងពិព័រណ៍ស្តីពីការជម្លៀសដោយបង្ខំនៅក្នុងរបបខ្មែរក្រហមដែរ ។

ជាមួយគោលបំណងជាក់លាក់ក្នុងការលើកកម្ពស់ចំណេះដឹងប្រវត្តិសាស្ត្ររបស់កម្មវិធីសន្តិភាពអន្លង់វែង សិស្ស-និស្សិតត្រូវចំណាយពេលទាំងនៅក្នុងថ្នាក់ និងនៅទីតាំងប្រវត្តិសាស្ត្រដោយធ្វើការសិក្សាមិនត្រឹមតែទ្រឹស្តីប៉ុណ្ណោះទេ ប៉ុន្តែក៏សិក្សាពីទិដ្ឋភាពជាក់ស្តែងនៃទីតាំងនីមួយៗ ដើម្បីធ្វើឲ្យការយល់ដឹងរបស់ខ្លួនពីប្រវត្តិសាស្ត្រខ្មែរក្រហមកាន់តែទូលំទូលាយ ។

តាមរយៈការយល់ដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីការនិទានប្រាប់ពីឪពុកម្តាយ ជីដូនជីតា និងក្រុមគ្រួសារ រួមទាំងការសិក្សាស្រាវជ្រាវតាមឯកសារប្រវត្តិសាស្ត្រនានានៅសាលា សិស្សនិស្សិត អាចទទួលបានចំណេះដឹងពីប្រវត្តិសាស្ត្រនេះមុនរួចទៅហើយ ប៉ុន្តែនៅតែមានការប៉ះពាល់ផ្លូវចិត្តពីការសម្លាប់រង្គាលទៅលើប្រជាជនកម្ពុជា ។ ដូច្នេះហើយ កម្មវិធីសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏អនុញ្ញាតឲ្យសិស្ស-និស្សិតបង្ហាញពីទំនាក់ទំនងអន្តរជំនាន់រវាងប្រជាជនអន្លង់វែង រួមបញ្ចូលទាំងអតីតទាហានខ្មែរក្រហម និងយុវជន ។ បន្ទាប់ពីកិច្ចពិភាក្សាលើទិដ្ឋភាពប្រវត្តិសាស្ត្រទូទៅ និងការជួបសំណេះសំណាលដោយផ្ទាល់ជាមួយអ្នករស់រានមានជីវិត និងអតីតទាហានខ្មែរក្រហម សិស្ស-និស្សិត ផ្លាស់ប្តូរទស្សនៈរបស់ខ្លួនពីមុន មិនត្រឹមតែប្រជាជនកម្ពុជា ប៉ុន្តែខ្មែរក្រហមខ្លួនឯងសុទ្ធតែជាជនរងគ្រោះនៅក្នុងរបបនេះ ។ គំនិតនេះបានផ្លាស់ប្តូរការយល់ឃើញរបស់សិស្ស-និស្សិតពីមុនមកថា ខ្មែរក្រហមទាំងអស់សុទ្ធតែឃោរឃៅ ។

ដើម្បីសិក្សាស្វែងយល់បន្ថែមទៅលើជ្រុងសំខាន់ផ្សេងទៀតនៃប្រវត្តិសាស្ត្រ កម្មវិធីសន្តិភាពអន្លង់វែង បានដឹកនាំសិស្ស-និស្សិតចុះទៅទីតាំងខ្មែរក្រហម និងធ្វើការសិក្សាទៅទិដ្ឋភាពផ្សេងនៅទីតាំងប្រវត្តិសាស្ត្រទាំងនោះផ្ទាល់ ដោយមានការពន្យល់បង្ហាញពីអ្នកមគ្គុទេសក៍អន្លង់វែង ។ ដូច្នេះហើយ សិស្ស-និស្សិតអាចបង្កើនចំណេះដឹងរបស់ខ្លួនតាមរយៈការបន្សល់ទុកភស្តុតាងប្រវត្តិសាស្ត្រ និងអនុវត្តតាមទ្រឹស្តីនៅក្នុងកិច្ចពិភាក្សាក្នុងថ្នាក់ ។ បន្ថែមពីលើនេះទៀត សិស្ស-និស្សិត ក៏ត្រូវបានផ្តល់ឱកាសទទួលបទពិសោធន៍តាមរយៈការតាំងពិព័រណ៍ស្តីពីការជម្លៀសដោយបង្ខំនៅក្នុងរបបខ្មែរក្រហមនៅវត្តថ្មី ដែលបង្ហាញពីទិដ្ឋភាពប្រវត្តិសាស្ត្រមួយផ្នែកទៀត ឆ្លុះបញ្ចាំងពីការតស៊ូទុកលំបាករបស់ប្រជាជនជម្លៀសនៅពេលនោះ ។ ជាការពិតនេះគឺជាឱកាសមានតែមួយគត់ សម្រាប់សិស្ស-និស្សិតយកអ្វីដែលខ្លួនទទួលបាននៅក្នុងថ្នាក់ និងនៅទីតាំងប្រវត្តិសាស្ត្រទៅប្រើប្រាស់ក្នុងការស្វែងយល់ជាក់ស្តែងនៅក្នុងការតាំងពិព័រណ៍ ។

កម្មវិធីដំណើរសន្តិភាពអន្លង់វែង ជួយលើកកម្ពស់ឲ្យមានការយល់ដឹងត្រិះរិះពិចារណាពីអតីតកាល ជាពិសេសប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈឲ្យសិស្ស-និស្សិតធ្វើការសិក្សាស្វែងយល់ដោយយកព្រឹត្តិការណ៍ពីអតីតកាលធ្វើជាបទពិសោធន៍ដើម្បីការពារកុំឲ្យអំពើឃោរឃៅកើតឡើងម្តងទៀត ។ ការយល់ដឹងប្រវត្តិសាស្ត្ររបស់ខ្លួនដោយត្រិះរិះពិចារណា ជាគន្លឹះសម្រាប់បើកទំព័រប្រវត្តិសាស្ត្រថ្មីនៃសន្តិភាព យុត្តិធម៌ ការផ្សះផ្សា និងការអភិវឌ្ឍនៅតំបន់អន្លង់វែង និងទូទាំងប្រទេសកម្ពុជា ។ **ស៊ាង ចិន្តា**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# ពូខ្ញុំស្លាប់ដោយសារតែមកលេងស្រុក


ញ៉ែម សុថុល

បើ យោងតាម សម្តីរបស់ ញ៉ែម សុថុល សព្វថ្ងៃអាយុ៥៩ឆ្នាំ ដែលត្រូវជាក្មួយស្រី ជនរងគ្រោះឈ្មោះ នុត កប ហៅ គាត បានរៀបរាប់ថា ពូរបស់គាត់ (កប) ជាកម្មាភិបាលជាន់ខ្ពស់ នៅក្នុងសម័យខ្មែរក្រហម ធ្វើការងារនៅក្នុងក្រសួងឧស្សាហកម្ម ។ ពូរបស់គាត់មានឪពុក ឈ្មោះ ប៊ុង នុត ម្តាយឈ្មោះ ឌិក ចាត និងមានបងប្អូនទាំងអស់៧នាក់ មានស្រុកកំណើតនៅភូមិកោក ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

កាលពីតូច ពូរបស់គាត់រៀននៅសាលាបឋមសិក្សាក្រោក រហូតដល់ចប់ថ្នាក់ ទើបឪពុកម្តាយបញ្ជូនឲ្យមករៀននៅភ្នំពេញ ដោយស្នាក់នៅជាមួយព្រះសង្ឃនៅវត្តកោះ ។ ពូរបស់គាត់រៀនបានត្រឹមថ្នាក់ឌីប្លូម ក៏បានបួសរៀនភាសាបាលី ភាសាអង់គ្លេស និងភាសាបារាំង ។ ក្រោយមក ពូរបស់គាត់បានលាចាកសិក្ខាបទ រួចបានដាក់ពាក្យចូលធ្វើការជាអ្នករត់សំបុត្រនៅស្ថានទូតអាមេរិកក្នុងក្រុងភ្នំពេញ ។ នៅឆ្នាំ១៩៥៦ ពូរបស់គាត់បានរៀបការប្រពន្ធឈ្មោះ លុយ ដួង ហៅ កាន់ រស់នៅក្នុងសង្កាត់ផ្សារដេប៉ូ ទីក្រុងភ្នំពេញ ។

នៅទសវត្សរ៍៦០ មានបាតុកម្មទាមទារឲ្យស្ថានទូតអាមេរិកដកចេញពីប្រទេសកម្ពុជា ចាប់តាំងពីពេលនោះមកមានចលនាស្នេហាជាតិ និងបក្សជាច្រើន បានកើតឡើងទូទាំងប្រទេសកម្ពុជា ។ នៅពេលនោះ ពូរបស់គាត់បានឈប់ពីការងារ ដោយសារតែស្ថានទូតអាមេរិកដកចេញ និងផ្អាកបេសកកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ។ នៅពេលនោះ ពូរបស់គាត់ក៏មកប្រកបរបរចិញ្ចឹមជ្រូក និងលក់ដូរគ្រឿងទេសជាមួយប្រពន្ធ នៅផ្សារដេប៉ូវិញ ។ នៅឆ្នាំ១៩៧០ ក៏កើតមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ បណ្តាលឲ្យមានការរំដើបរំជួល និងមានបាតុកម្មតបតចំពោះការទម្លាក់នេះ រហូតបណ្តាលឲ្យមានអំពើហិង្សាកើតឡើង ។

នៅឆ្នាំ១៩៧២ ពូរបស់គាត់បានចាកចេញពីប្រពន្ធកូន ដើម្បីចូលរួមចលនារំដោះជាតិនៅក្នុងព្រៃ តាមការអំពាវនាវរបស់សម្តេចព្រះនរោត្តម សីហនុ ។ ពូរបស់គាត់បានធ្វើដំណើរដល់ខេត្តកំពង់ស្ពឺ ស្ថិតនៅក្នុងតំបន់៣៣ ភូមិភាគបស្ចិម ។ ពេលនោះ ដោយសារពូរបស់គាត់រៀនបានជ្រៅជ្រះ និងមានចំណេះដឹង ទើបអង្គការចាត់តាំងឲ្យទទួលខុសត្រូវខាងសេដ្ឋកិច្ច ដោយរកស្បៀងផ្គត់ផ្គង់ដល់យោធា ។ បន្ទាប់មក អង្គការក៏ដំឡើងតួនាទីពូរបស់គាត់ជាប្រធានសេដ្ឋកិច្ចយោធានៅក្នុងកងវរសេនាតូចលេខ១៥៨ទៀត ។ ពូរបស់គាត់បានខិតខំតស៊ូ ធ្វើការងារដោយមិនគិតពីការនឿយហត់ និងខ្វាយខ្វល់ពីប្រពន្ធកូនឡើយ ។

នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ អង្គការបានជម្លៀសប្រពន្ធកូនពូរបស់គាត់ឲ្យត្រឡប់ទៅរស់នៅស្រុកកំណើតនៅភូមិក្រោកវិញ ។ បន្ទាប់ពីបានទទួលដំណឹងនេះ ពូរបស់គាត់បាន ទៅយកប្រពន្ធកូនឲ្យមករស់នៅភ្នំពេញវិញ ។

នៅឆ្នាំ១៩៧៦ ពូរបស់គាត់បានធ្វើការងារនៅក្នុងក្រសួងឧស្សាហកម្ម ដោយមានតួនាទីជាប្រធានឃ្លាំង ចំណែកប្រពន្ធរបស់គាត់ អង្គការចាត់តាំងឲ្យមើលថែកុមារតូចៗ នៅក្នុងក្រសួងឧស្សាហកម្មដែរ ។ នៅឆ្នាំ១៩៧៦-៧៧ ពូរបស់គាត់ និងអង្គរក្សបួននាក់ ស្លៀកពាក់ខោអាវខ្មៅ ពាក់មួកកន្ទីបបង់កក្រមាក្រហម ព្រមទាំងមានកាំភ្លើងគ្រប់ដៃ បានជិះរថយន្តម៉ាកហ្ស៊ីបមកលេងស្រុកកំណើត ។ ពូរបស់គាត់បានជួបឪពុកម្តាយ និងបងប្អូន ហើយបានចែកស្បៀងអាហារមួយចំនួនឲ្យប្រជាជននៅក្នុងសហករណ៍ ព្រមទាំងបាននិយាយលេងសើចទៀតផង ។ ពូរបស់គាត់បាននិយាយថា មិនចង់ឃើញប្រជាជននៅភូមិកំណើតមានជីវភាពខ្វះ

ខាត គ្មានអាហារហូប និងធ្វើការងារជាទម្ងន់ទេ ។ នៅពេលបានមកលេងស្រុកកំណើតម្តងៗ ពូរបស់គាត់តែងតែណែនាំបងប្អូនឲ្យខិតខំធ្វើការងារ និងហាមប្រឆាំងជាមួយអង្គការ ដោយលើកឡើងថា "សម័យនេះ ជាសម័យសង្គ្រាមគ្រាប់អង្ករ បើសង្គ្រាមគ្រាប់ផ្លោង យើងអាចមានត្រង់សេសម្រាប់លាក់ខ្លួនបាន" ។ ពូរបស់គាត់មិនបានទៅលេងស្រុកកំណើតដូចកាលពីពេលមុនទេ ក្រោយពីត្រឡប់មកធ្វើការនៅភ្នំពេញវិញ ។ នៅឆ្នាំ១៩៧៨ ដោយនឹកកូន (ពូរបស់គាត់) ខ្លាំងពេក តារបស់គាត់ក៏សុំច្បាប់ប្រធានឃុំឈ្មោះ ឡេង ឲ្យសរសេរសំបុត្រអនុញ្ញាតឲ្យគាត់ (តា) មកលេងកូននៅភ្នំពេញ ។ ពេលមកជួបពូ និងសម្រាកបានមួយយប់ ពូរបស់គាត់ក៏ឲ្យឪពុក (តារបស់គាត់) ត្រឡប់មកស្រុកកំណើតវិញ ព្រោះសភាពការណ៍មិនល្អ ។ ចាប់តាំងពីនោះមក បាត់ដំណឹងពូ និងប្រពន្ធកូនរបស់គាត់រហូតមក ។


ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

១- ឈ្មោះដើម ... ឈ្មោះវិវ ...
២- អាយុ ... ឆ្នាំ ភេទ ... ជនជាតិ ...
៣- ក្រសួងនិងមុខងារចាប់ពីថ្ងៃចូលប.ខ.រហូតដល់បច្ចុប្បន្ន
៤- កើតនៅភូមិ ... ឃុំ ... ស្រុក ... តំបន់ ...
៥- ឪពុកឈ្មោះ ... ម្តាយឈ្មោះ ...
៦- របបទុកឪពុកម្តាយពីមុនមក ...
៧- ប្តី ឬ ប្រពន្ធ ឈ្មោះដើម ... ឈ្មោះវិវ ...
៨- កើតនៅភូមិ ... ឃុំ ... ស្រុក ... តំបន់ ...
៩- ក្រសួង-នាទី នឹងកន្លែងរស់នៅបច្ចុប្បន្ន ...
១០- មានកូនប្រុសចំនួន ... នាក់ កូនស្រី ... នាក់ ...
១១- ទីកន្លែងឃាត់ខ្លួន ...
១២- ឃាត់ខ្លួន ថ្ងៃទី ២១ ខែ ១១ ឆ្នាំ ១៩៧៨ ។ ផ្ទះ ៣១ បន្ទប់ធំ ១ ...
ភិនភាគ
----
កំពស់ :
ប្រវែងជុំខ្លួន :

ចំណែក សុថុល ដែលមានឪពុកឈ្មោះ តែម ម្តាយឈ្មោះ ឡា បានមករស់នៅភ្នំពេញ តាំងពីសម័យសង្គមរាស្ត្រនិយម ដោយឪពុករបស់គាត់ជាមន្ត្រីនៅក្នុងក្រសួងឧស្សាហកម្ម ជាមួយលោក គាត ឈុន និង ជៀវ ស៊ីនលាន ។ សុថុល កើតនៅភ្នំពេញ ហើយពេលធំដឹងក្តី បានចូលរៀននៅសាលាបឋមសិក្សាសន្ធរម៉ុក ។

នៅឆ្នាំ១៩៧០ ពេលលោកសេនាប្រមុខ លន់ នល់ បានឡើងកាន់អំណាច សុថុល រៀននៅថ្នាក់ទី៣ "ចាស់" នៃវិទ្យាល័យឥន្ទ្រទេវី ។ រហូតដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានទទួលជ័យជម្នះ និងប្រាប់ឲ្យប្រជាជនចេញពីផ្ទះភ្លាមៗ តែក៏មានគ្រួសារខ្លះ ដែលមិនទាន់ជួបជុំសមាជិកក៏បន្តស្នាក់នៅមួយរយៈ (ពីរទៅបីថ្ងៃ) ទៀតដែរ ។ គ្រួសាររបស់ សុថុល បានចេញពីភ្នំពេញនៅថ្ងៃទី១៩ មេសា ឆ្នាំ១៩៧៥ ដោយយោធាខ្មែរក្រហមបង្ខំឲ្យចេញទាំងយប់ ទៅស្រុកកំណើតវិញ ដោយគ្រួសារគាត់មិនបានយកអ្វីមកច្រើនតាមខ្លួនទេ ព្រោះអង្គការប្រកាសថាឲ្យចេញតែរយៈពេលបីថ្ងៃប៉ុណ្ណោះ ។ តាមពិតគ្មានប្រជាជនណាម្នាក់បានចូលមករស់នៅផ្ទះសម្បែងនៅភ្នំពេញវិញទេ លើកលែងតែកម្មាភិបាលយោធាខ្មែរក្រហម និងកម្មករដែលធ្វើការងារនៅរោងចក្រ ។

នៅពេលមកដល់ស្រុកកំណើតវិញ សុថុល មានអាយុ១៨ឆ្នាំប៉ុណ្ណោះ ។ មិនយូរប៉ុន្មាន អង្គការបានបំបែក សុថុល ចេញពីឪពុកម្តាយ និងបងប្អូនឲ្យទៅធ្វើការងារនៅក្នុងអង្គភាពកងចល័តស្រុក ៥២ រយៈពេលពីរបីខែទើបអនុញ្ញាតឲ្យមកជួបឪពុកម្តាយម្តងៗ ។ សុថុល មិនដែលហ៊ានមកជួបឪពុកម្តាយទេ បើសិនជាអង្គការមិនអនុញ្ញាត ។ នៅក្នុងសម័យខ្មែរក្រហម យុវជន និងយុវនារីមិនអាចនិយាយលេងសើចជាមួយគ្នាបានទេ ព្រោះខ្លាចខុសសីលធម៌អង្គការ ។ អ្នកដែលប្រព្រឹត្តខុស អង្គការនឹងហៅយកទៅកសាង ហើយខ្លះទៀតមានទោសរហូតដល់ស្លាប់ទៀតផង ជាពិសេសយុវជន ។ អង្គការបានសាងសង់រោងយុវជនឲ្យនៅ

ឆ្ងាយពីយុវនារីដែលមានចម្ងាយជាង១០០ម៉ែត្រពីគ្នា ។ ការងាររបស់ សុថុល ពេលនោះគឺត្រូវក្រោកឡើងនៅម៉ោង៣ទៀបភ្លឺ ទៅស្ទូងដកសំណាប ច្រូតស្រូវ ជីកប្រឡាយ និងលើកទំនប់រហូត ដល់យប់ជ្រៅទើបឈប់ ដោយទទួលបានរបបបាយនៅខែច្រូត និងរបបបបរនៅខែស្ទូង ។ ប្រធានកងចល័តមួយចំនួនបានស្តីបន្ទោសសមាជិកកងរាល់ថ្ងៃ ហើយពេលខ្លះក៏មានបាត់សមាជិកនៅក្នុងកងដែរ ។

នៅឆ្នាំ១៩៧៦ អង្គការបានជម្លៀសប្រជាជននៅក្នុងភូមិមួយចំនួនឲ្យទៅរស់នៅខេត្តផ្សេងៗ ដូចជា ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។ ប្រធានឃុំបានជ្រើសរើសយកគ្រួសារមួយណាដែលមិនសូវខិតខំធ្វើការ និងហ៊ានតវ៉ាប្រឆាំងជាមួយនឹងអង្គការ ។ គ្រួសារ សុថុល មានសំណាងព្រោះអង្គការមិនបាន ជម្លៀសចេញពីភូមិ ។ នៅឆ្នាំ១៩៧៧ ប្រធានកងចល័តបានបញ្ជូន សុថុល ឲ្យទៅជីកព្រែកនៅព្រៃក្មេង ក្នុងខេត្តកំពង់ស្ពឺ ។ នៅទីនោះ សុថុល បានឃើញអង្គការរៀបការឲ្យយុវជន យុវនារីដែលមានចាប់ពី ២០ទៅ៣០គូ ដោយមានតែប្រធានកងជាគណៈអធិបតី និងគ្មានអាចារ្យ និងព្រះសង្ឃទេ ។

នៅឆ្នាំ១៩៧៩ សុថុន បានត្រឡប់មកជួបជុំឪពុកម្តាយបងប្អូនវិញ និងបានរៀបការប្តីឈ្មោះ ឈឹម ផា មានកូនចំនួន៤នាក់ (ប្រុស១-ស្រី៣) ហើយសព្វថ្ងៃ គាត់ជាគ្រូបង្រៀននៅសាលាបឋម សិក្សាទ្រនំជ្រើង ។

**សុខ ខណ្ណៈ**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បង់ទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើបសហរដ្ឋអាមេរិកចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស បែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនា រៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង អ៊ួច មករា តាមរយៈទូរស័ព្ទលេខៈ ០១៧ ៦៦៥ ៦៧៥ ។ អ៊ីម៉ែល : *truthmakara@dccam.org*

គេហទំព័រ : *www.ariverchangescourse.com*







# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី ៖ អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

*(តពីលេខមុន)*

## *សវនាការភេរវកម្ម*

*ជាងប្រាំមួយខែក្រោយពីការចាប់ខ្លួនជនសង្ស័យទាំងបួននាក់ សវនាការត្រូវបានកំណត់នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៤ ។ ចៅក្រមពីតុលាការក្រុងភ្នំពេញបាននិយាយថា មូលហេតុដែលនាំឲ្យមានការពន្យារពេលគឺបណ្ដាលមកពីគ្មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ជនសង្ស័យ ។ ចៅក្រមបាននិយាយថា គាត់បានធ្វើសំណើសុំទៅរដ្ឋាភិបាល និងស្ថានទូតអាមេរិកដើម្បីផ្ដល់នូវភ័ស្តុតាងបន្ថែម ។ តាមការពិត សវនាការបានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៤ ។ ប៉ុន្តែសវនាការនេះបានបិទទៅវិញ ដោយគ្មានការការពិភាក្សាណាមួយច្បាស់លាស់ ។ មេធាវីរបស់ជនជាប់ចោទ កៅ សុភា (Kao Sophea) បានដើរចេញពីបន្ទប់សវនាការ ដោយសារ ចៅក្រមបដិសេធមិនព្រមអានមាត្រាច្បាប់ដែលកូនក្ដីរបស់គាត់ត្រូវបានចោទប្រកាន់ ។ សុភា និយាយថា កូនក្ដីរបស់គាត់ត្រូវបានចោទប្រកាន់ពីបទភេរវកម្មអន្តរជាតិ ប៉ុន្តែមាត្រាច្បាប់ដែលកូនក្ដីគាត់ត្រូវបានចោទប្រកាន់ គឺមាត្រា២នៃច្បាប់ដែលបានចែងឆ្នាំ ១៩៩២ ស្ដីអំពីអំពើភេរវកម្មពាក់ព័ន្ធទៅនឹងការចាប់ជម្រិត និងឃុំខ្លួនខុសច្បាប់ ។ នៅពេលនោះ សារព័ត៌មានចាប់ផ្ដើមធ្វើការរិះគន់ដំណើរការកាត់ក្ដីដែលខ្វះភ័ស្តុតាងគ្រប់គ្រាន់ និងភ័ន្តច្រឡំដំណើរការនីតិវិធី ។ អង្គការសិទ្ធិមនុស្សក្នុងស្រុកបានធ្វើការតវ៉ាថា ជនសង្ស័យមិនបានទទួលការកាត់ក្ដីដោយយុត្តិធម៌ ។ បុរសជាប់សង្ស័យទាំងនោះបានជាប់ក្នុងមន្ទីរឃុំឃាំងដោយមិនបានទទួលការកាត់ក្ដីក្នុងសវនាការក្នុងរយៈពេល ៨ខែ ។*

*តុលាការក្រុងភ្នំពេញបានធ្វើការបើកសវនាការមួយទៀត*



ប្រជាជននៅក្នុងសហគមន៍ចាម ក្នុងខេត្តកំពត ចូលរួមវេទិកាសាធារណៈស្ដីពីការអប់រំពីអំពើប្រល័យពូជសាសន៍

នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៤ ។ ពេលនោះ ចៅក្រមបានប្រកាសសេចក្តីសម្រេចដោះលែងជាបន្ទាន់គ្រូជនជាតិអេហ្ស៊ីបឈ្មោះ មូហាម៉ាត់ ខាឌៀ អាលី (Mohammad Khadir Ali) ប៉ុន្តែកាត់ទោសគ្រូជនជាតិថៃពីរនាក់ និងជនជាតិខ្មែរម្នាក់ឲ្យជាប់ឃុំឃាំងអស់មួយជីវិត ។ គ្រូទាំងបីនាក់ឈ្មោះ អាប់ឌុល អាហ្ស៊ី ហាជ្ជី ជីមីង (Abdul Azi Haji Chiming) មូហាម៉ាត់ យ៉ាឡាលូឌិន ម៉ាឌីង (Mohammad Yalaludin Mading) និង ស្មាន់ អ៊ីស្មាអែល (Sman Ismael) ។ ប្រតិកម្មពីសហគមន៍ចាមរួមមាន ការអស់ជំនឿ ភ្ញាក់ផ្អើល និងភាពអយុត្តិធម៌ ទោះបីជា សហគមន៍គាត់បង្ហាញអាកប្បកិរិយាក្នុងលក្ខណៈមិនបើកចំហ និងគួរសមក៏ដោយ ។ ពេជ សូលីន ដែលធ្លាប់ជានាយកកម្មវិធីអប់រំបែបវិទ្យាសាស្ត្រ នៅអតីតសាលារៀន អុំអាល់គូរ៉ា បាននិយាយថា "សេចក្តីសម្រេចនេះ គឺពិតជាត្រឹមត្រូវណាស់ ការដោះលែងជនជាតិអេហ្ស៊ីប ប៉ុន្តែនៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់ទេ ពីព្រោះអ្នកគ្មានកំហុសនៅស្ថិតនៅក្នុងមន្ទីរឃុំឃាំងនៅឡើយ ។ តុលាការគួរធ្វើការស៊ើបអង្កេតឲ្យបានច្បាស់លាស់ ។ ប្រសិនបើតុលាការធ្វើការអង្កេតឲ្យបានច្បាស់លាស់នោះ អ្នកទាំងអស់នោះច្បាស់ជាគ្មានកំហុសនោះទេ ។ ជនជាតិមូស្លីមជាច្រើននៅក្នុងសហគមន៍ខ្ញុំមិនពេញចិត្តនឹងដីកាសម្រេច និងរបៀបកាត់ក្តីនោះទេ ។ គេជឿថាសវនាការនេះនៅខ្វះភស្តុតាងគ្រប់គ្រាន់" ។ មេធាវីការពារក្តីជនជាប់ចោទ កៅ សុភា បានរៀបរាប់ថា ដីកាសម្រេចនេះគឺមិនអាចទទួលយកបានទេ ហើយគាត់គ្រោងនឹងជួយកូនក្តីគាត់ប្តឹងឧទ្ធរណ៍ ដែល សុភា បានធ្វើនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ ។

បួនឆ្នាំក្រោយមក នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨ តុលាការឧទ្ធរណ៍បានបើកសវនាការដែលសម្រេចកាត់ទោស ស្មាន់ អ៊ីស្មាអែល អាប់ឌុល អាហ្ស៊ី ហាជ្ជី ឈីមីង និង មូហាម៉ាត់ យ៉ាឡាលូឌីន ម៉ាឌីង ឲ្យជាប់ឃុំឃាំងអស់មួយជីវិត ។ អង្គចៅក្រមដែលមានសមាជិក៥នាក់ បានសម្រេចថាអ្នកទាំងបីបានជួយ ហាំបាលី ក្នុងការរៀបចំការវាយប្រហារទៅលើស្ថានទូតអង់គ្លេស និងការិយាល័យយូណេស្កូនៅភ្នំពេញ ។ ទោះជាយ៉ាងនេះក៏ដោយ មេធាវីការពារក្តីយល់ថាសេចក្តីសម្រេចនេះ "មិនអាចទទួលយកបាន" ផ្អែកទៅលើមូលហេតុពីរសំខាន់ ។ ទីមួយ តុលាការនេះមិនបានស្តាប់សក្ខីកម្មសាក្សី ដើម្បីបង្ហាញថា ជនជាប់ចោទទាំងបីពិតជាឃុបឃិតនឹង ហាំបាលី ឬក្រុមជ្រុលនិយមអន្តរជាតិ ។ ទីពីរ មេធាវីការពារក្តីបាននិយាយថា តុលាការនេះប្រើប្រាស់តែក្រដាសមួយសន្លឹកដែលបានមកពីស្ថានទូតអាមេរិកដើម្បីបញ្ជាក់ថាជនជាប់ចោទមានកំហុស ។ ក្រុមសិទ្ធិមនុស្សនៅប្រទេសថៃ បានធ្វើការរិះគន់លើដំណើរការនីតិវិធីរបស់តុលាការដែលមិនបានបើកចំហជាសាធារណៈ និងចោទប្រកាន់ថាការដាក់ទោសនេះថាផ្អែកទៅលើតែភស្តុតាងដែលផ្តល់ដោយសហរដ្ឋអាមេរិកប៉ុណ្ណោះ ។

ប្រពន្ធរបស់ជនជាប់ចោទជនជាតិថៃទាំងពីរនាក់ បានតាមដានសំណុំរឿងនេះអស់រយៈពេល៥ឆ្នាំ ។ ក្រោយពីតុលាការកំពូលចេញដីកាសម្រេចមក អ្នកទាំងពីរគ្រោងស្នើសុំទៅរដ្ឋាភិបាលកម្ពុជាធ្វើការអនុញ្ញាត ឲ្យប្តីរបស់ខ្លួនអាចទៅទទួលទោសនៅប្រទេសថៃវិញ ដែលនៅទីនោះខ្លួនអាចសុំការលើកលែងទោសពីព្រះមហាក្សត្រ ។

អ្នកទាំងពីរ បានផ្ញើពាក្យទទួចអង្វរទៅស្ថានទូតអាមេរិកនៅទីក្រុងបាងកក អ្នកអង្គម្ចាស់ក្សត្រីថៃ សុរិន្ទថន (Sirindhorn) និងអភិបាលរង គ្រីសាដា (Grisada) ។ ពាក្យទទួចអង្វរនេះត្រូវបានទទួលយក ។ នៅដើមឆ្នាំ២០០៩ រដ្ឋមន្ត្រីក្រសួងការបរទេសថៃ កាសិត បានធ្វើសំណើសុំទៅរាជរដ្ឋាភិបាលកម្ពុជា និងព្រះមហាក្សត្រដើម្បីពិចារណាលើការអភ័យទោសដល់ជនជាតិថៃទាំងពីរ ។ នៅខែកក្កដា ឆ្នាំ២០០៩ ជនជាតិថៃទាំងពីរត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសថៃវិញដោយស្ងៀមស្ងាត់ ។ ការដោះលែងនេះជាផ្នែកមួយនៃការយល់ព្រមធ្វើការដោះដូរអ្នកទោសរវាងប្រទេសកម្ពុជា និងប្រទេសថៃ ។ ជនជាតិថៃទាំងពីរនាក់ត្រូវបានឃាត់ទុកធ្វើការសួរចម្លើយរយៈពេលពីរសប្តាហ៍នៅទីក្រុងបាងកក និងខេត្តយ៉ាឡា ប្រទេសថៃ មុនពេលដោះលែងឲ្យទៅជួបក្រុមគ្រួសារវិញ ។ អាជ្ញាធរថៃគ្មានមូលដ្ឋានគ្រប់គ្រាន់ក្នុងការចោទប្រកាន់អ្នកទាំងពីរពីបទល្មើសដែលប្រព្រឹត្តនៅប្រទេសថៃ ។ អ្នកអង្គម្ចាស់ សុរិន្ទថន បានធ្វើអន្តរាគមន៍ដោះលែងអ្នកទាំងពីរដែរ ។ បុរសទាំងពីរសព្វថ្ងៃ បង្រៀននៅសាលារៀនសាសនាអ៊ីស្លាមឯកជនមួយដែលខ្លួនធ្លាប់បម្រើការមុនពេលទៅបង្រៀននៅប្រទេសកម្ពុជា ។

ចំពោះ ស្មាន់ អ៊ីស្មាអែល អនាគតរបស់គាត់មានសភាពអាប់អួរ ។ ក្រៅពីទទួលការអាណិតអាសូរពីសំណាក់ជនជាតិចាម និងក្រុមសារព័ត៌មានគ្មានសកម្មភាពណាមួយធ្វើឡើងដើម្បីជួយឲ្យ

គាត់មានសេរីភាពពីមន្ទីរឃុំឃាំង ។ អ្នកផ្តល់ព័ត៌មានម្នាក់របស់អ្នកនិពន្ធ ដែលជាសមាជិកក្រុមសាឡាហ្វី បានសារភាពថា ស្មាន់ អ៊ីស្មាអែល ពិតជាបានជួបជាមួយ ហាំបាលី នៅកម្ពុជាមែន ហើយជួយគាត់ ហាំបាលី តាមវិធីផ្សេងៗ ដែលក្នុងនោះរួមមានការជួយផ្តល់ និងរកទីជម្រករយៈពេលខ្លីដល់ ហាំបាលី និងជួយឧបត្ថម្ភជាសម្ភារផ្សេងៗ ។ អ្នកផ្តល់ព័ត៌មាននោះបានអះអាងថា ចំណុចសំខាន់នោះគឺថា ស្មាន់ អ៊ីស្មាអែល ដែលជាគ្រូបង្រៀនរបស់គាត់នៅចោមចៅមិនបានដឹងថា អ្នកដែលគាត់បានជួយនោះគឺជា ហាំបាលី ដែលជាសមាជិកថ្នាក់ខ្ពស់នៃក្រុម ចេម៉ាស អ៊ីស្លាមីយ៉ះ (Jemaah Islamiyah) និងជាអ្នកទទួលខុសត្រូវក្នុងការផ្ទុះគ្រាប់បែកនៅកោះបាលីនោះទេ ។ ចាប់តាំងពីជនជាតិថៃពីរនាក់ដែលបានជាប់ចោទពីបទល្មើសដូចគ្នានៅកម្ពុជាមានសេរីភាពនៅប្រទេសថៃមក ស្មាន់ អ៊ីស្មាអែល គួរតែត្រូវបានបានដោះលែងដូចគ្នាដែរ នៅប្រទេសកម្ពុជា ។

ក្រុមភេរវកម្មទាំងមូលបានបង្កើតនូវរូបភាពមិនល្អនៅក្នុងសហរដ្ឋអាមេរិក ជាពិសេសក្នុងចំណោមជនជាតិចាម ។ សារព័ត៌មានបានចោទប្រកាន់សហរដ្ឋអាមេរិកថាមានភាពមិនស្មោះត្រង់នៅក្នុងករណីនេះ ។ សហរដ្ឋអាមេរិកកំពុងតែបំពេញកិច្ចការមួយចំនួននៅប្រទេសកម្ពុជាដើម្បីកសាងនូវការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋដែលជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ ។ ផ្ទុយទៅវិញ ពេលដែលខ្លួនត្រូវដោះស្រាយបញ្ហាប្រឆាំងនឹងអំពើភេរវកម្ម ជាពិសេសចំពោះករណីសវនាការនៃជនសង្ស័យទាំងបីរូប សហរដ្ឋអាមេរិកបែរជាព្រងើយកន្តើយនឹងការអនុវត្តនូវនីតិរដ្ឋទៅវិញ ។ ភស្តុតាងដែលគាំទ្រសំណុំរឿងនោះមានលក្ខណៈមិនគ្រប់គ្រាន់ រីឯនីតិវិធីវិញ មានភាពមិនប្រក្រតី ។

**ចំណងអាពាហ៍ពិពាហ៍**

មានប្រភពព័ត៌មានខ្លះបានរាយការណ៍ថា ហាំបាលី និងសមាជិកក្រុមរបស់ខ្លួនប្រើប្រាស់វិធីសាស្ត្រម្យ៉ាងដើម្បីបង្កើនទំនុកចិត្ត និងការគាំទ្រពីមូស្លីមក្នុងស្រុក វិធីសាស្ត្រនោះគឺការរៀបអាពាហ៍ពិពាហ៍ ។ ស្មាន់ អ៊ីស្មាអែល ចំណាយពេលបីឆ្នាំដើម្បីសិក្សាសាសនាអ៊ីស្លាមនៅសាលាសាសនាអ៊ីស្លាមនៅប្រទេសថៃភាគខាងត្បូង កន្លែងដែលគាត់ជួបជាមួយអ៊ីប្រាហ៊ីម (Ibrahim) ដែលរបាយការណ៍ភ្នាក់ងារសម្ងាត់បានចោទប្រកាន់ថា ជាអ្នកប្រតិបត្តិការរួមជាមួយ ហាំបាលី ក្នុងពេលដែលគាត់ស្នាក់នៅប្រទេសកម្ពុជា ។ ពេលអ៊ីប្រាហ៊ីមធ្វើដំណើរទៅប្រទេសកម្ពុជា ស្មាន់ អ៊ីស្មាអែល បានណែនាំគាត់ទៅកាន់ប្អូនស្រីរបស់ខ្លួនឈ្មោះ ស្មាន់ ខាត ទី យ៉ះ (Sman Khat Ti Yah)ដែលរស់នៅខេត្តកំពត ។ ដោយមានផ្តល់ប្រាក់កាសបន្តិចបន្តួច គ្រួសាររបស់ស្មាន់ អ៊ីស្មាអែល បានយល់ព្រមរៀបការ ស្មាន់ ខាត់ទី យ៉ះ ទៅអ៊ីប្រាហ៊ីម ដែលគ្រួសារនោះដឹងត្រឹមថា អ៊ីប្រាហ៊ីមគឺជាមិត្តភក្តិរបស់ ស្មាន់ អ៊ីស្មាអែល ។ ការរៀបការកូនស្រីទៅបុរសជនជាតិបរទេសគឺជារឿងធម្មតានៅពេលនោះ ។ ជនជាតិខ្មែរ ចិន និងចាម សុទ្ធតែបានរៀបការកូនស្រីទៅបុរសជនជាតិកម្ពុជាដែលធ្លាប់ទៅរស់នៅបរទេសជាច្រើនឆ្នាំ ដែលអ្នកស្រុកហៅថា អាណិកជនរួមមានទាំងជនជាតិបរទេសមកប្រទេសខាងលិច ជនជាតិកូរ៉េ និងជនជាតិដទៃទៀត ។ ជារឿយៗ គ្រួសាររបស់កូនក្រមុំដឹងពីប្រវត្តិរបស់បុរសទាំងអស់នោះតិចតួចណាស់ ។ ក្នុងករណីភាគច្រើនបុរសទាំងនោះធ្វើល្អទៅលើកូនក្រមុំ ។

ចំពោះគ្រួសារក្រីក្រ និងមានចំណេះវិជ្ជាទាបដូចជា គ្រួសាររបស់ ស្មាន់ ខាត់ទី យ៉ះ អ៊ីប្រាហ៊ីម បុរសដែលមានទ្រព្យសម្បត្តិគួរសមមានចំណេះដឹង និងសម្បុរបែបដែលជាជម្រើសគួរឲ្យទាក់ទាញចំពោះកូនស្រីរបស់ខ្លួន ។ ស្មាន់ ខាត់ទី យ៉ះ និយាយថា «ខ្ញុំមិនដឹងរឿងអ្វីអំពីគាត់ទេ ប្រហែលជាខ្ញុំមិនចង់បានគាត់តទៅទៀតទេ» ។ ខាត់ ទី យ៉ះ និយាយថា អ៊ីប្រាហ៊ីម ចេញទៅបាត់នៅចុងឆ្នាំ២ ០ ០២ ។ ប៉ូលីសនិយាយថា «គ្រួសារនេះលង់ខ្លាំងណាស់ គាត់មិនដឹងពីប្រវត្តិផ្ទាល់ខ្លួនរបស់កូនកំលោះ ។ គ្រួសារក្រីក្រច្រើនតែជាប់នឹងផ្លាក់ទឹកប្រាក់បន្តិចបន្តួច» ។ ប៉ុន្តែប៉ូលីសជឿជាក់ថា ស្មាន់ អ៊ីស្មាអែល ស្ថិតនៅក្នុងប្រទេសកម្ពុជាជាមួយ ហាំបាលី អ៊ីប្រាហ៊ីម និងសមាជិកម្នាក់ទៀតឈ្មោះ ហ្សែត ដើម្បីរៀបចំគម្រោងការវាយប្រហារនេះ ហេតុនេះ អ៊ីស្មាអែល គួរតែដឹងថាការរៀបការនេះមានន័យដូចម្តេច ។ ប្រសិនបើ ស្មាន់ អ៊ីស្មាអែល គឺជាជនជាតិមូស្លីមកម្ពុជាទីមួយ ដែលត្រូវបានបញ្ចុះបញ្ចូលឲ្យចូលរួមក្នុងក្រុមចាម៉ាស អ៊ីស្លាមីយ៉ះ វិធីសាស្ត្ររបស់ក្រុមនេះក្នុងការទាក់ទាញ អ៊ីស្មាអែល មានលក្ខណៈខ្លាំងពូកែគឺថា ផ្តល់ជាការគាំទ្រ និងបង្រៀនគាត់នៅពេលគាត់កំពុងស្ថិតនៅក្នុងដំណាក់កាលទន់ខ្សោយ នឹកផ្ទះពេលកំពុងរៀននៅបរទេស និងតាមរយៈការបង្កើតនូវចំណងអាពាហ៍ពិពាហ៍មួយដ៏រឹងមាំ ។

តើអ្វីទៅដែលជំរុញ ស្មាន់ អ៊ីស្មាអែល ឲ្យធ្វើដូច្នេះ? តាមសេចក្តីរាយការណ៍ខ្លះបានឲ្យដឹងថា ក្រុមចាម៉ាស អ៊ីស្លាមីយ៉ះ មានគម្រោងបង្កើតនូវការិយាល័យអ៊ីស្លាមមួយនៅអាស៊ីអាគ្នេយ៍ ដែលមានវិសាលភាពពីប្រទេសម៉ាឡេស៊ី ទៅប្រទេសឥណ្ឌូនេស៊ី ថៃ សិង្ហបុរី វៀតណាមខាងត្បូង ទីម័រខាងកើត ហ្វីលីពីន និងកម្ពុជា ។ តើស្មាន់ អ៊ីស្មាអែល ប្រាថ្នាចង់បង្កើតការិយាល័យនេះដែរឬទេ? គ្មានភ័ស្តុតាងណាមួយដែលបញ្ជាក់យ៉ាងដូច្នេះទេ បើទោះបីជា ស្មាន់ អ៊ីស្មាអែល ត្រូវបានកាត់ទោសរួចហើយក៏ដោយ ។

របាយការណ៍របស់ International Crisis Group ខែសីហា ឆ្នាំ២០០៣ ដែលមានចំណងជើងថា "ចេម៉ាស អ៊ីស្លាមីយ៉ះ នៅអាស៊ីអាគ្នេយ៍ៈ បែកបាក់តែនៅតែគ្រោះថ្នាក់" បានអះអាងថាក្រុមចេម៉ាស អ៊ីស្លាមីយ៉ះ បានប្រើប្រាស់សាលារៀន និងការរៀបការជាយុទ្ធសាស្ត្រដើម្បីជ្រើសរើស សមាជិកថ្មី និងដើម្បីរក្សាភក្តីភាពនៅក្នុងក្រុម ។ របាយការណ៍នោះបានបញ្ជាក់ថា "បណ្តាញ ចេម៉ាស អ៊ីស្លាមីយ៉ះ បានរួមបញ្ចូលគ្នាមិនត្រឹមតែជាមនោគមន៍វិជ្ជា និងការបណ្តុះបណ្តាលប៉ុណ្ណោះទេ តែថែមទាំងដោយសារបណ្តាញអាពាហ៍ពិពាហ៍យ៉ាងស្មុគស្មាញថែមទៀតដែលពេលខ្លះធ្វើឲ្យមើលទៅដូចជាគ្រួសារដ៏ធំសម្បើមមួយ" ។ របាយការណ៍នោះបានបន្ថែមទៀតថា "ក្នុងករណីជាច្រើន មេដឹកនាំជាន់ខ្ពស់ ចេម៉ាស អ៊ីស្លាមីយ៉ះ បានរៀបចំអាពាហ៍ពិពាហ៍អ្នកនៅក្រោមបង្គាប់ឲ្យប្អូនស្រីឬប្អូនស្រីថ្លៃរបស់ខ្លួនដើម្បីរក្សាបណ្តាញនេះឲ្យមានស្ថិរភាព" ។ នៅក្នុងករណីនេះ ដោយរៀបការជាមួយ ស្មាន់ ខាត់ទីយ៉ះ អ៊ីប្រាហ៊ីម អាចស្នាក់នៅប្រទេសកម្ពុជាបានយូរ និងទទួលបាននូវលិខិតឆ្លងដែនកម្ពុជាស្របច្បាប់ ឬក្លែងក្លាយមួយដែលអាចបន្ថយការចាប់អារម្មណ៍មកលើខ្លួនជាជាងពេលដែលខ្លួនប្រើប្រាស់លិខិតឆ្លងដែនមកពីប្រទេសមូស្លីមនៅក្នុងអំឡុងពេលក្រោយព្រឹត្តិការណ៍កោះបាលី ។

ទោះបីជាយ៉ាងនេះក៏ដោយ គ្រួសារ ស្មាន់ អ៊ីស្មាអែល នៅតែបន្តបដិសេធថា អ៊ីស្មាអែល ចូលរួម និងជួយសកម្មភាពរបស់ក្រុមចេម៉ាស អ៊ីស្លាមីយ៉ះ នៅកម្ពុជាដោយអចេតនា ។ ស្មាន់ អ៊ីស្មាអែល គឺជាសិស្សខ្សោះខ្សាយព្យាយាម ។ គាត់រៀនចប់ថ្នាក់ទី៩ នៅខេត្តកំពតមុនពេលមកភ្នំពេញដើម្បីបន្តការសិក្សា ។ ក្រោយមកគាត់ទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសថៃខាងត្បូងនៅសាលាសាសនាអ៊ីស្លាម រយៈពេល៣ឆ្នាំ មុនពេលត្រឡប់មកប្រទេសកម្ពុជាវិញ ធ្វើជាគ្រូបង្រៀនសាសនាអ៊ីស្លាម នៅមណ្ឌលកុមារកំព្រាចោមចៅ ។ របាយការណ៍ខ្លះបានអះអាងថា អ៊ីស្មាអែល ជាសមាជិករបស់ ក្រុមចេម៉ាស អ៊ីស្លាមីយ៉ះ ប៉ុន្តែមណ្ឌលកុមារកំព្រាចោមចៅត្រូវបានបង្កើតឡើងដោយ RIHS របស់ប្រទេសគុយវ៉ែត ដែលជាស្ថាប័នសាឡាហ្វី ។ សង្ឃឹមថាការអប់រំនឹងជួយបង្កើនជីវភាពរស់នៅរបស់គ្រួសារ គ្រួសាររបស់ អ៊ីស្មាអែល ព្យាយាមរកប្រាក់ដើម្បីឧបត្ថម្ភការសិក្សានៅប្រទេសថៃខាងត្បូង ។ ស្មាន់ ខាត់ទីយ៉ះ និយាយថា "ម្តាយខ្ញុំឲ្យគាត់ទៅរៀននៅទីនោះ ហើយលក់គោក្នុងមួយឆ្នាំមួយ ដើម្បីផ្ញើប្រាក់ទៅគាត់ ។ ញាតិជិតខាងក៏ជួយគាត់ដែរ ។ យើងចង់ឲ្យគាត់រៀនឲ្យបានពូកែ ។ ម្តាយខ្ញុំនៅជំពាក់បំណុលគេ នៅឡើយ ដើម្បីផ្ញើលុយទៅឲ្យគាត់រៀន ។ បំណុលនោះនៅមិនទាន់សងគេអស់នៅឡើយ ។ ម្តាយខ្ញុំ និងយាយខ្ញុំយំរៀងរាល់ថ្ងៃ" ។ ទោះបីជា ខាត់ ទី យ៉ះ ក្លាយទៅជាស្ត្រីមេម៉ាយដោយសារតែបងប្រុសគាត់ឲ្យគាត់រៀបការនឹង អ៊ីប្រាហ៊ីម ក៏ដោយ ក៏គាត់មិនខឹងនឹងបងប្រុសគាត់ទេ ។ ខាត់ទីយ៉ះ រៀបរាប់ថា "ខ្ញុំអាចនិយាយបានថា ការចាប់ខ្លួនគាត់គឺជារឿងខុសទាំងស្រុង ។ យើងមិនជឿថាគាត់ធ្វើអ្វីដូចដែលពាក្យគេនិយាយនោះទេ ។ ការចោទប្រកាន់នេះគឺមិនគួរឲ្យជឿទាល់តែសោះ" ។

## ៤) ទំនាក់ទំនងជាមួយប្រទេសថៃខាងត្បូងៈ ជាជីវពលអ៊ីស្លាម ឬអ្នករងកំហុសជំនួសអ្នកដទៃ?

ជនជាតិចាមមិនត្រឹមតែត្រូវបានភ្ជាប់ទៅនឹងក្រុមភេរវកម្មអ៊ីស្លាម នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០ប៉ុណ្ណោះទេ ជនជាតិចាមថែមទាំងត្រូវបានភ្ជាប់ទៅនឹងក្រុមជីវពលអ៊ីស្លាមនៅប្រទេសថៃភាគខាងត្បូង ដែលបានចាប់ផ្តើមពង្រឹងខ្លួនកាន់តែរឹងមាំនៅដើមឆ្នាំ២០០៤ ។ នៅបីបួនឆ្នាំមុន មានការកើនឡើងការបញ្ជូនកម្មករពីប្រទេសកម្ពុជាទៅប្រទេសនានានៅតំបន់អាស៊ីអាគ្នេយ៍ នៅអាស៊ីចុងបូព៌ា និងមជ្ឈិមបូព៌ាគួរឲ្យកត់សម្គាល់ ។ ពីខែតុលា ឆ្នាំ២០០៩ ដល់ខែតុលា ឆ្នាំ២០១០ មានកម្មករចំនួន ១២២.៧៣១នាក់ទៅធ្វើការនៅបួនប្រទេសៈ ៩៤.៥៦៤នាក់នៅប្រទេសថៃ១៩.៥៨៨ នៅប្រទេសម៉ាឡេស៊ី៩.០៨២នាក់នៅប្រទេសកូរ៉េ និង៩៧នាក់នៅប្រទេសជប៉ុន ។ យោងតាមក្រសួងការងារ ជាមធ្យម កម្មករគ្មាន

ជំនាញអាចរកប្រាក់ចំណូលបានពីចន្លោះ២៥០ ទៅ៣០០ដុល្លារក្នុងមួយខែ នៅប្រទេសថៃ៦០០ដុល្លារ នៅប្រទេសកូរ៉េខាងត្បូង និង៩០០ដុល្លារនៅប្រទេសជប៉ុន ។ ជនជាតិចាមជាច្រើនបានចូលរួមនៅក្នុងលំហូរនៃការងារនេះ ។ ជនជាតិមូស្លីមចូលចិត្តទៅធ្វើការនៅប្រទេសថៃខាងត្បូង និងម៉ាឡេស៊ីជាងទៅប្រទេសកូរ៉េឬជប៉ុន ទោះជាប្រទេសថៃ និងម៉ាឡេស៊ីផ្តល់ប្រាក់កម្រៃតិចជាងក៏ដោយ ។ គោលដៅសំខាន់នៅក្នុងប្រទេសថៃគឺ ខេត្តផាតានី យ៉ាឡា និងណារ៉ាធីវ៉ាត់ ដែលមានទីតាំងជាប់នឹងរដ្ឋខេឡាន់តាន់ ប្រទេសម៉ាឡេស៊ី ដែលជាគោលដៅរបស់ចាមម៉ាឡេទៅធ្វើការ និងសិក្សា ។ ទោះជាយ៉ាងនេះក៏ដោយ នៅឆ្នាំ១៩៩៩ មានជនជាតិចាមប្រមាណ១ម៉ឺននាក់ត្រូវបានបញ្ជូនត្រឡប់មកប្រទេសកម្ពុជាពីប្រទេសម៉ាឡេស៊ីវិញ ។ ខេត្តជាប់ព្រំដែនទាំងបីគឺផាតានី យ៉ាឡា និងណារ៉ាធីវ៉ាត់ ត្រូវបានកាត់បញ្ចូលមកជាខេត្តនៅក្នុងទឹកដីសៀមនៅឆ្នាំ១៩០៩ ។ តំបន់នេះមានទំហំប្រហាក់ប្រហែលនឹងអតីត ស៊ុលតង់ម៉ាឡេ នៃផាតានី ។ ទោះបីជាប្រទេសថៃខិតខំប្រឹងប្រែងបញ្ជ្រាបឥទ្ធិពលព្រះពុទ្ធសាសនាចូលទៅក្នុងតំបន់នេះយ៉ាងណាក៏ដោយ ក៏តំបន់នេះនៅតែគ្របដណ្តប់ដោយជនជាតិម៉ាឡេមូស្លីមដែលមានចំនួនប្រជាជន រហូតដល់ទៅ៨០ភាគរយ ។ គោលនយោបាយប្រឋាច់បញ្ចូលគ្នារបស់បាងកកមានឥទ្ធិពលតិចតួចណាស់ ទៅលើវប្បធម៌ ប្រវត្តិសាស្ត្រ និងសាសនានៅក្នុងតំបន់ ។ ហេតុនេះ ប្រទេសថៃមិនដែលទទួលបានជោគជ័យក្នុងការបញ្ចូលតំបន់នេះទៅក្នុងរដ្ឋ និងសង្គមថៃ ។ ចាប់តាំងពីកាត់បញ្ចូលតំបន់នេះចូលទៅក្នុងរាជាណាចក្រសៀមនៅដើមសតវត្សរ៍ទី២០មក តំបន់នេះជួបប្រទះនូវការតស៊ូរើបម្រះ និងជម្លោះជាបន្តបន្ទាប់ ។ ព្រឹត្តិការណ៍សំខាន់ពីរដែលគួរឲ្យកត់សម្គាល់នោះគឺ ហេតុការណ៍ឌុស៊ុនយរ ឌុសុនយៀរ (ថ្ងៃ២៦-២៨ ខែមេសា ឆ្នាំ១៩៤៨) ដែលជនជាតិមូស្លីមជាច្រើនរយនាក់បានត្រូវសម្លាប់នៅខេត្តណារ៉ាធីវ៉ាត់ និងការចាប់ខ្លួនសមាជិកអ៊ីស្លាមលេចធ្លោម្នាក់គឺ ហាជី ស៊ូឡុង Haji Sulong ដោយប៉ូលីសថៃ ។ ហាជី ស៊ូឡុង បាត់ខ្លួនរហូត ។

ក្រុមតស៊ូជាច្រើនបានលេចឡើងនៅទសវត្សរ៍ឆ្នាំ១៩៦០ ក្នុងនោះរួមមាន អង្គការរណសិរ្សរួបរួម ផាតានី (PULO) និងពារិសាន Revolusi Nasional (BRN) ។ ក្រុមជីវពលអ៊ីស្លាមប្រាថ្នាចង់បង្កើត "រដ្ឋអ៊ីស្លាមផាតានី" ។ នៅទសវត្សរ៍ឆ្នាំ១៩៨០ និង១៩៩០ ជម្លោះបានថមថយចុះទៅវិញ ដោយសារតែគោលនយោបាយចូលរួមដ៏ជោគជ័យរបស់នាយករដ្ឋមន្ត្រីថៃ ព្រឹម ទីនស៊ូឡាណុន (Prem Tinsulanond ១៩៨០ - ១៩៨៨) ។ លោកនាយករដ្ឋមន្ត្រីបានផ្តល់ការលើកលែងទោសទៅដល់ក្រុមជីវពលដែលជាប់ឃុំឃាំង រៀបចំទម្រង់រដ្ឋាភិបាលថ្មី និងផ្តល់ឯកសិទ្ធិនយោបាយទៅដល់ជនជាតិមូស្លីមម៉ាឡេ និងផ្តល់ជំនួយអភិវឌ្ឍន៍នៅក្នុងតំបន់ ។ គាត់ក៏បានចាត់ចែងឲ្យមន្ត្រីម្នាក់មើលការខុសត្រូវផ្នែករដ្ឋបាលនៅតំបន់នេះ ដែលមានឈ្មោះជាផ្លូវការថា មជ្ឈមណ្ឌលរដ្ឋបាលខេត្តតាមបណ្តោយព្រំដែន (Southern Border Provinces Administrative Center SBPAC) ដោយផ្តល់នូវស្វ័យភាពខ្លះទៅកាន់តំបន់នេះ ។

ចាប់តាំងពីដើមឆ្នាំ២០០៤មក ស្ថានភាពនៅប្រទេសថៃខាងត្បូងមានសភាពកាន់តែទ្រុឌទ្រោមទៅ ។ ជម្លោះនេះបានសម្លាប់មនុស្សអស់ជាង៣០០០នាក់ទាំងសងខាង ដោយគ្មានសង្ឃឹមថានឹងបញ្ចប់នៅពេលអនាគត ។ មានមូលហេតុមួយចំនួនដែលអាចពន្យល់ពីការផ្ទុះឡើងនូវអំពើហិង្សានេះ ៖ ការជំរុញលើកទឹកចិត្តពីសំណាក់អ៊ីស្លាមអន្តរជាតិ និងសង្គ្រាមនៅអ៊ីរ៉ាក់ ភាពក្រីក្រ និងក្រោមការអភិវឌ្ឍគោលនយោបាយរដ្ឋាភិបាលចំពោះតំបន់ខាងត្បូងមានការផ្លាស់ប្តូរ ការធ្លាក់ចុះការគោរពសិទ្ធិមនុស្ស និងសង្គ្រាមប្រឆាំងគ្រឿងញៀន ។ រដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រី តាក់ស៊ីន ស៊ីណាវ៉ាត្រា (២០០១-២០០៥) បានប្រព្រឹត្តកំហុសសំខាន់ៗជាច្រើនទាក់ទងទៅនឹងនយោបាយនៅថៃខាងត្បូង ។ ថាក់ស៊ីន បានរំលាយចោលនូវការចាត់ចែងនយោបាយដែលរៀបចំដោយអតីតនាយករដ្ឋមន្ត្រី ព្រឹម ទីនស៊ូឡាណុន និងបានដាក់កម្លាំងប៉ូលីសការពារសន្តិសុខនៅតំបន់ខាងត្បូងដែលមិនទទួលបានការស្វាគមន៍ពីប្រជាជន ។ The International Crisis Group បានរាយការណ៍ថា "មូលហេតុសំខាន់ពីរគឺ ការបំបែកស្ថាប័នរដ្ឋាភិបាលសំខាន់ៗ និងការធ្លាក់ចុះការគោរពសិទ្ធិមនុស្សដែលនាំឲ្យប្រជាជនបាត់បង់ជំនឿទៅលើនីតិរដ្ឋ ។ ភាពភ័យខ្លាច និងការថ្នាំងថ្នាក់ចិត្ត ដែលបង្កើតឡើងដោយការចាប់ខ្លួន និងភាពសាហាវ ឃោរឃៅរបស់ប៉ូលីស គួបផ្សំនឹងភាពបរាជ័យរបស់រដ្ឋាភិបាលក្នុងការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ និងក្រុមគ្រួសារ ។ បញ្ហាទាំងអស់នេះបង្កឲ្យមានការមិនសប្បាយចិត្តដែល

ជំរុញឲ្យប្រជាជនចូលរួម និងគាំទ្រដល់ក្រុមតស៊ូប្រដាប់អាវុធ” ។

ទន្ទឹមនឹងបរាជ័យក្នុងការបង្ក្រាប និងដោះស្រាយជម្លោះនេះ មន្ត្រីរដ្ឋាភិបាលថៃមួយចំនួនមានបំណងធ្វើឲ្យជម្លោះនេះក្លាយជាបញ្ហាអន្តរជាតិ ដោយអះអាងថា ក្រុមមូស្លីមប្រដាប់អាវុធនៅក្រៅប្រទេសថៃ បានផ្តល់ជំនួយទៅដល់ក្រុមអ្នកតស៊ូតាមរយៈការផ្តល់ការបណ្តុះបណ្តាល គ្រឿងសព្វាវុធ និងគ្រាប់កាំភ្លើង ។ មានមូលហេតុពីរយ៉ាងដែលនាំឲ្យរដ្ឋាភិបាលថៃមានការសង្ស័យថាមានជាប់ពាក់ព័ន្ធនឹងក្រុមមូស្លីមអន្តរជាតិ នោះគឺភាពសម្បូរបែបនៃក្បួនយុទ្ធសាស្ត្រប្រយុទ្ធ និងគ្រាប់បែករបស់ក្រុមបះបោរ ។ នៅខែកក្កដា ឆ្នាំ២០០៥ មេបញ្ជាការទាហានចូលនិវត្តន៍ម្នាក់ឈ្មោះ គីទី រតនាឆាយា (Kitti Rattanachaya) បានអះអាងថា មានជនជាតិមូស្លីមឥណ្ឌូនេស៊ីយ៉ាងហោចណាស់ក៏៧នាក់ដែរ ដែលបានផ្តល់ជាការបណ្តុះបណ្តាលផ្នែកយោធាទៅក្រុមបះបោរមូស្លីមនៅតំបន់ខាងត្បូង ។ ក្រុមចេម៉ាស អ៊ីស្លាមីយ៉ះ ត្រូវបានរាប់បញ្ចូលថាមានជាប់ពាក់ព័ន្ធនឹងជម្លោះនៅប្រទេសថៃភាគខាងត្បូងដែរ ដោយសារតែមានការបង្ក្រាបក្រុមនេះនៅប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងសិង្ហបុរី ។ ចម្លើយសារភាពរបស់សមាជិកក្រុមជនជាតិសិង្ហបុរីម្នាក់ឈ្មោះ អារីហ៊្វីន ប៊ិន អាលី (Arifin bin Ali) ហៅ ចន វ៉ង អា ហ៊ុង (John Wong Ah Hung) បានឆ្លើយភ្ជាប់ជនជាតិថៃមូស្លីមបីនាក់ទៀតនៅខេត្តណារ៉ាធីវ៉ាត់ និងខេត្តយ៉ាឡា ។ បុរសពីរនាក់ត្រូវបានចាប់ខ្លួននៅឆ្នាំ២០០៣ ប៉ុន្តែដោយសារខ្វះភ័ស្តុតាងលើសពីចម្លើយសារភាពនោះ តុលាការព្រហ្មទណ្ឌបាងកកបានសម្រេចដោះលែងអ្នកទាំងបីនៅឆ្នាំ២០០៥ ។ ក្រុមប្រដាប់អាវុធមកពីអាស៊ីភាគខាងត្បូងត្រូវបានជឿជាក់ថាមានការជាប់ពាក់ព័ន្ធក្នុងរឿងនេះដែរ ។

ចាប់តាំងពីឆ្នាំ២០០៤មក ជនជាតិចាមដែលធ្វើដំណើរទៅប្រទេសថៃភាគខាងត្បូងដើម្បីស្វែងរកការងារ ឬឆ្លងព្រំដែនថៃខាងត្បូងទៅប្រទេសម៉ាឡេស៊ីត្រូវបានចោទប្រកាន់ថាជួយ និងចូលរួមក្នុងក្រុមឧទ្ទាមថៃខាងត្បូង ។ នៅខែឧសភា ឆ្នាំ២០០៤ នៅពេលសិស្សជនជាតិចាម៥០នាក់បានចាកចេញពីសាលារៀនអ៊ីស្លាមនៅខេត្តជាតានី ហើយអាជ្ញាធរថៃមិនបានតាមដានក្រុមសិស្សនេះ ក្រុមនេះត្រូវបានសង្ស័យថា បានចូលរួមជាមួយក្រុមបះបោរក្នុងការវាយប្រហារទៅលើជំរំកងទ័ពនៅខេត្តណារ៉ាធីវ៉ាត់ ។ ប៉ូលីសថៃបានភ្ជាប់រឿងភ្លាមៗ ។ ក្នុងនោះប្រភពមួយបានឲ្យដឹងថា “ក្រុមមូស្លីមជ្រុលនិយមនៅភាគខាងត្បូងអាចនឹងមានទំនាក់ទំនងនឹងក្រុមភេរវកម្មអន្តរជាតិ ។ គ្រូបង្រៀនសាសនាខ្លះមកពីសាលារៀនប៉ុនដុក (Pondok) នៅក្នុងខេត្តតាមបណ្តោយព្រំដែនខាងត្បូងត្រូវបានចាប់ខ្លួនថ្មីៗនេះនៅប្រទេសកម្ពុជា ដោយក្រុមភ្នាក់ងារសម្ងាត់ខាងលិចដែលសង្ស័យក្រុមនេះថាអាចមានជាប់ពាក់ព័ន្ធនឹងក្រុមភេរវកម្មអាល់កៃដា” ។ ប៉ូលីសថៃសំដៅទៅលើការចាប់ខ្លួនជនសង្ស័យដែលជាសមាជិកក្រុម ចេម៉ាស អ៊ីស្លាមីយ៉ះ នៅប្រទេសកម្ពុជាឆ្នាំ២០០៣ ។ មកដល់ចំណុចនេះ ការចោទប្រកាន់ទៅលើជនជាតិចាមម្នាក់ថាជាប់ពាក់ព័ន្ធនឹងក្រុមភេរវកម្មអ៊ីស្លាមកើតឡើងជាបន្តបន្ទាប់ ។

ការសង្ស័យរបស់រដ្ឋាភិបាលថៃស្តីអំពីការជាប់ពាក់ព័ន្ធរបស់ក្រុមអ៊ីស្លាមអន្តរជាតិជាមួយជម្លោះនៅភាគខាងត្បូងត្រូវបានពង្រឹងកាន់តែខ្លាំងឡើងដោយរដ្ឋាភិបាលថៃបានបញ្ជាឲ្យវាយឆ្មក់ចូលសាលារៀន និងវិហារអ៊ីស្លាម ព្រមទាំងបិទទ្វារសាលារៀនអ៊ីស្លាមមួយចំនួនទៀតនៅខេត្តយ៉ាឡា និងជាតានី ។ សិស្សជនជាតិចាមជាច្រើនដែលបានសិក្សានៅសាលារៀនទាំងអស់នេះត្រូវបានបង្ខំឲ្យត្រឡប់ទៅផ្ទះវិញ ។ សិស្សដែលត្រឡប់មកផ្ទះវិញនិយាយថា អាជ្ញាធរថៃធ្វើឲ្យយើងពិបាកក្នុងការសុំទិដ្ឋាការត្រឡប់ទៅវិញ ឬទិដ្ឋាការសម្រាប់សិស្សថ្មីដែលទៅរៀននៅភាគខាងត្បូង ។ ស្ថានទូតថៃបានបដិសេធការអះអាងនេះ ។ នៅពេលកំពុងធ្វើការត្រួតពិនិត្យជនជាតិចាម១០០នាក់ដែលធ្វើដំណើរទៅភាគខាងត្បូងដើមខែឧសភា ឆ្នាំ២០០៤ កាសែតថៃ ដឺណេស្សិន (The Nation) បានសរសេរថាសមាជិកអ៊ីស្លាមម្នាក់បានប្រាប់ជនជាតិចាមម្នាក់អំពីការបង្កើត“រដ្ឋអ៊ីស្លាមនៅជាតានី” ដែលជនជាតិមូស្លីមអាចរស់នៅ និងធ្វើការដោយសេរី ។ ដំណើរការត្រួតពិនិត្យដ៏តឹងរ៉ឹងត្រូវបានរៀបចំឡើងដើម្បីពិនិត្យជនជាតិចាមដែលឆ្លងព្រំដែនទៅប្រទេសថៃ ទោះជាអ្នកដំណើរទាំងនោះមានឯកសារធ្វើដំណើរត្រឹមត្រូវយ៉ាងណាក៏ដោយ ។ ការត្រួតពិនិត្យបែបនេះ ជាទូទៅរួមមានការថតរូបជនជាតិមូស្លីមក្រៅពីរូបថតដែលមានស្រាប់ ការថតចម្លងលិខិតឆ្លងដែន និងការសួរសំណួរលម្អិតអំពីការធ្វើដំណើរ ។ នៅក្នុងករណីខ្លះតម្រូវឲ្យមានការយកស្នាមម្រាមដៃ ។ អាម៉ាត់ យ៉ះយ៉ា (Ahmad Yahya) សារភាពថា “ជនជាតិចាមជាច្រើនធ្វើដំណើរឆ្លងព្រំដែនថៃ

ជារៀងរាល់ថៃទៅកាន់ថ្ងៃភាគខាងត្បូង និងប្រទេសម៉ាឡេស៊ី ។ ជនជាតិចាមទាំងអស់នោះ ទៅរៀន ទៅធ្វើការ ។ ខ្លះក៏ស្របច្បាប់ ខ្លះក៏មិនស្របច្បាប់ ។ ប៉ុន្តែមូស្លីមនៅកម្ពុជាមិនចូលរួមគាំទ្រក្រុមតស៊ូដើម្បីឯករាជ្យនោះទេ» ជនជាតិចាមខ្លះស្នាក់នៅហួសរយៈពេលកំណត់ក្នុងទិដ្ឋាការទេសចរណ៍ ទិដ្ឋាការការងារ និងទិដ្ឋាការនិស្សិតដែលពួកគេប្រើប្រាស់ដើម្បីចូលទៅក្នុងប្រទេសថៃ ។ ប៉ុន្តែយោងតាមអ្នកដែលស្គាល់ជនជាតិចាមដែលធ្វើដំណើរប្រទេសថៃ ជនជាតិចាមទាំងនោះស្នាក់នៅប្រទេសថៃដើម្បីតែរកការងារធ្វើប៉ុណ្ណោះ ។

នៅខែឧសភា ឆ្នាំ២០០៥ ប្រជាជនប្រមាណ៦០០នាក់បានស្លាប់នៅក្នុងព្រឹត្តការណ៍ចលាចលហិង្សានៅថៃភាគខាងត្បូង ។ អំឡុងពេលនោះ អាជ្ញាធរថៃនៅច្រកព្រំដែនប៉ោយប៉ែត បានរាយការណ៍ថា ជនជាតិចាមជាងមួយរយនាក់ក្នុងមួយថ្ងៃបានឆ្លងព្រំដែនចូលទៅក្នុងប្រទេសថៃចំនួន១០ដងច្រើនជាងចំនួនធម្មតា ។ អាជ្ញាធរបាននិយាយថា មូលហេតុដែលជនជាតិចាមធ្វើដំណើរចូលទៅគឺដើម្បីទៅសួរសុខទុក្ខបងប្អូន និងធ្វើដំណើរបន្តទៅប្រទេសម៉ាឡេស៊ីដើម្បីទៅសិក្សាសាសនា ។ មន្ត្រីថៃនិយាយថា «យើងខ្លាចថា ជនជាតិចាមមូស្លីមទាំងនេះអាចត្រូវបានលួងលោមដោយក្រុមបះបោរខាងត្បូងដើម្បីឲ្យចូលរួមក្នុងសកម្មភាពបះបោរ» ។

នៅខែកក្កដា ឆ្នាំ២០០៥ កាសែត ថៃរ៉ាត់ (Thai Rat) បានដកស្រង់ប្រភពភ្នាក់ងារសម្ងាត់ថៃថា «ជនជាតិចាមមូស្លីមត្រូវបានបញ្ជូនឲ្យទៅរស់នៅជាមួយក្រុមអ៊ីស្លាមនៅតាមតំបន់ព្រំដែនចន្លោះខេត្តជាតានី និងណារ៉ាធីវ៉ាត់ ។ ក្រុមដែលទទួលខុសត្រូវក្រុមចាមមូស្លីមមានជាប់ពាក់ព័ន្ធនឹងចលនាក្រុមបះបោរដែលធ្វើប្រតិបត្តិការនៅខេត្តតាមបណ្តោយព្រំដែនខាងត្បូងទាំងបី ។ ជនជាតិថៃកាន់ព្រះពុទ្ធសាសនាត្រូវបានបំពាន ហើយបង្ខំឲ្យចាកចេញពីភូមិ ។ តាមគម្រោង ក្រុមអ្នកឆ្លងដែនមូស្លីមមកពីប្រទេសកម្ពុជា ភូមា ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ត្រូវបានបញ្ជូនឲ្យទៅតាំងទីលំនៅនៅខេត្តជាតានីដើម្បីត្រៀមរៀបចំជារដ្ឋអ៊ីស្លាមនៅជាតានី នាពេលអនាគត» ។

នៅក្នុងខែតែមួយនោះ អាជ្ញាធរថៃបានបញ្ជូនក្តីសង្ស័យរបស់ខ្លួនឲ្យអាជ្ញាធរកម្ពុជាដឹងថាជនជាតិចាមអាចនឹងជាប់ពាក់ព័ន្ធនឹងចលនាក្រុមបំបែកខ្លួនថៃមូស្លីម ។

នៅខែវិច្ឆិកា ឆ្នាំ២០០៥ ជនជាតិចាមជិត៧០០នាក់បានឆ្លងព្រំដែនទៅកាន់ប្រទេសថៃ ។ ក្នុងចំណោមអ្នកទាំងអស់នោះ មានជនជាតិចាម៨៦នាក់ (៣៦នាក់ជាស្ត្រី) ត្រូវបានដាក់ឃុំឃាំងដោយមន្ត្រីទាហានថៃមកពីកងកម្លាំងកសាងសន្តិភាពខេត្តតាមបណ្តោយព្រំដែនខាងត្បូង (the Southern Border Provinces Peace building Command) បើទោះបីជាអ្នកទាំងអស់នោះមានឯកសារធ្វើដំណើរគ្រប់គ្រាន់យ៉ាងណាក៏ដោយ ។ មន្ត្រីព្រំដែនថៃបានអនុញ្ញាតឲ្យឆ្លងព្រំដែនហើយ ប៉ុន្តែយោធាបានឃុំឃាំងជនជាតិចាមទាំងនោះដោយនិយាយថា ក្រុមនោះផ្តល់ព័ត៌មានមិនច្បាស់លាស់ទាក់ទងនឹងមូលហេតុដែលធ្វើដំណើរទៅប្រទេសថៃ ។ វ៉ាន់ម៉ាត់ ប្រធានសមាគមអ៊ីស្លាមកម្ពុជាបានធ្វើអន្តរាគមន៍ថា «ខ្ញុំបានសុំឲ្យរដ្ឋាភិបាលថៃធ្វើការពិនិត្យឲ្យបានច្បាស់លាស់នៅក្នុងសំណុំរឿងនេះ ហើយប្រសិនបើថៃពិតជារកឃើញថាក្រុមជនជាតិចាមនេះមានជាប់ពាក់ព័ន្ធនឹងអំពើហិង្សានៅថៃខាងត្បូងមែននោះ សូមប្រើច្បាប់ដើម្បីដោះស្រាយទៅចុះ ។ ប្រសិនបើរកមិនឃើញថាជាប់ពាក់ព័ន្ធទេ សូមដោះលែងក្រុមនេះទៅ» ។ ក្រោយមកក្រុមនេះ ត្រូវបានដោះលែងហើយត្រូវបានតាមដានយ៉ាងជាប់លាប់តាមផ្លូវទៅកាន់ប្រទេសថៃខាងត្បូង ។ នាយកសាលាសាសនាអ៊ីស្លាមនៅខេត្តជាតានី បានពន្យល់ថា មានជនជាតិចាមមិនដល់១ពាន់នាក់ផងមកសិក្សានៅខេត្តទាំងបីនេះ ហើយពួកគេមកនេះ ក៏ព្រោះតែនៅប្រទេសកម្ពុជាមានសាលារៀនសាសនាអ៊ីស្លាមតិចតួច ហើយអ្នកចេះដឹងជនជាតិចាមជាច្រើនត្រូវបានសម្លាប់អស់នៅក្នុងរបបខ្មែរក្រហម ។ គាត់បន្ថែមថា ជនជាតិចាមមកសិក្សានៅប្រទេសថៃខាងត្បូងអស់រយៈពេលជាងមួយសតវត្សរ៍មកហើយ ។

នៅខែកញ្ញា ឆ្នាំ២០០៦ ជនជាតិចាម៨០នាក់ (ស្ត្រី៥១នាក់) ត្រូវបានចាប់ខ្លួននៅច្រកពិនិត្យអន្តោប្រវេសន៍នៅអារ៉ាញ់យ៉ាប្រាថេត (Aranyaprathet) ពីបទមានបំណងនាំចូលថ្នាំពេទ្យ និងសម្ភារដែលអាចធ្វើជាគ្រឿងផ្ទុះចូលទៅក្នុងប្រទេសថៃ ។ ថ្នាំពេទ្យដែលបានរកឃើញនោះភាគច្រើនជាថ្នាំផ្សះ ។ ចំណុចដែលគួរឲ្យកត់សម្គាល់នោះគឺថាប្រជាជនកម្ពុជា ទាំងមូស្លីម និងពុទ្ធសាសនិកតែងយកថ្នាំដាក់តាមខ្លួននៅពេលធ្វើដំណើរ ។ ក្រោយពីជួបប្រទះនូវសង្គ្រាមអស់ជាច្រើនឆ្នាំដែលបំផ្លាញនូវរចនាសម្ព័ន្ធ និងធ្វើឲ្យមានការខ្វះខាតនូវសម្ភារចាំបាច់ផ្សេងៗ ប្រជាជនកម្ពុជារៀនដាក់របស់របរតាមខ្លួនគ្រប់

គ្រាន់នៅពេលធ្វើដំណើរផ្លូវឆ្ងាយឆ្លងខេត្តរវាងភូមិដាច់ស្រយាល រួមទាំងធ្វើដំណើរទៅប្រទេសអភិវឌ្ឍន៍ផង ។ ទម្លាប់នេះអាចឲ្យយើងអាចយល់បានពីមូលហេតុដែលជនជាតិចាមដាក់ថ្នាំផ្សះតាមខ្លួនទៅប្រទេសថៃខាងត្បូង ដែលថ្នាំនេះនឹងត្រូវបានប្រើប្រាស់សម្រាប់ព្យាបាលជំងឺផ្ទាល់ខ្លួនពេលធ្វើការរយៈពេលយូរនៅទីនោះ ។ សម្ភារដែលសង្ស័យថានឹងប្រើប្រាស់ដើម្បីផលិតគ្រឿងផ្ទុះនោះគឺ នីត្រាតប៉ូតាស្យូម២គីឡូក្រាម ដែលអាចនឹងត្រូវបានប្រើប្រាស់ដើម្បីច្នៃធ្វើគ្រាប់បែក ប៉ុន្តែគ្រឿងផ្សំនេះក៏អាចនឹងប្រើលើត្រី និងសាច់ ដើម្បីរក្សាជាតិប្រូតេអ៊ីន ។ អាជ្ញាធរថៃបន្តឃ្លាំមើលចលនារបស់ជនជាតិចាមថាអាចនឹងចូលរួមធ្វើជាក្រុមប្រតិបត្តិការជាមួយក្រុមបះបោរអ៊ីស្លាម ដោយសារថាមនុស្សជាង១៧០០នាក់បានស្លាប់នៅក្នុងជម្លោះចាប់តាំងពីឆ្នាំ២០០៤មក ។

នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៧ ឧត្តមសេនីយ៍ វ៉ាតានាឆៃ ឆៃមួនវង់ (Watnachai Chaimuanwong) ទីប្រឹក្សាជាន់ខ្ពស់ផ្នែកសន្តិសុខរបស់នាយករដ្ឋមន្ត្រីថៃបានប្រាប់អ្នកសារព័ត៌មានថា “របាយការណ៍ភ្នាក់ងារសម្ងាត់បានចង្អុលបង្ហាញទៅអ្នកជំនាញពីក្រុមបះបោរប្រទេសឥណ្ឌូនេស៊ី និងកម្ពុជា នៅប្រទេសថៃខាងត្បូង ប៉ុន្តែរដ្ឋាភិបាលមិនអាចបញ្ជាក់ពីជនជាតិរបស់ក្រុមនោះបានដោយសារយើង នៅមិនទាន់មានភ័ស្តុតាងគ្រប់គ្រាន់នៅឡើយ” ។ អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម ខៀវ កញ្ញារីទ្ធិ បានបញ្ជាក់ថា ប្រទេសថៃកំពុងព្យាយាមស្វែងរកអ្នកមកទទួលកំហុសចំពោះអំពើហិង្សាដែលបានកើតឡើងនៅភាគខាងត្បូង ។ ទោះបីជាយ៉ាងណាក៏ដោយ មេបញ្ជាការកំពូលរបស់ប្រទេសថៃ ឧត្តមសេនីយ៍ ប៊ុនសង់នាមប្រាឌិត (Boonsang Niempradit) បាននិយាយថា អាជ្ញាធរថៃកំពុងតែធ្វើការស៊ើបអង្កេតក្នុងសំណុំរឿងនេះ ។ គាត់និយាយថា “ចំពោះជនជាតិចាមមូស្លីមដែលចូលទៅក្នុងប្រទេសថៃ យើងកំពុងតែធ្វើការពិនិត្យមើលថាតើក្រុមនេះមកប្រទេសថៃធ្វើអ្វី ។ ពេលខ្លះយើងឆ្ងល់ថាហេតុអ្វីទើបចំនួនប្រជាជន ដែលចេញ និងចូលប្រទេសមានចំនួនមិនស្មើគ្នា” ។ ទោះបីជាយ៉ាងនេះក៏ដោយ ឧត្តមសេនីយ៍ វ៉ាតានាឆៃ បានអះអាងយ៉ាងច្បាស់លាស់ជាងមុន ។ អ្នកសារព័ត៌មានបានដកស្រង់សម្តីគាត់ថា “ទោះបីជា ខ្ញុំមិនដឹងថាក្រុមនេះស្ថិតនៅកន្លែងណា ខ្ញុំអាចនិយាយបានថា ប្រជាជនកម្ពុជាដែលមានជាប់ខ្សែពាក់ព័ន្ធនឹងក្រុម ចេម៉ាស អ៊ីស្លាមីយ៉ះ កំពុងស្ថិតនៅភាគខាងត្បូងប្រទេសថៃ” ។ ការភ័យខ្លាចរបស់គាត់អំពីទំនាក់ទំនងរបស់ក្រុម ចេម៉ាស អ៊ីស្លាមីយ៉ះ ជាមួយជនជាតិចាម ផ្អែកទៅលើរបាយការណ៍មួយដែលនិយាយថា ហាំបាលី ស្ថិតនៅប្រទេសកម្ពុជាមុនពេលត្រូវបានចាប់ខ្លួននៅប្រទេសថៃ ហើយជនសង្ស័យបីនាក់ទៀតកំពុងស្ថិតនៅក្នុងមន្ទីរឃុំឃាំងនៅកម្ពុជា ។

នៅឆ្នាំ២០០៥ ជនជាតិចាម៨៤៨៨នាក់ បានចូលមកប្រទេសថៃតាមរយៈច្រកព្រំដែនប៉ោយប៉ែត ខណៈពេលដែលមានតែ៥៨៦នាក់ប៉ុណ្ណោះដែលត្រឡប់ទៅវិញ ។ នៅឆ្នាំ២០០៦ ជនជាតិចាមចូលប្រទេសថៃមាន៧២៧០នាក់ ប៉ុន្តែមានតែ៦៩៨នាក់ប៉ុណ្ណោះដែលត្រឡប់ទៅវិញ ។ នៅពាក់កណ្តាលទីមួយឆ្នាំ២០០៧ ជនជាតិចាមចូលប្រទេសថៃមាន២៧៩០នាក់ ហើយមានតែ២៦៦នាក់ប៉ុណ្ណោះ ដែលត្រឡប់មកវិញ ។ ឧត្តមសេនីយ៍ វ៉ាតានាឆៃ ត្រូវបានដកស្រង់សម្តីថា ជនជាតិចាមមួយចំនួនបានចូលរួមក្នុងក្រុមបះបោរ GMIP ។

សេចក្តីអធិប្បាយរបស់ឧត្តមសេនីយ៍ វ៉ាតានាឆៃ ធ្វើឲ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បដិសេធទាំងខឹងសម្បារថា ដោយសារតែប្រទេសថៃបរាជ័យក្នុងការនាំយកនូវសន្តិភាពទៅកាន់ថៃភាគខាងត្បូង ថៃចាប់ផ្តើមបន្ទោសទៅលើជនជាតិមូស្លីមអន្តរជាតិ ។ ទាក់ទងទៅនឹងទំនាក់ទំនងទៅថ្ងៃអនាគតរវាងកម្ពុជា និងថៃចំពោះបញ្ហានេះ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានកំណត់បីចំណុច ៖

◆ កម្ពុជាគោរពឯករាជ្យ និងអធិបតេយ្យភាពរបស់ប្រទេសថៃ

◆ កម្ពុជាសូមធ្វើការអំពាវនាវទៅរដ្ឋាភិបាលថៃ ឬថ្នាក់ដឹកនាំយោធារបស់ថៃឲ្យឈប់យករឿងរ៉ាវផ្ទៃក្នុងរបស់ប្រទេសថៃឲ្យពាក់ព័ន្ធនឹងមូស្លីមអន្តរជាតិ ដោយបន្ទោសទៅលើអ្នកដទៃ ដូចជាចាមមូស្លីមមកពីប្រទេសកម្ពុជាជាដើម ។

◆ កម្ពុជាត្រៀមខ្លួនចរចាជាមួយប្រទេសថៃនៅរាល់លំដាប់ថ្នាក់ទាំងអស់រួមទាំងថ្នាក់នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ដើម្បីដោះស្រាយបញ្ហាភេរវកម្ម ។ ***(តទៅលេខក្រោយ)***

**អេង កុកថាយ**

# អាថិកំបាំងរបស់ ប៉ុល ពត

**(តពីលេខមុន)**

ប៉ុន្តែ គាត់នៅមានតំណែងជាអគ្គលេខាបក្សដដែល ដូចនេះ គាត់នៅតែជាអគ្គបញ្ជាការកងទ័ពព្រៃ ដែលមានកម្លាំងពី៣ ទៅ ៤ ម៉ឺននាក់ សម្រាប់វាយប្រយុទ្ធទល់នឹងពួកវៀតណាមនៅកម្ពុជា ។ ក្រោយពីលែងកាន់តំណែងជានាយករដ្ឋមន្ត្រីមក គេមិនសូវបានដឹងឮថា ប៉ុល ពត ធ្វើអ្វីខ្លះ ឬស្ថិតនៅទីណាប្រាកដទេ ។ តាមសេចក្តីរាយការណ៍ខ្លះថា គាត់ធ្លាប់ទៅព្យាបាលជំងឺសរសៃឈាមបេះដូងនៅក្រុងប៉េកាំង ក្នុងអំឡុង ឆ្នាំ១៩៨១-១៩៨៣ ។ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៨៥ វិទ្យុលួចលាក់របស់ខ្មែរក្រហម បានប្រកាសឲ្យដឹង ថា ប៉ុល ពត បានចូលនិវត្តពីតំណែងអគ្គបញ្ជាការនៃ «កងទ័ពជាតិ» នៃកម្ពុជាប្រជាធិបតេយ្យហើយ ហើយបានត្រូវតែងតាំងជានាយក «វិជ្ជាស្ថានជាន់ខ្ពស់ការពារជាតិវិញ» ។

ប៉ុល ពត ដែលមានសក់ល្បាយអាចម៍ខ្លាទៅហើយនោះ បានរៀបការម្តងទៀតជាមួយយុវកសិករស្រីម្នាក់ និងបានកូនពីរ ។ ប៉ុន្តែ គាត់មិនដែលបោះបង់ការប្រយុទ្ធប្រឆាំងនឹងចក្រពត្តិនិយម និងគំនិតងាកចេញពីមាគ៌ារបស់បក្សគាត់ឡើយ ។ ប៉ុល ពត នៅតែជឿថា របបរបស់គាត់ «បានប្រគល់សិទ្ធិអំណាចយ៉ាងពេញលេញដល់ប្រជាជនកម្ពុជា ជាលើកដំបូងបំផុតតាំងពី២០០០ឆ្នាំមកហើយ បើទុកជាបានប្រព្រឹត្តខុសក្នុងការធ្វើឲ្យប្រជាជនខ្លួនស្លាប់អស់រាប់រយពាន់នាក់ក៏ដោយ» ។

តើមេដឹកនាំរូបនេះ មានយល់ថា អំណើះតទៅ គាត់លែងមានផលប្រយោជន៍សម្រាប់ពួកចិនដែលជាអ្នកធ្លាប់គាំពារគាត់ និងយល់ថា ក្បួនទ្រឹស្តីកុម្មុយនីស្តរបស់គាត់ វាហួសសម័យទៅហើយឬទេ? គំនិតនេះបានការអ្វីខ្លះទៅ? ការពិត គាត់មិនគិតថា បានការ ឬមិនបានការឡើយ ។

ទោះជារបប ប៉ុល ពត ត្រូវបណ្តេញចេញពីអំណាចទៅ



ហើយក៏ដោយ ក៏ក្នុងខែតុលា ឆ្នាំ១៩៨០ អង្គការសហប្រជាជាតិ រួមទាំងសហរដ្ឋអាមេរិកផង នៅតែទទួលស្គាល់របបព្រៃផ្សៃនេះឲ្យមានឋានៈជាសមាជិកនៃអង្គការកំពូលនេះដដែលដោយសំឡេង ៧៤ ទល់នឹង ៣៥ ។ ទន្ទឹមគ្នានោះ មានសេចក្តីរាយការណ៍ថា ប៉ុល ពត នៅតែកាន់តំណែងជានាយករដ្ឋមន្ត្រីដដែល ប៉ុន្តែ ក្រោយពេលដែលរណសិរ្សសាមគ្គីសង្គ្រោះជាតិដឹកនាំដោយលោក ហេង សំរិន ផ្តួលរំលំនោះ តំណែងនេះត្រូវបានជំនួសដោយ ខៀវ សំផន ក្នុងគោលបំណងយ៉ាងច្បាស់លាស់ ដើម្បីកែលម្អរូបភាពរបស់ខ្លួននៅលើឆាកជាតិ និងអន្តរជាតិ ។

ទោះបីជាមានព័ត៌មានតិចតួចស្តួចស្តើងដែលនិយាយពីការរស់នៅផ្ទាល់របស់ ប៉ុល ពត ក៏ដោយ ក៏គេអាចដឹងខ្លះៗថា ក្នុងឆ្នាំ ១៩៧៨ លោក ឌុដម៉េន នៃកាសែត សាំងល្វីស៍ និងអ្នកស្រី អេលីហ្សាប៊ែត បេកខ័រ អ្នកឆ្លើយឆ្លងព័ត៌មាននៃកាសែតវ៉ាស៊ីនតោន ប៉ុស្តិ៍ បានទទួលការអនុញ្ញាតឲ្យជួបធ្វើសម្ភាស ជាមួយ ប៉ុល ពត ផ្ទាល់ ហើយបានរាយការណ៍ឲ្យគេឯងដឹងថា ប៉ុល ពត ពាក់អាវធំពណ៌ប្រផេះដូចអាវរបស់លោកប្រធានម៉ៅ គាត់និយាយភាសាខ្មែរធ្វើបុក "ដូចស្តេចមួយអង្គអ៊ីចឹង" ។ លោក ឌុដម៉េន បានឲ្យដឹងថា ប៉ុល ពត មានកែវភ្នែកភ្លឺថ្លាសក់ល្បាយអាចម៍ខ្លា ទឹកមុខដូចមនុស្សនៅក្មេងមានម្រាមដៃតូចៗទន់ល្មើយស្ទើរតែដូចដើងពីងពាង ។

ចំណែក អ្នកស្រី បេកខ័រ មើលឃើញថា ប៉ុល ពត ជាមនុស្សរួសរាយរាក់ទាក់ ស្រគត់ស្រគំ ហើយមានមាឌរាងធំបន្តិច បើប្រៀបធៀបនឹងជនជាតិខ្មែរមួយចំនួនធំ ។ ចំណែកលោក ហ្សូនបារ៉ុង និង លោក អេនថូនី ប៉ូល បានកត់សម្គាល់ថា ប៉ុល ពត មានអត្តចរិត "ស្ងប់ស្ងៀម ហើយមិនសូវចង់ជួបមនុស្សម្នាទេ ចេះអត់ធ្មត់ជាប់ខាតក្នុងការងារ" ។ តាមសម្តីអ្នកប្រឆាំងម្នាក់ថា គាត់ជាមនុស្សមិនវាងវៃ និងមានលក្ខណៈដូចស្រីអ៊ីចឹង ។ អតីតនាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានទទួលស្គាល់ថា មានសមត្ថភាពពូកែខាងប្រវត្តិសាស្ត្រនោះ ត្រូវបានលោក ឌូក្លាស ផែក ចាត់ទុកថា "មានទេពកោសល្យខ្ពស់ក្នុងលក្ខណៈមួយដូច អាដុល ហ៊ីត្លែរ ដែរ" ។

នៅឆ្នាំ១៩៨២ ចលនាតស៊ូទាំងប៉ុន្មានដែលរួមគ្នាប្រឆាំងនឹងរបបលោក ហេង សំរិន គឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានោះ បាននាំគ្នាបង្កើតរដ្ឋាភិបាលចម្រុះមួយមានឈ្មោះថា "រដ្ឋាភិបាល ចម្រុះកម្ពុជាប្រជាធិបតេយ្យ" ដឹកនាំដោយ សម្តេច សីហនុ រួមមានចលនារណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែររបស់លោក សឺន សាន, ចលនាហ៊្វុនស៊ិនប៉ិច របស់ទ្រង់ រណប្ញទ្ធិ និងចលនាខ្មែរក្រហមរបស់ ខៀវ សំផន ។

ក្រោយមកទៀត ប្រហែលក្នុងឆ្នាំ១៩៨៦-៨៧ សម្តេច សីហនុ និងលោក ហ៊ុន សែន ដែលកាលណោះជានាយករដ្ឋមន្ត្រី បានជួបចរចាគ្នាជាសម្ងាត់ ដើម្បីស្វែងរកសន្តិភាពជូនកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំនាប្រទេសបារាំង រហូតបានសម្រេចនូវកិច្ចព្រមព្រៀងសន្តិភាពមួយដែលភាគីទំនាស់ទាំងអស់បានចុះហត្ថលេខានៅទីក្រុងប៉ារីស នាថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩១ ដោយសម្រេចបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់មួយ ដើម្បីតំណាងអធិបតេយ្យឯករាជ្យ និងឯកភាពរបស់កម្ពុជាក្នុងដំណាក់កាលអន្តរកាល និងបង្កើតអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា អ៊ុនតាក់ "*UNTAC*" ដើម្បីរៀបចំ និងត្រួតពិនិត្យការបោះឆ្នោតជ្រើសរើសសភានីតិបញ្ញត្តិមួយ ពីថ្ងៃទី២៣ ដល់ថ្ងៃ២៨ ខែឧសភា ឆ្នាំ១៩៩៣ រហូតបង្កើតបានរដ្ឋាភិបាលចម្រុះមួយដើម្បីគ្រប់គ្រងប្រទេសតាមប្រព័ន្ធសេរីពហុបក្ស ។ ប៉ុន្តែ ប៉ុល ពត បានប្រឆាំងជំទាស់មិនគោរពតាមកិច្ចព្រមព្រៀងនេះទេ ហើយបានបន្តការប្រយុទ្ធនឹងរដ្ឋាភិបាលថ្មីមកទល់នឹងបច្ចុប្បន្ន ទោះជាភាគីខ្លួនជាហត្ថលេខីមួយនៃកិច្ចព្រមព្រៀងនេះក៏ដោយ ព្រមទាំងខិតខំបំផ្លាញផែនការសន្តិភាពរបស់អង្គការសហប្រជាជាតិថែមទៀត ។

### ៧) ប៉ុល ពត រៀបគម្រោងការដណ្តើមអំណាចនៅកម្ពុជាវិញ ដោយរបៀបណា?

ហេតុអ្វីបានជា ប៉ុល ពត ធ្វើឲ្យអន្តរាយផែនការសន្តិភាពរបស់កម្ពុជា? ។ ជីវប្រវត្តិនយោបាយដំបូងបំផុតរបស់មេដឹកនាំខ្មែរក្រហម ដែលគាត់តែងឡើងដោយជនជាតិអូស្ត្រាលី ដេវិឌ ឆេនល័រ យ៉ាងល្អិតល្អន់គ្មានចន្លោះនេះ បានធ្វើឲ្យគេកាន់តែយល់ច្បាស់ពីសកម្មភាពរបស់គាត់ ។ ជាអ្នកទទួលខុសត្រូវចំពោះការស្លាប់នៃជនរួមជាតិឯងចំនួនជាង២លាននាក់ ប៉ុល ពត ពុំមានផ្លាស់ប្តូរបន្តិចណាសោះ ដោយនៅតែប្រកាន់យ៉ាងតឹងរ៉ឹងតាមខ្សែបន្ទាត់នៃលទ្ធិស្តាលីន-ម៉ៅនិយម ឯកោខ្លួនឯងក្នុងព្រៃភ្នំ គាត់បានត្រៀមខ្លួនដឹកនាំប្រទេសរបស់គាត់ម្តងទៀត ដោយអនុវត្តតាម "ក្បួន" ដូចកាល

ពីមុនដដែល ។

ជាមនុស្សដែលចូលចិត្តលាក់ខ្លួនមិនចង់ឲ្យនរណាជួបឡើយ ។ តើគាត់នៅតែរស់នៅម្តងម្កាលនៅ “ការិយាល័យ៨៧” ដែលជាបន្ទាយដ៏រឹងមាំរបស់គាត់មានបរិវេណ៣០០ម៉ែត្រ គុណនឹង៥០០ម៉ែត្រ ព័ទ្ធជុំវិញដោយរបងលួសបន្លា ក្បែរខេត្តត្រាត ប្រទេសថៃដែរឬទេ? ឬមួយគាត់រស់នៅតំបន់ប៉ាងរលឹម ដែលជាមូលដ្ឋានធំរបស់ខ្មែរក្រហមស្ថិតនៅក្នុងព្រៃរបស់កម្ពុជា? ។ ទំនងប្រហែលជាគាត់ខស្សាហ៍ធ្វើដំណើរទៅមករវាងកន្លែងទាំង២នេះ ដោយបែងចែកពេលវេលាដើម្បីតាមឃ្លាំមើលយ៉ាងជិតដល់ចំពោះតំណាងទាំង២រូបរបស់គាត់ដែលស្ថិតក្នុងផ្ទៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៅក្រុងភ្នំពេញ និងការថ្នាក់ថ្នមបរបោសអង្អែលកូនស្រីគាត់ដែលមានអាយុ៥ឆ្នាំនោះហើយមើលទៅ ។

បើទុកជាគាត់ពុំមានការទទួលខុសត្រូវណាមួយក្នុងឋានានុក្រមខ្មែរក្រហមក៏ដោយ ក៏ ប៉ុល ពត នៅតែជាអ្នករៀបចំគម្រោងការដ៏ចម្បងក្នុងបញ្ហាសំខាន់ៗរបស់កម្ពុជាដដែល ។ យុទ្ធសាស្ត្ររបស់គាត់គឺបំផ្លាញផែនការសន្តិភាពរបស់អង្គការសហប្រជាជាតិ ។ ការបដិសេធមិនបណ្តោយឲ្យពួកមួកខៀវដកអាវុធពីក្រុមរបស់គាត់ ការដាក់មីនតាមផ្លូវនានា ការកាប់សម្លាប់ពួកអន្តោប្រវេសន៍វៀតណាម ការចាប់ពង្រត់ពួកទាហានអង្គការសហប្រជាជាតិតមកទៀត ការវាយប្រហារទីក្រុងបាត់ដំបងនៅពេលជិតបុណ្យណូអែល និងការបាញ់គ្រាប់បែកទៅលើពួកមួកខៀវដែលបោះទីតាំងនៅជិតក្រុងសៀមរាប គឺ គាត់ជាអ្នកបញ្ជាទាំងអស់ ។ បច្ចុប្បន្នក៏ដូចពីមុន ខៀវ សំផន ដែលជាមេដឹកនាំផ្លូវការរបស់ចលនានេះ បានផ្សព្វផ្សាយសំឡេង “ចៅហ្វាយ” របស់គាត់ ប្រៀបដូចជាម៉ាញ៉េថតសំឡេងមួយអ៊ីចឹង ។

ហេតុអ្វីបានជាគាត់ចង់បំបាក់មុខអង្គការសហប្រជាជាតិ? និងជ្រើសរើសយកការប្រឈមមុខដាក់គ្នា បន្ទាប់ពីខ្លួនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសរួចហើយនោះ ។ បើទុកជាគាត់មានការស្អប់ខ្ពើមវៀតណាមយ៉ាងណាក៏ដោយ ក៏គាត់មិនទុកចិត្តចំពោះលេសដែលជាភ័ស្តុតាងនៃការបដិសេធរបស់គាត់មិនសហការជាមួយផែនការសន្តិភាពនោះថា វាត្រឹមត្រូវ ឬយ៉ាងណាទេ ។ លេសនោះ គឺការសង្ស័យថា មានវត្តមាននៃកងពលរបស់វៀតណាមនៅកម្ពុជានៅឡើយ ។ ក៏ប៉ុន្តែការវិភាគដ៏ចង្អៀតចង្អល់របស់គាត់ អំពីភាពដូចគ្នានៃកម្លាំងផ្សេងៗ បានជំរុញឲ្យគាត់ប្រព្រឹត្តការរំលោភបំពានមួយ ។ ពួកខ្មែរក្រហមពុំអាចឈ្នះការបោះឆ្នោតទេ ។ ប៉ុន្តែ អង្គការសហប្រជាជាតិ ក៏ពុំមានមធ្យោបាយបង្ក្រាបពួកនេះដោយកម្លាំងយោធាបានដែរ ។ នៅថ្ងៃណាមួយ អង្គការសហប្រជាជាតិនឹងចាកចេញទៅវិញ នៅពេលនោះ “បងលេខ១” អតីតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ប្រហែលជាអាចវិលមកកាន់អំណាចជាថ្មីនៅកម្ពុជា ។

តើនេះជាការយល់សប្តិរបស់មនុស្សឆ្កួតម្នាក់ឬ? គេជាជនកុម្មុយនីស្តបរិសុទ្ធចុងក្រោយ ជាពន្លកថ្មីចុងក្រោយរបស់ ស្តាលីន និង ម៉ៅ គេជាមនុស្សម្នាក់ដែលមិនដែលសម្តែងការសោកស្តាយទាល់តែសោះចំពោះជនរងគ្រោះរាប់លាននាក់នៃរបបមួយដែលគេអួតថា “ត្រឹមត្រូវតាមច្បាប់ និងប្រកបដោយគុណធម៌” នោះ ។ គេជាមនុស្សម្នាក់ដែលជីវប្រវត្តិរបស់ខ្លួនស្ថិតនៅក្រោមអានុភាពនៃការរួមគំនិតក្បត់ និងអាថ៌កំបាំង ។

## ៣) ជីវិតបច្ចុប្បន្នរបស់ ប៉ុល ពត

តាមការរៀបរាប់របស់ឧត្តមសេនីយ៍ខ្មែរក្រហម ដែលរត់មកចុះចូលជាមួយរដ្ឋាភិបាលថ្មី បានឲ្យដឹងថា “ប៉ុល ពត តែងរត់គេចខ្លួនពីកន្លែងពួនមួយទៅកន្លែងពួនមួយ ដោយរួមដំណើរជាមួយប្រពន្ធថ្មី និងកូនស្រីរបស់គាត់ជានិច្ច ។

មេផ្តាច់ការរូបនេះ ដែលបង្កប់ឲ្យគេសម្លាប់ប្រជាជនឯងបច្ចុប្បន្នមានតែពួកទ័ពព្រៃមួយក្តាប់តូចប៉ុណ្ណោះ ដែលនៅដើរតាមគាត់ដោយសារតែការរត់ចោលជួរជាបន្តបន្ទាប់របស់ពួកនេះ ។ ក្នុងការចាញ់របស់គាត់ មេដឹកនាំខ្មែរក្រហមរូបនេះ នៅតែជាតួអង្គម្នាក់ដែលគេមិនអាចស្គាល់បានដដែល ។ គេស្ទើរតែមិនដឹងអ្វីបន្តិចសោះពីជីវិតឯកជនរបស់គាត់ ។ ឈរពីលើសាកសពរាប់លាននាក់ ប៉ុល ពត បានបង្កឲ្យមានការកោតស្ញប់ស្ញែងក្នុងរយៈមួយដ៏យូរដែលស្ទើរតែគ្មានលាក់លៀមថា គាត់ជាដើមឯកខាងលទ្ធិសង្គមនិយមពិតប្រាកដ ។ ការពិពណ៌នាអំពីចរិតមនុស្ស ដែលអតីតឧត្តមសេនីយ៍របស់គាត់និយាយប្រាប់អ្នកកាសែត បានបង្ហាញឲ្យឃើញថា ប៉ុល ពត ជាឃាតករម្នាក់ និងជាអ្នកមិនគោរពសាសនាម្នាក់ ។

## ៤) ប៉ុល ពត ផ្លាស់ប្តូរទីកន្លែងគ្មានឈប់ឈរ ដើម្បីគេចពី

## គ្រាប់ផ្លោងកាំភ្លើងធំ

ក្នុងទីតាំងមួយរបស់កងទ័ពកម្ពុជានៅក្បែរអន្លង់វែង អតីតនាយទាហានជាន់ខ្ពស់ខ្មែរក្រហមម្នាក់ ដែលសុំចុះចូលនឹងរដ្ឋាភិបាលស្របច្បាប់ បានជួបសម្ភាសជាមួយអ្នកកាសែតម្នាក់ ដោយបើកភ្នែកធំៗ ដូចភ្នែកខ្លា ដើម្បីបង្ហាញឲ្យឃើញនូវភាពស្មោះត្រង់អស់ពីដួងចិត្តរបស់ខ្លួនថា «តើលោកមិនជឿខ្ញុំទេឬ?» មានត្រង់ណាទៅដែលគេមិនជឿគាត់នោះ? ព្រោះគាត់ធ្លាប់ស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់ ប៉ុល ពត ក្នុងរយៈពេលជាង២០ឆ្នាំមកហើយ ហើយធ្លាប់នៅក្បែរ ប៉ុល ពត ជាញឹកញាប់ផង ។ គេជៀសមិនស្រឡាំងកាំងបានឡើយ នៅពេលដែលគេឮសាក្សីដ៏មានអំណាចម្នាក់នេះ បញ្ជាក់អះអាងយ៉ាងច្បាស់ ថាឧក្រិដ្ឋជនដ៏ល្បីល្បាញម្នាក់ក្នុងចំណោមឧក្រិដ្ឋជនល្បីៗរបស់ពិភពលោក អ្នកប្រព្រឹត្តអំពើកាប់សម្លាប់ប្រជាជនកម្ពុជា គឺជាស្វាមីដ៏ចេះថ្នាក់ថ្នមម្នាក់ និងជាជីតាដ៏ស្លូតបូតបំផុតម្នាក់នោះ ។ «គាត់បានរៀបការម្តងទៀតជាលើកទី២ ក្នុងអាយុ៦៨ឆ្នាំ ជាមួយស្រីម្នាក់ដែលមានអាយុតិចជាងគាត់៤០ឆ្នាំ និងបានកូនស្រីមួយ ។ គាត់មានឥរិយាបថពោរពេញដោយការស្រឡាញ់ទៅលើប្រពន្ធ និងកូនខ្លាំងជាងមនុស្សប្រុសឯទៀតៗ ហើយជាមួយមនុស្សគ្រប់រូប គាត់មានបុកពាជាសាស្ត្រាចារ្យម្នាក់ ដែលមានឥទ្ធិពលទៅលើកូនសិស្សរបស់ខ្លួន ដោយសារសម្រស់ និងការពូកែនិយាយរបស់គាត់» ។

ទុយ ប៊ុនរ៉េត ជាមេបញ្ជាការកងវរសេនាធំខ្មែរក្រហម ៩១២ ជាឧត្តមសេនីយ៍ម្នាក់ថាអ្វីចឹងចុះ ប៉ុន្តែក្នុងកងទ័ពរបស់ ប៉ុល ពត ឋានន្តរស័ក្តិនេះ ពុំមានទេ ។ រ៉េត ជាមនុស្សមានមាឌក្រអាញ អាយុ៤០ឆ្នាំ បានរត់មកចុះចូលនឹងកងទ័ពរដ្ឋាភិបាលនៅខែកុម្ភៈ ឆ្នាំ១៩៩៥ ជាមួយកម្លាំងរបស់គាត់២០០នាក់ ។ គាត់បាននិយាយថា «ខ្ញុំធ្លាប់វាយប្រយុទ្ធតាំងពី២២ឆ្នាំមកម្ល៉េះ ។ ខ្ញុំគិតថា គេនឹងមិនចំណេញបានអ្វីទាំងអស់ក្នុងការបន្តសង្គ្រាមទៀតនោះ ។ តាំងពីយូរយារមកហើយ ពួកយុទ្ធជនដែលនៅក្រោមបញ្ជាខ្ញុំ មានការនឿយណាយនឹងធ្វើសង្គ្រាមណាស់ ។ ពេលនោះ ខ្ញុំបានបញ្ចុះបញ្ចូលកូនចៅខ្ញុំ ដែលខ្ញុំមានទំនុកចិត្តជាងគេ ហើយយើងបានលួចរត់ចេញដោយនាំយកអាវុធ និងសម្ភារមកជាមួយផង» ។

អតីតឧត្តមសេនីយ៍ខ្មែរក្រហមរូបនេះ បានអះអាងថា តាំងពីដើមមក ប៉ុល ពត មិនដែលរស់នៅកន្លែងណាមួយឲ្យជាប់លាប់ទេ ។ គាត់ភ័យខ្លាចណាស់ក្រែងត្រូវគេទម្លាក់គ្រាប់បែក ឬវាយឆ្មក់ចាប់ខ្លួនបាន ។ «គាត់ផ្លាស់ប្តូរទីកន្លែងបោះជំរំរៀងរាល់ថ្ងៃ ។ គាត់កម្រស្ថិតនៅក្នុងសេនាធិការមួយឲ្យបាន២យប់ជាប់គ្នាណាស់ ។ ប៉ុន្តែ តាមបណ្តោយព្រំដែនដែលគាត់តែងធ្វើដំណើរទៅមកញឹកញាប់ គឺសុទ្ធតែជាកន្លែងដែលមានសន្តិសុខបំផុត ។ សឹងតែគ្រប់ពេលគាត់ច្រើនធ្វើដំណើរតាមរថយន្ត ៤x៤ ម៉ាស៊ីន ត្រជាក់របស់ជប៉ុន១គ្រឿង ពណ៌ស និងមានអង្គរក្ស៤នាក់ តាមគាត់ជាប់គ្រប់ជំហាន» ។ ទីបញ្ជាការដ៏សំខាន់របស់គាត់ ស្ថិតនៅលើជួរភ្នំខាងលិចជួរភ្នំក្រវាញជាប់ព្រំដែនថៃ ។ ជួរភ្នំដែលគេមិនអាចវាយលុកបាននេះ ជាជម្រកប្រពៃណីរបស់ពួកទ័ពព្រៃ ដែលមានចំណុចខ្ពស់បំផុត១៧១៧ម៉ែត្រ គ្របដណ្តប់ទៅលើប្រទេសថៃ និងឈូងសមុទ្រសៀម មានបណ្តោយប្រវែងប្រហែល៥០០គីឡូម៉ែត្រ ។ ទីបញ្ជាការនោះ គេហៅជាឈ្មោះសម្ងាត់ថា «ការិយាល័យ៨៧» រួមមានផ្ទះឈើតូចៗ ដែលមានផ្ទះជាច្រើនត្រូវគេរៀបចំសម្រាប់ពួកមេដឹកនាំខ្មែរក្រហមកំពូលៗ និងក្រុមគ្រួសាររបស់គេ ។ ជំរំដ៏រឹងមាំនេះ គឺមានទីតាំងនៅជិតបង្កើយបំផុតនឹងប្រទេសថៃ ។ នៅពេលមានភេរវសញ្ញា ប៉ុល ពត និងញាតិមិត្តរបស់គាត់ អាចរត់រកទីលាក់ខ្លួននៅម្ខាងព្រំដែនបានយ៉ាងឆាប់រហ័សដោយឆ្លងកាត់តាមព្រៃក្រាស់មួយឆ្ពោះទៅខេត្តត្រាតរបស់ថៃតែម្តង ។ ម៉្យាងទៀតជនកាល ដើម្បីរត់គេចពីការទម្លាក់គ្រាប់បែក ឬប្រតិបត្តិការជាយថាហេតុផ្សេងៗ ដែលធ្វើឡើងតាមខទ្ធម្ភាគចក្រ គាត់នឹងស្ថិតនៅក្នុងទឹកដីថៃ ដោយគ្មានលាក់លៀមឡើយ វាពិតណាស់ គឺដោយសារមានការឃុបឃិតរបស់កងទ័ពក្រុងបាងកកនេះឯង ដែលក្នុងនោះ មានកងឯកភាពពិសេស២ កងលេខ៣៨៨ និងលេខ៨៣០ ដែលនៅតែបន្តផ្គត់ផ្គង់ស្បៀង អាហារ និងគ្រាប់រំសេវជាសម្ងាត់ឲ្យពួកខ្មែរក្រហមរហូតមក ។ អតីតឯកអគ្គរដ្ឋទូតខ្មែរក្រហមម្នាក់ប្រចាំនៅអឺរ៉ុប ហើយដែលសព្វថ្ងៃកំពុងរស់នៅដោយស្ងាត់កំបាំងនៅប្រទេសថៃ បានបញ្ជាក់ថា គាត់ធ្លាប់បានឃើញពីចម្ងាយនូវមនុស្សដែលគេហៅ «បងលេខ១» នៅតាមផ្លូវមួយនៃទីរួមខេត្តត្រាត ។ អ្នកការទូតនេះបានរៀបរាប់ថា «ប៉ុល ពត ហាក់ដូចជាមនុស្សដែលមិនចេះរីងខ្លួនដៃ គាត់ឱបកញ្ចប់ទំនិញដែលគាត់ទើបនឹងទិញពីហាងលក់អីវ៉ាន់មួយចំនួន គាត់ដើរទៅកាន់រថយន្តរបស់គាត់ ដែលមានលេខសម្គាល់

ចុះបញ្ជីនៅប្រទេសថៃ ។ ពួកកម្មាភិបាលខ្មែរក្រហមដើរតាមពីក្រោយគាត់កិតៗ ធ្វើមិនដឹង» ។ នៅចម្ងាយ៨០គីឡូម៉ែត្រ ពី «ការិយាល័យ៨៧» នាភាគនិរតីបំផុតរបស់កម្ពុជា គឺកំពង់ផែខ្វងយៃរបស់ថៃ ហើយដែលស្ថិតមិនឆ្ងាយប៉ុន្មានពីកំពង់ផែ កំពង់សោមឡើយ នេះគឺជាច្រកទ្វារក្នុងការដឹកនាំចូលនូវសម្ភារយោធារបស់ចិនសម្រាប់ផ្តល់ឲ្យពួកខ្មែរក្រហម ។

គឺជារឿងដែលគេដឹងឮគ្រប់គ្នាទៅហើយថា ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ប៉ុល ពត តែងត្រាច់ចរដូច្នេះបានដោយសេរីនៅក្នុងប្រទេសថៃ គាត់ក៏ធ្លាប់ទៅស្នាក់អាស្រ័យព្យាបាលរោគនៅមន្ទីរពេទ្យយោធាក្រុងបាងកកជាច្រើនលើក ដោយធ្វើដំណើរតាមឧទ្ធម្ភាគចក្រ ។ វត្តមានរបស់គាត់នៅទីនោះ ត្រូវបានគេប្រកាសឲ្យដឹងជារឿយៗទៅដំរីមួយទៀត ដែលស្ថិតនៅខាងជើងបំផុតនៃជួរភ្នំក្រវាញ ក្បែរភូមិមួយរបស់ថៃឈ្មោះ បូរ៉ៃ និងមិនឆ្ងាយប៉ុន្មានពីទីក្រុងប៉ៃលិនឡើយ ។ ដើម្បីធ្វើដំណើរពីតំបន់មួយទៅតំបន់មួយ ពីឈូងសមុទ្រសៀមទៅព្រំដែនឡាវ គឺវាងាយស្រួលណាស់ចំពោះគាត់ ក្នុងការប្រើប្រាស់ផ្លូវជាតិធំៗ និងផ្លូវលំនានាតាមបណ្តោយព្រំដែនថៃពីលិចទៅកើត ។ អ្នករត់ចោលជួរ ខ្លះបានពោលអះអាងថា បើទុកជារដ្ឋាភិបាលក្រុងបាងកក បានស្បថស្បែប្រាំដែលៗនឹងក្រុងភ្នំពេញក៏ដោយ ក៏ភាពងាយស្រួលទាំងនេះ នៅតែត្រូវបានបន្តអនុញ្ញាតឲ្យគាត់ដដែល ។ ក៏ប៉ុន្តែឥឡូវនេះ ប៉ុល ពត មានការរួញរានឹងបង្ហាញខ្លួននៅប្រទេសថៃយ៉ាងខ្លាំង ។ គាត់ច្រើនតែធ្វើដំណើរស្រាវជ្រាវរយៈពេលខ្លីៗ ខាងក្រៅព្រំដែនរបស់ខ្លួនជាមួយសេនាធិការរបស់គាត់ ឬក៏ម្នាក់ឯង ។ ជាពិសេស ការធ្វើដូច្នេះ គឺមកពីគាត់មានបំណងផ្លាស់ប្តូរទីកន្លែងតែម៉្យាងប៉ុណ្ណោះ ។

អតីតឧត្តមសេនីយ៍ខ្មែរក្រហមរូបនេះ បានប្រាប់រឿងឲ្យគេដឹងថា «មុនការដើរត្រួតពិនិត្យរបស់គាត់ម្តងៗ ពួកអ្នកដែលទទួលបន្ទុកការពារសន្តិសុខរបស់គាត់ តែងដើរទៅមុខជានិច្ច ដើម្បី «បោសសម្អាត» ។ សម័យនោះ ផ្ទះតូចមួយដែល ប៉ុល ពត ត្រូវទៅធ្វើការមិនអាចឲ្យនរណាម្នាក់ចូលទៅជិតបានឡើយ ។ នៅជុំវិញផ្ទះ មានកប់មីនប្រឆាំងមនុស្សយ៉ាងច្រើន ។ គាត់នៅតែរុំព័ទ្ធជុំវិញខ្លួន ដោយភាពអាថ៌កំបាំងលើសពីមុនទៅទៀត ដូចគ្នាដែរកាលពីឆ្នាំ១៩៩១ នៅពេលដែល ខៀវ សំផន មាន ទីស្នាក់ការជាផ្លូវការនៅក្រុងភ្នំពេញ ហើយពេលដែលពួកយើងរស់នៅក្នុងតំបន់របស់យើងប្រកបដោយសន្តិសុខនោះ ប៉ុល ពត មិនដែលបង្ហាញខ្លួនឲ្យគេឃើញសោះឡើយ ។ ជាច្រើនលើកណាស់ ក្នុងឱកាសដែលខ្ញុំទៅជួប ប៉ុល ពត ម្តងៗ ខ្ញុំអាចឃើញប្រពន្ធថ្មី និងកូនរបស់គាត់នៅជាមួយនោះដែរ ។ ខ្ញុំបានដឹងពីការរៀបការលើកទី២ របស់គាត់តាំងពីយូរយារណាស់មកហើយ ។ នេះពុំមែនជាការសម្ងាត់មួយសម្រាប់បុគ្គលណាម្នាក់ទេ ។ ប៉ុន្តែ រហូតមកទល់នឹងពេលនេះ ខ្ញុំពុំមានឱកាសសម្គាល់រឿងនេះឲ្យច្បាស់ដោយខ្លួនឯងនៅឡើយ ។ ខ្ញុំក៏ដឹងដែរថា យុវនារីអាយុ៣០ឆ្នាំនេះ បានបម្រើការងារជំនួសគាត់បានយ៉ាងល្អ ហើយថា ក្មេងស្រីតូចអាយុ៤ឆ្នាំ ដែលតាមគាត់ស្អិតនោះ គឺជាកូនដែលគាត់បានភពប្រសព្វជាមួយនាងនោះហើយ ។ ដុតពីសម័យប្រជុំផ្សេងៗ ដែលពេលនោះពួកយើងត្រូវបានអញ្ជើញឲ្យចូលរួមពិធីជប់លៀងរួមគ្នារៀងរាល់លើកដែលគាត់បង្ហាញខ្លួនឲ្យឃើញ គឺតែងតែមានប្រពន្ធ និងកូនតាមជាប់ជាមួយជានិច្ច ហើយជាមួយប្រពន្ធ និងកូន គាត់តែងប្រកាន់ឥរិយាបថជាស្វាមី ដែលចេះយកចិត្តយកថ្លើមម្នាក់ និងជាឪពុកដ៏ទន់ភ្លន់ម្នាក់ ។ ប៉ុល ពត ក៏ខស្សរាហ៍ពកូនរបស់គាត់ទៅកន្លែងធ្វើការរបស់ក្រុមប្រឹក្សាយោធាដែរ ។ រឿងនេះ អាចធ្វើឲ្យគេជឿងឆ្ងល់ក្នុងចិត្ត ប៉ុន្តែ ប៉ុល ពត ពុំដែលសម្តែងខ្លួនឲ្យគេចាប់អារម្មណ៍ថា គាត់ជាមេដឹកនាំក៏តឹងរ៉ឹងគ្មានសន្តោសម្នាក់នោះឡើយ ។ ផ្ទុយទៅវិញ គាត់តែងសម្តែងចេញឲ្យឃើញហាក់ដូចជាបុគ្គលម្នាក់ដែលចូលចិត្តភាពស្ងប់ស្ងៀម និងស្លូតបូត បើទុកជាគាត់មិនសូវនិយាយស្តីក៏ដោយ ។ ការសើចញញឹមរបស់គាត់ ក៏កម្រមានដែរ ប៉ុន្តែនៅពេលដែលគាត់បង្ហាញខ្លួនម្តងៗ គាត់ច្រើនបញ្ចេញការសប្បាយរីករាយ ដោយគ្មានលាក់លៀមឡើយ ។ ពេលគាត់និយាយ គឺតែងបង្ហាញឲ្យឃើញធ្មេញសក្បុស និងរាបស្មើដួរយ៉ាងល្អ ។ សំឡេងដ៏ធូន់របស់គាត់បែរជាមានភាពរមទម្យ និងស្រទន់គ្មានប្រឡោត ។ នៅពេលចេញពីសិក្ខាសាលាផ្សេងៗ ជាទីដែលគាត់តែងតែនិយាយខទ្មេសនាមហូរហៀរៗនោះ គាត់បែរជានិយាយតិចតួចទៅវិញនៅខាងក្រៅ ។ បទបញ្ជាទាំងឡាយរបស់គាត់ ពិតមែនតែខ្លី តែមានខ្លឹមសារច្បាស់លាស់ ។ គេច្រើនហៅគាត់ថា «អ៊ំៗ» ដោយការគោរព និងការខ្លាចញញើត បើទុកជាវាផ្ទុយនឹងទឹកចិត្តខាងក្នុងរបស់ខ្លួនក៏ដោយ ។ គ្រាន់តែគេដើរចូលទៅជិត

ដល់កន្លែងដែលគាត់រស់នៅ គេបានប្រកាសប្រាប់យើងឲ្យដឹងជាមុនថា ហាមមិនឲ្យអាត់សំឡេង និងថតរូបឡើយ ។ ប្រពន្ធរបស់គាត់ហាក់ដូចជាមានសារសំខាន់ណាស់ សម្រាប់រូបគាត់ ។ នាងរស់នៅក្នុងផ្ទះឈើតូចដាច់ដោយឡែកពីគេ ឆ្ងាយពីផ្ទះដែលគេបម្រុងទុកសម្រាប់បើកសម័យប្រជុំសិក្សាផ្សេងៗ ដោយបណ្ដាមេបញ្ជាការកងវរសេនាតូច ឬកងពល ។

**៤) មេដឹកនាំអាយុ៦៨ឆ្នាំ យកចិត្តយកថ្លើមប្រពន្ធអាយុ៣០ឆ្នាំ នៅមុខអង្គរក្សរបស់ខ្លួន**

អ្នករត់ចុះចូលនឹងរដ្ឋាភិបាលភ្នំពេញម្នាក់ទៀតឈ្មោះ ម៉ុក ជាកូនទាហានសាមញ្ញម្នាក់ ក្នុងអម្បូរជនជាតិភាគតិចចារ៉ាយ ហើយដែលធ្លាប់ធ្វើជាអ្នកបម្រើអស់រយៈជាច្រើនឆ្នាំក្នុងការយាមការពារក្បែរៗ ប៉ុល ពត នោះ បានរៀបរាប់យ៉ាងល្អិតល្អន់ពី "ចៅហ្វាយចាស់" របស់ខ្លួនថា "នៅមុខពួកអង្គរក្សរបស់គាត់ ពុក (ពួកជនជាតិច្រើនហៅ ប៉ុល ពត ដូច្នេះ) បញ្ចេញកាយវិការដែលធ្វើឲ្យគេរំជួលចិត្តជាញឹកញាប់ជាមួយនឹងប្រពន្ធរបស់គាត់ ដូចជាគាត់រៀបតម្រឹមក្រមាដែលប្រពន្ធបង់ជុំវិញក ឬអង្អែលប្រអប់ដៃ ឬកំភួនដៃប្រពន្ធ" ។ អ្នករត់ចោលជួររូបនេះ បានសម្គាល់ឃើញថា "មនុស្សប្រុសម្នាក់ដែលមានអាយុច្រើន ជាទូទៅគឺមានការខ្មាសអៀនណាស់ នៅពេលដែលគេធ្វើដូច្នេះជាមួយប្រពន្ធរបស់ខ្លួន នៅចំពោះមុខមនុស្សយ៉ាងច្រើននោះ" ។ គាត់បន្ថែមថា "ហេតុការណ៍ធម្មតាមួយ ដែលមានអ្នកណាម្នាក់ហ៊ានព្យួរម៉ាស៊ីនថតរូបនៅនឹងក ឬកាន់នៅដៃ ហើយហ៊ានចូលទៅក្បែរ ប៉ុល ពត នោះ អាចត្រូវផ្ដន្ទាទោស "បាត់ខ្លួន" ជាមិនខាន" ។ ថ្ងៃមួយ គាត់បានឃើញរឿងដូចនេះកើតឡើង គាត់បាននិយាយថា មានកម្មាភិបាលម្នាក់ដែលទើបត្រឡប់មកពីប្រទេសចិនថ្មីៗ បានត្រូវគេនាំយកទៅព្រៃមួយក្បែរៗទីនោះ ប្រហែលជាគាត់លើកកាមេរ៉ាវីដេអូតម្រង់ទៅរកកន្លែង ប៉ុល ពត ហើយមើលទៅ ។

ក្រោយសំឡេងគ្រាប់កាំភ្លើងផ្ទុះ ខ្ញុំបានឮ ប៉ុល ពត ចោទប្រកាន់កម្មាភិបាលដែលប្រព្រឹត្តល្មើសនេះថាជា "មេរោគ" ។ នេះជាពាក្យមួយដែលជាទម្លាប់របស់គាត់ដើម្បីជេរត្មះតិះដៀលគូសត្រូវទាំងឡាយរបស់គាត់ ហើយជាពិសេស គឺជេរពួកអ្នកកាន់អំណាចនៅភ្នំពេញមួយក្រុម ហើយក៏ជាសញ្ញាសម្គាល់គ្រោះអាក្រក់មួយដែរ ។

ការរៀបអាពាហ៍ពិពាហ៍លើកទី២របស់ ប៉ុល ពត ជាមួយអតីតអ្នកបម្រើគាត់ រឹតតែធ្វើឲ្យ ទុយ ប៊ុនរេត និងបណ្ដាមិត្តភក្ដិគាត់ភ្ញាក់ផ្អើលខ្លាំងឡើងៗ ព្រោះគេដឹងថា ប៉ុល ពត ធ្លាប់មានប្រពន្ធម្នាក់រួចមកហើយ និងមានកូនប្រុសម្នាក់ ស្រីម្នាក់ ដែលសព្វថ្ងៃប្រហែលជាមានអាយុ១០ ឬ១១ឆ្នាំប៉ុណ្ណោះ ។ គាត់បានរៀបការលើកទី២ នៅឆ្នាំ១៩៨២ បន្ទាប់ពីបានលែងលះប្រពន្ធទី១របស់គាត់ឈ្មោះ ខៀវ ប៉ុណ្ណារី ដែលមានអាយុបងគាត់៧ឆ្នាំ ដែលគាត់ធ្លាប់ជួបស្គាល់កាលពីឆ្នាំ១៩៥០ នៅក្រុងប៉ារីស ពេលនោះ អ្នកទាំងពីរ គឺជានិស្សិតដែលទទួលអាហារូបករណ៍ពីរដ្ឋាភិបាលបារាំង ។

តើប៉ុណ្ណារី ប្រពន្ធទី១របស់ជនស្រេកឃ្លានឈាម ប៉ុល ពត ក្លាយទៅជាយ៉ាងណាទៅហើយ? ។ គ្មានអ្នកចុះចូលណាម្នាក់បានឃើញរូបនាងតាំងពីច្រើនឆ្នាំមកហើយ ។ ព័ត៌មានផ្សេងៗ បានរាយការណ៍ដូចគ្នាថា នាងបានស្លាប់នៅឆ្នាំ១៩៨៧ ឬ១៩៨៨ ដោយសារជំងឺ ឬត្រូវគេសម្លាប់ចោល ។ ដោយអ្នកណា? ប្រហែលតាមបញ្ជារបស់ ប៉ុល ពត ដោយផ្ទាល់តែម្ដង ។ នាងធ្លាប់បានគេចផុតពីការប៉ុនប៉ងដាក់ថ្នាំបំពុលមួយដងនៅឆ្នាំ១៩៧៩ ឬ១៩៨០ តែគេបានជួយសង្គ្រោះជីវិតនាងបានយ៉ាងប្រផិតប្រផើយ ដោយបញ្ជូននាងទៅដេកពេទ្យនៅប្រទេសថៃ ។ នៅពេលនោះ ហើយដែល ប៉ុល ពត បានមករស់នៅជាមួយប្រពន្ធទី២របស់គាត់ ក្នុងតំបន់មួយដែលនៅមិនឆ្ងាយពីកន្លែងមុនឡើយ ។ ប្រការនេះ គ្រាន់តែគាត់ចង់ជៀសវាងពីមនុស្សខ្លះ ដែលបានឃើញការលូកដៃរបស់គាត់ក្នុងការប៉ុនប៉ងធ្វើឃាតនេះប៉ុណ្ណោះ ។ **(តទៅលេខក្រោយ)**

**ធេព ម៉េងឃាន**

## អានទស្សនាវដ្ដីតាមគេហទំព័រ

ទស្សនាវដ្ដីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ការជួបជាមួយ នួន ជា នៅតុលាការកាត់ទោស មេដឹកនាំខ្មែរក្រហម

លោកសាស្ត្រាចារ្យ អាឡិចហ្សានដឺ ហ៊ិនតុន គឺជាអ្នកនិពន្ធសៀវភៅ «ហេតុអ្វីបានសម្លាប់មនុស្ស ៖ ប្រទេសកម្ពុជានៅក្នុងស្រមោលអំពើប្រល័យពូជសាសន៍» ។ ជាសៀវភៅមួយដែលបានបោះផ្សាយនៅឆ្នាំ២០០៥ ស្តីអំពីរបបខ្មែរក្រហម ។ នៅខែមីនា លោកបានផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅម្យ៉ាងទៀតថា តុលាការខ្មែរក្រហម នៅរាជធានីភ្នំពេញ ។ អ្នកនិពន្ធជនជាតិអាមេរិកាំង និងជាអ្នកសិក្សាស្រាវជ្រាវរូបនេះ បានផ្តល់សក្ខីកម្មរយៈពេលជាងបីថ្ងៃពេញ នៅតុលាការ ដើម្បីផ្តល់សក្ខីកម្មនៅក្នុងករណី០០២/០២ ដែលជាសវនាការអំពីការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ចំពោះមេដឹកនាំកំពូលនៃរបបខ្មែរក្រហម នួន ជា និង ខៀវ សំផន ។ លោកសាស្ត្រាចារ្យបាននិយាយជាមួយកញ្ញា សើ សាយ្យាណា នៃ វី.អូ.អេ ខ្មែរ អំពីការប្រឈមរបស់លោកជាមួយនឹង «បងធំទី២» នួន ជា និងអំពីមូលហេតុដែលលោកធ្វើការសច្ចាប្រណិធានខុសពីសាក្សីជាជនជាតិប៉ែកលោកខាងលិចដទៃទៀត គឺលោកបែរជាស្បថសច្ចាតាមបែបប្រពៃណីរបស់ពុទ្ធសាសនានៅមុខលោកតាដំបងដែកទៅវិញ នៅមុនពេលដែលលោកឡើងបំភ្លឺក្នុងសាលសវនាការ ។ បទសម្ភាសន៍នេះត្រូវបានសម្រួលដើម្បីឲ្យមានភាពច្បាស់លាស់ និងងាយយល់ន័យ ។

***តើលោកកំពុងគិតអំពីអ្វីខ្លះដែរ នៅពេលដែលលោកឡើងបំភ្លឺថ្ងៃដំបូងនៅតុលាការខ្មែរក្រហម?***

វាគឺជារយៈពេលដ៏តានតឹងមួយក្នុងការផ្តល់សក្ខីកម្មរយៈពេលបីថ្ងៃកន្លះនេះ ។ នៅពេលខ្ញុំទៅដល់ដំបូង មានការមិនប្រាកដក្នុងចិត្តខ្លះ ដោយសារខ្ញុំដឹងច្បាស់ថាដំណើរការយ៉ាងម៉េច ហើយគេនឹងសួរខ្ញុំពីអ្វីខ្លះ ។ ប៉ុន្តែ ខ្ញុំក៏មានអារម្មណ៍រំភើបខ្លាំងណាស់ដែរ ដែលបានចូលរួមចំណែកក្នុងដំណើរការដ៏សំខាន់នេះ ជាពិសេសនៅប្រទេសកម្ពុជា ។ ខ្ញុំដឹងថាពេលខ្លះតុលាការនេះបានរងការរិះគន់ ប៉ុន្តែខ្ញុំជឿថា អ្វីដែលតុលាការកំពុងធ្វើពិតជាមានសារសំខាន់ខ្លាំងណាស់ ។

***តើក្នុងរយៈពេលប៉ុន្មានថ្ងៃនៅតុលាការនេះ មានពេលវេលាណាខ្លះដែលសំខាន់គួរឲ្យចាប់អារម្មណ៍សម្រាប់លោក?***

នៅពេលខ្ញុំផ្តល់សក្ខីកម្ម ខ្ញុំពិតជាចង់ផ្តល់នូវសក្ខីកម្មជំនាញ ដើម្បីឆ្លើយតបទៅនឹងសំណួរដែលព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីជនជាប់ចោទបានសួរ ។ ពេលជាមួយគ្នានោះ ខ្ញុំសង្ឃឹមថាខ្ញុំនឹងអាចនិយាយអំពីរឿងរ៉ាវដែលកើតឡើងនៅក្នុងភូមិ និងតំបន់ដែលខ្ញុំបានចុះស្រាវជ្រាវពីឆ្នាំ១៩៩៤ដល់១៩៩៥ ។ ភូមិនោះហៅថាភូមិពោធិ៍ នៅជិតវត្តភ្នំប្រុសភ្នំស្រី ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ខ្ញុំបានរស់នៅទីនោះរយៈពេលមួយឆ្នាំពី១៩៩៤ដល់១៩៩៥ ហើយទីបំផុត សៀវភៅដែលខ្ញុំ


សាស្ត្រាចារ្យ អាឡិចហ្សានដឺ ហ៊ិនតុន ផ្តល់សក្ខីនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី១៤-១៧ ខែមីនា ឆ្នាំ២០១៦

បានសរសេរ និងបានស្រាវជ្រាវ គឺដើម្បីស្វែងយល់អំពីបទពិសោធន៍នៃការរស់នៅឆ្លងកាត់របបខ្មែរក្រហម ។

នៅក្នុងតំបន់នេះ ជីវិតរស់នៅមានលក្ខណៈល្អប្រសើរ ប៉ុន្តែនៅឆ្នាំ១៩៧៧ នៅពេលដែលពួកកម្មាភិបាលភូមិភាគនិរតីមកដល់ គឺនៅចំណុចនោះហើយ និងក៏ដូចជានៅតាមតំបន់ជាច្រើនទៀតនៃប្រទេសកម្ពុជា ចាប់ផ្តើមកើតមានការកាប់សម្លាប់ និងកាន់តែខ្លាំងឡើងជាបន្តបន្ទាប់ ស្ថានភាពកាន់តែពិបាកឡើងៗ ។ ដូច្នេះ ខ្ញុំសង្ឃឹមថាទោះបីជាខ្ញុំបានឆ្លើយនឹងសំណួរក៏ដោយ ខ្ញុំក៏អាចនឹងបានផ្តល់ការយល់ដឹងអំពីជីវិតវេទនារបស់ប្រជាជននៅតំបន់នោះ នៅពេលខ្ញុំធ្វើសក្ខីកម្មបំភ្លឺ ។ និយាយអំពីពេលវេលាដែលចាំបាច់ នោះគឺជារឿងសំខាន់សម្រាប់ខ្ញុំ ។

ប្រហែលពេលដែលគួរឲ្យអស់សង្ឃឹមបំផុតនោះ គឺនៅពេលចាប់ផ្តើមដំបូង ពេលដែលខ្ញុំចង់និយាយស៊ីជម្រៅអំពីពាក្យប្រល័យពូជសាសន៍ដែលជានិច្ចជាកាលត្រូវបានយល់ច្រឡំ ។ ខ្ញុំចង់និយាយពីបញ្ហានេះនៅក្នុងតុលាការខ្លាំងណាស់ ។ ប៉ុន្តែតុលាការមាននិយមន័យជាក់លាក់មួយមកប្រើដោយចេញពីអនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីអំពើប្រល័យពូជសាសន៍ ហើយមេធាវីការពារចុងចោទបានឡើងតវ៉ាថាឲ្យខ្ញុំឆ្លើយតែសំណួរបានហើយ ។ អ៊ីចឹងពីដំបូង ខ្ញុំមានការខកចិត្តបន្តិច ព្រោះមិនអាចនិយាយពីរឿងនេះ ។ ប៉ុន្តែនៅក្នុងរយៈពេលបីថ្ងៃកន្លះនៃការធ្វើសក្ខីកម្មដ៏ខ្លាំងក្លានេះ ខ្ញុំអាចនិយាយអំពីអត្ថន័យនៃពាក្យប្រល័យពូជសាសន៍បានខ្លះ និងអំពីការជ្រាបចូលនៃអំពើប្រល័យពូជសាសន៍មកក្នុងប្រទេសកម្ពុជា ដែលមិនត្រឹមតែចូលក្នុងក្រុមការពារទាំងបួន គឺក្រុមពូជសាសន៍ ជាតិពន្ធុ ជាតិសាសន៍ និងក្រុមសាសនា ដែលចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិប៉ុណ្ណោះទេ ប៉ុន្តែ និយមន័យនេះអាចសំដៅដល់ក្រុមធំជាងនេះ ឧទាហរណ៍ដូចជា ជាតិពន្ធុចិនដែលរងការរំលោភបំពានដែលអាចកើតឡើងដោយវាយប្រហារផ្អែកលើកម្រិតថ្នាក់ ។ ប្រហែលជាការសម្លាប់មនុស្សនៅភូមិភាគបូព៌ា ។ ដូច្នេះ នៅខណៈពេលដំណើរការបណ្តឹងនេះបានលាតត្រដាង ខ្ញុំក៏បាននិយាយពិភាក្សាអំពីបញ្ហានេះ ។

ខ្ញុំគិតថាពេលវេលាមួយដែលលេចធ្លោនៅចុងបញ្ចប់នោះ គឺនៅពេលលោកនួន ជា ដែលជាជនជាប់ចោទមួយរូប ជាបងធំទីពីររបស់ខ្មែរក្រហម នៃរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពី ប៉ុល ពត បានចូលមកនិយាយក្នុងបន្ទប់សវនាការ ។ ខ្ញុំត្រេកអរដែលបានព្



រូបខាងឆ្វេង ៖ លោកសាស្ត្រាចារ្យ អាឡិចហ្សានដឺ ហ៊ីនតុន ចូលរួមវេទិកា “ស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍” នៅរដ្ឋធានីយ៉េរ៉េវ៉ាន់ ប្រទេសអាមេនី កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៦

ព្រោះសំឡេងរបស់គាត់បានបាត់ ។ ខ្ញុំជឿជាក់យ៉ាងខ្លាំងថាមេធាវីការពារជនជាប់ចោទគួរតែមានសំឡេងច្បាស់លាស់ ។ ពួកគេគួរតែបញ្ចេញសំឡេងតវ៉ារបស់ពួកគេឲ្យបានដឹងឮ ។ គាត់បានស្ងាត់ស្ងៀមមិននិយាយមួយរយៈហើយ ។ អ៊ីចឹង គាត់ក៏ឡើងមកក្នុងសវនការ ហើយខ្ញុំត្រេកអរដែរ ។ នោះហើយ ជាពេលវេលាមួយដែលខ្ញុំឲ្យតម្លៃបំផុត ។

***នួន ជា មានប្រតិកម្មយ៉ាងខ្លាំងចំពោះសកម្មភាពដែលលោកបានផ្តល់ទៅលើការប្រើពាក្យថាយួន ។ តើលោកគិតយ៉ាងណាចំពោះអ្វីដែលបានកើតឡើងនៅពេលនោះ?***

ខ្ញុំមិនអាចដឹងអំពីចិត្តរបស់គាត់ទេ ។ មានតែគាត់ទេដែលដឹងចិត្តខ្លួនឯង ។ ខ្ញុំគ្រាន់តែអាចឮពាក្យសម្តីរបស់គាត់ប៉ុណ្ណោះ ។ ដូច្នេះ នោះគឺជាមូលដ្ឋានដែលខ្ញុំត្រូវសន្និត ។ គាត់មិនបានសុំអភ័យទោសទេ ។ ហើយគាត់និយាយពន្យល់វិញ ។ គាត់គួរតែធ្វើអ៊ីចឹងហើយ ។ គាត់តំណាងឲ្យមេធាវីការពារជនជាប់ចោទ ដែលគួរតែមានសំឡេង ។ ពេលគឺការដែលគាត់ឡើងមកនិយាយ គឺជាការពិភាក្សាមួយដែលខ្ញុំកំពុងជជែកជាមួយក្រុមមេធាវីការពារចុងចោទ ដែលបានសួរថាតើការប្រើពាក្យយួននៅក្នុងបរិបទខ្មែរក្រហម ជាក់ស្តែងជាពាក្យបណ្តាលឲ្យមានការស្អប់ឬទេ ។ ខ្ញុំបានបង្ហាញដោយផ្អែកលើការចុះសិក្សារបស់ខ្ញុំ និងបទពិសោធន៍របស់អ្នកដែលនៅស្រុកកំពង់សៀមជាមួយនឹងចំណេះដឹងរបស់ខ្ញុំអំពីកម្ពុជា ដែលបានមកទីនេះជាច្រើនលើកច្រើនសា ក៏ដូចជាការស្រាវជ្រាវដែលខ្ញុំបានធ្វើ ។ ខ្ញុំបានលើកបញ្ជាក់យ៉ាងច្បាស់ថា ពេលខ្លះពាក្យយួនអាចប្រើក្នុងន័យដែលមិនមានបង្កប់ន័យញុះញង់ និងការស្អប់ ប៉ុន្តែជានិច្ចកាលវាអាចយកមកប្រើក្នុងពាក្យសម្តីមនោគមន៍ប្រើដោយអ្នកនយោបាយដើម្បីផ្សព្វផ្សាយជាសារនៃការស្អប់ ។

បើនិយាយនៅក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ សារនេះបង្កប់ន័យខ្លាំងបំផុត ។ វាមាននៅគ្រប់ទីកន្លែងនៅក្នុងការផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា ទាំងនៅក្នុងវិទ្យុ និងការបោះពុម្ពផ្សាយផ្សេងរបស់បក្ស ។ វាបង្ហាញច្បាស់ថាសារទាំងនេះគឺពន្យុះឲ្យមានអំពើប្រល័យពូជសាសន៍ ។ ខ្ញុំនិយាយពីចំណុចនេះ ហើយខ្ញុំយល់ចំពោះអ្នកការពារជនជាប់ចោទពួកគេត្រូវតែឆ្លើយតបនឹងញ្ហានេះ ។

ជាក់ស្តែង អ្វីដែលបានកើតឡើងគួរឲ្យចាប់អារម្មណ៍បំផុតនោះគឺ នួន ជា បានចេញមកអង្គុយលើកៅអីកង់ ហើយបាននិយាយស្រែកខ្លាំងៗ ។ គាត់ថា ប៉ុល ពត ប្រាប់ឲ្យប្រើពាក្យ (យួន) នោះ ។ ប៉ុន្តែគាត់និយាយថាវាមិនមានបង្កប់ន័យស្អប់នោះទេ ។ ដូច្នេះខ្ញុំគោរពអ្វីដែលគាត់បាននិយាយ ប៉ុន្តែខ្ញុំមិនយល់ស្របនោះទេ ។ ខ្ញុំមានឱកាសឆ្លើយតបទៅនឹងបញ្ហានេះ និងសំណួរផ្សេងទៀត ហើយខ្ញុំបាននិយាយថាអ្វីដែលសំខាន់ខ្លាំងនោះគឺយើងគិតពិចារណា និងពិភាក្សាអំពីការប្រើពាក្យដូចនេះនៅក្នុងសង្គម ។ ខ្ញុំសង្ឃឹមថាការពិភាក្សានោះអាចបើកឲ្យមានការពិភាក្សាមួយកាន់តែទូលាយថែមទៀតនៅក្នុងប្រទេសកម្ពុជា ។ ជាពិសេស អំពីអត្ថន័យនៃការប្រើពាក្យមួយ ការសន្មតជាតួយ៉ាង អារម្មណ៍ទឹងសម្បារ និងពេលខ្លះ ថែមទាំងមានការស្អប់ ដែលប្រដូចនឹងពាក្យនេះ ។ ដូច្នេះ ខ្ញុំត្រេកអរ ដែលគាត់បានលើករឿងនេះឡើង ទោះបីជាគាត់មិនយល់ស្របនឹងខ្ញុំក៏ដោយ ។ ប៉ុន្តែ វាច្បាស់ណាស់ ដូចដែលខ្ញុំបាននិយាយពេលចុងបញ្ចប់ជាមួយគាត់ គឺការប្រើពាក្យយួននៅក្នុងបរិបទរបស់កម្ពុជាប្រជាធិបតេយ្យ គឺជាការញុះញង់ឲ្យកើតអំពើប្រល័យពូជសាសន៍លើក្រុមជនជាតិវៀតណាមយ៉ាងច្បាស់ណាស់ ។

***តើលោកយល់យ៉ាងណាចំពោះក្រុមមេធាវីការពារក្តីរបស់ នួន ជា ដែលដឹកនាំដោយលោក វិចទ័រ កុបេ? ប្រសិនបើប្រៀបធៀបទៅនឹងក្រុមមេធាវីការពារក្តី ខៀវ សំផន តើមានភាពយុត្តិធម៌ត្រឹមត្រូវឬទេ នៅពេលពួកគេចោទសួរលោក?***

ក្រុមការពារចុងចោទស្ថិតក្នុងតួនាទីលំបាកមួយ ។ មានភ័ស្តុតាងច្រើនសន្ធឹកសន្ធាប់ណាស់ ប្រឆាំងនឹងកូនក្តីរបស់ពួកគេ ។ ពួកគេយល់ថាសំឡេងរបស់ពួកគេមិនត្រូវបានគេយកចិត្តទុកដាក់គ្រប់គ្រាន់ ។ ដូច្នេះ ខ្ញុំយល់ថាក្នុងនាមជាមេធាវីការពារជនជាប់ចោទ អ្នកត្រូវខំឲ្យអស់លទ្ធភាពដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ ។

មេធាវីខ្លះប្រើវិធីកាត់បន្ទាក់ ។ (មេធាវីបារាំងដែលបានស្លាប់នោះ) ហ្សាក់ វែរហ្សេ ជាមេធាវីតំណាងឲ្យ ខៀវ សំផន ពីដំបូងនោះ គឺជាអ្នកនាំប្រើវិធីបន្ទាក់នេះមុនគេ ។ ពួកគេនឹងរកវិធីបន្ទាក់ និងសួរពីនីតិវិធីច្បាប់គ្រប់ពេលបណ្តឹងសវនាការ ។ នេះជាយុទ្ធសាស្ត្រទូទៅមួយ ។ ជាប្រភេទយុទ្ធសាស្ត្រកាត់បន្ទាក់ក្នុងផ្លូវច្បាប់ ។ មេធាវីផ្សេងទៀត ប្រកាន់តាមច្បាប់បទវិធាន និងជំទាស់តវ៉ាក្តីតាមវិធីនោះ ។ ដូច្នេះ ក្រុមមេធាវីទាំងពីរនេះមានយុទ្ធសាស្ត្រ

ខុសគ្នា ។

ខ្ញុំគិតថាវិធីសាស្ត្ររបស់លោក កុបប៉េ ជាវិធីកាត់បន្ថក់ខ្លាំង ។ គាត់ប្រហែលជាព្យាយាមក្រឡុកអ្នកកំពុងផ្តល់សក្ខីកម្ម ប្រសិនបើសក្ខីកម្មនោះបង្ហាញថាមានជាប់ខក្រិដ្ឋ ហើយខ្ញុំគិតថាសក្ខីកម្មដែលខ្ញុំបានផ្តល់ពាក់ព័ន្ធនឹងការសម្លាប់ជនជាតិចាម និងវៀតណាម នៅតំបន់៤១ នៃភូមិភាគកណ្តាលនោះ គឺបញ្ជាក់ពីបទឧក្រិដ្ឋ ។ ដូច្នេះ ទោះបីជាគាត់ព្យាយាមវាយប្រហារលើការអះអាងរបស់ខ្ញុំតាមវិធីផ្សេងៗក៏ដោយ នោះគឺជាអ្វីដែលគាត់គួរតែធ្វើ ។ ខ្ញុំនឹងទុកឲ្យអ្នកផ្សេងជាអ្នកកាត់ក្តីចុះ ទោះជាពេលខ្លះគាត់ដូចជាជ្រុលបន្តិច ប៉ុន្តែដូចនិយាយអីចឹង ខ្ញុំគោរពនូវអ្វីដែលគាត់ព្យាយាមធ្វើដើម្បីការពារកូនក្តីរបស់គាត់ ។ គាត់គួរតែបំពេញតួនាទីរបស់គាត់ឲ្យអស់ពីលទ្ធភាព ។

ក្រុមមេធាវីការពារ ខៀវ សំផន ក៏ដូចគ្នាដែរ ។ ពួកគេត្រូវការខ្លាំង ។ ទោះបីជាខ្ញុំមានទំនុកចិត្តចំពោះសក្ខីកម្មរបស់ខ្ញុំដែលកើតឡើងក្នុងពេលដំណើរការក្តី បានបង្ហាញច្បាស់យ៉ាងណាក៏ដោយ ឧទាហរណ៍ដូចជាការប្រើពាក្យឃួន ក្នុងន័យបណ្តាលឲ្យស្អប់ និងមានអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម ក៏ខ្ញុំគិតថាពួកគេត្រូវមានសំឡេង មានសិទ្ធិការពារចុងចោទ ។ ហើយពួកគេគួរតែធ្វើដូច្នេះឲ្យអស់ពីលទ្ធភាពរបស់គេ ។

***លោកបាននិយាយអំពីឈ្មោះយាយ យុត ជាច្រើនដងនៅក្នុងការផ្តល់សក្ខីកម្មរបស់លោក ។ តើគាត់មានពាក់ព័ន្ធអីនឹងករណីប្រល័យពូជសាសន៍នេះ?***

នៅអំឡុងពេលនោះ កន្លែងសម្លាប់បានបង្កើតឡើងនៅវត្តភ្នំប្រុសភ្នំស្រី ដែលជាវត្តល្បីមួយនៅក្នុងខេត្តកំពង់ចាម ហើយពួកគេបានកែប្រែទៅជាមន្ទីរសន្តិសុខដែលមានមនុស្សជាង១០,០០០ ប្រហែលជាជាង១២,០០០នាក់ ត្រូវគេសម្លាប់ ។ មនុស្សជាច្រើនបានស្លាប់នៅទីនោះ ។ មានកន្លែងផ្សេងទៀតដែរ ដូចជានៅទួលវែង ។

ប៉ុន្តែនៅឆ្នាំ១៩៧៧ ក្រោយពី កុយ ធួន និងបក្ខពួកត្រូវបានសម្លាប់នោះ សោកនាដកម្មក៏បានមកដល់កំពង់សៀម ។ កម្មាភិបាលក្នុងស្រុក ត្រូវបានចោទថាជាប់ពាក់ព័ន្ធនឹង កុយ ធួន និងខ្សែរបស់គាត់ ហើយត្រូវជំនួសដោយពួកកម្មាភិបាលមកពីនិរតី ។ មនុស្សជាច្រើនប្រាប់ខ្ញុំថា យាយ យុត មកពីនិរតី ។ គាត់ក្លាយជាគណៈស្រុក ។ មានស្ត្រីម្នាក់នៅក្រោមគាត់ ឈ្មោះ រ៉ុម ដែលជាគណៈឃុំក្រឡា ហើយខ្ញុំបានឮរឿងរ៉ាវជាច្រើនអំពីពួកគាត់ ។ មានរឿងមួយនោះ គឺថា យាយយុត កាចសាហាវណាស់ រហូតដល់សុខចិត្តសម្លាប់ប្តីរបស់គាត់ ដើម្បីបង្ហាញថាគាត់លះបង់អ្វីៗទាំងអស់ដើម្បីបក្ស ។

ខ្ញុំគួរបញ្ជាក់ថា ពួកគេពីរនាក់ជាប់ពាក់ព័ន្ធនឹងកម្មាភិបាលផ្សេងៗមកពីខាងនិរតី ប៉ុន្តែ ដោយឡែក តា អាន (ជនជាប់សង្ស័យក្នុងករណី០០៣) ក៏នៅទីនោះដែរ ។ គាត់គឺជាអ្នកមើលការខុសត្រូវពីលើយាយ យុត ។ ប៉ុន្តែ មានសោកនាដកម្មជាច្រើនបានកើតឡើងនៅក្រោមការគ្រប់គ្រងរបស់យាយ យុត រួមមានទាំងការសម្លាប់ មិនមែនតែជនជាតិភាគតិចចាមដែលត្រូវបានសម្លាប់អស់យ៉ាងច្រើននៅស្រុកកំពង់សៀមនោះទេ ប៉ុន្តែ មាន "ប្រជាជនថ្មី" និស្សិត អ្នកប្រាជ្ញ អ្នកមកពីទីក្រុងដែលពួកខ្មែរក្រហមយល់ថាជាពួកមាននិន្នាការមូលធននិយម ឬកម្មសិទ្ធិសួនតួ មានគំនិតប្រឆាំងបដិវត្តន៍ ។ នៅរយៈកាលនេះ ខ្មែរក្រហមគិតថាប្រជាជនប្រហែលជាអាចដុសខាត់ស្មារតីរបស់ខ្លួន ប្រើប្រយោគរបស់ពួកគេ និងបន្សុទ្ធខ្លួនឯងពីអ្វីដែលពួកគេហៅថា "ធាតុមិនស្អាតស្អំ" ។ ប៉ុន្តែ នៅចុងឆ្នាំ១៩៧៦ និងជាពិសេសនៅក្នុងឆ្នាំ១៩៧៧ ប្រជាជនទាំងនេះត្រូវបានជាប់សង្ស័យកាន់តែខ្លាំងឡើងៗ ហើយយើងបានឃើញរឿងអាក្រក់កើតឡើងនៅកំពង់ចាមដែលកើតមានការសម្លាប់រង្គាល ។

ខ្ញុំបាននិយាយអំពីយាយ យុត ច្រើនដង ដោយសារគាត់ជាតំណាងដែលអ្នកនៅក្នុងតំបន់នោះស្គាល់ គឺគាត់ និងកម្មាភិបាលផ្សេងទៀតដូចជា រ៉ុម ត្រូវបានស្គាល់ថាកាចសាហាវ ហើយប្រជាជនមានការភ័យខ្លាច ។ ខ្ញុំមិនអាចប្រាប់អ្នកឲ្យចំបានទេនូវអ្វីដែលបានកើតឡើងនៅក្នុងមន្ទីរសន្តិសុខរបស់យាយ យុត ។ ប៉ុន្តែខ្ញុំអាចប្រាប់បានថា រឿងទាំងនោះក៏ជាតំណាងនៃពេលដ៏រន្ធត់ក្នុងជីវិតរបស់ប្រជាជននៅពេលដែលសេចក្តីភ័យខ្លាចរបស់ពួកគេកើនឡើងយ៉ាងខ្លាំងនោះ ជីវិតក៏កាន់តែលំបាកខ្លាំងដែរ ។ ប្រជាជនជាច្រើនបាត់បង់មនុស្សជាទីស្រឡាញ់ និងការសម្លាប់រង្គាល ដែលជាទ្រង់ទ្រាយដ៏ធំមួយនៅក្នុងដំណើរការប្រល័យពូជសាសន៍នៅកម្ពុជា ។

***នៅអំឡុងពេលធ្វើសក្ខីកម្មនោះ លោកបាននិយាយអំពីប្រលោមលោកសម័យខ្មែរក្រហម ដាំ ផេង ។ តើលោកអាចពន្យល់បានទេថាហេតុអ្វី?***

រឿងដាំ ផេង នេះ មាននិយាយនៅក្នុងទស្សនាវដ្តីខ្មែរក្រហម

យុវជនបដិវត្តន៍ ។ មានសំណៅមួយបោះពុម្ពនៅឆ្នាំ១៩៧៣ ប៉ុន្តែរឿងនោះគេគិតថាជារឿងជំរុញបំផុសទឹកចិត្ត ឧទាហរណ៍ការសម្តែងផ្សេងៗដែលធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនបាននិយាយអំពីការចងចាំរបស់គេចំពោះរឿងនេះ ។ ខ្ញុំជឿថាលោក ឆាំង យុ ជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏មានកំណត់ត្រាដែរដោយសារគាត់បាននិយាយពីរឿងនេះ ។

វាគឺជារឿងព្រេងនិយាយអំពីយុវជនខ្មែរដែលកើតចេញពីគ្រួសារក្រីក្រមួយនៅជនបទ បានទៅរៀននៅភ្នំពេញ និងទីបំផុតបានជាប់ជំពាក់នឹងសាររបស់ខ្មែរក្រហម ។ សាររបស់ពួកគេ ស្តីអំពីការគាបសង្កត់លើវណ្ណៈ នៅពេលសង្គ្រាមកំពុងកើតឡើងនៅប្រទេសជាប់គ្នានោះ គឺវៀតណាមដែលបានលាន់ខ្ទរដល់កម្ពុជាដែរ ។ ដូច្នេះរឿង ដាំ ដេង និយាយអំពីការចាប់ផ្តើមធ្វើបដិវត្តន៍របស់ដាំ ដេង ដើម្បីប្រយុទ្ធប្រឆាំងនឹងចក្រពត្តិអាមេរិក ប្រឆាំងនឹងការគាបសង្កត់លើវណ្ណៈ ហើយនៅក្នុងរឿងនេះដាំ ដេង បានសង្ខេបអំពីគុណសម្បត្តិរបស់បដិវត្តន៍ដ៏ល្អ ដែលមានមនសិការបរិសុទ្ធស្អាតស្អំ ដែលត្រៀមប្រយុទ្ធដោយឥតស្ទាក់ស្ទើរ ។ ខ្ញុំមិនចាំថារឿងនោះចប់ឆ្នាំណាទេ នៅវង្វង់ចុងទសវត្សឆ្នាំ៦០ ដាំ ដេង ត្រូវចាប់ខ្លួន រងការធ្វើទារុណកម្ម ប៉ុន្តែទោះយ៉ាងណាក៏គាត់មិនព្រមចុះចាញ់ មិននិយាយពីបក្ខពួករបស់គាត់ ហើយនៅទីបញ្ចប់ ក្រោយពីត្រូវរងទារុណកម្ម គាត់បានសរសេរកំណាព្យមួយដោយឈាមរបស់គាត់នៅលើជញ្ជាំងគុកនោះ មុនពេលគាត់ស្លាប់ ។

ដូចខ្ញុំបាននិយាយអីចឹង រឿងនេះប្រហែលជារឿងល្បីមួយដែលប្រើជាសារមនោគមវិជ្ជារបស់ខ្មែរក្រហមសម្រាប់ជួយដល់ការឃោសនា ។ ប៉ុន្តែ ខ្ញុំនិយាយជាមួយមនុស្សម្នាក់ដែលនិយាយថាដាំ ដេង គឺជាមនុស្សពិត ។ ខ្ញុំជឿថារឿងនេះ ត្រូវបានលើកឡើងនៅអំឡុងពេលសវនាការរបស់ ឌុច (ករណី០០១) ហើយថាមានតួអង្គឆ្នើម និងអ្នកនិពន្ធនោះគឺប្រហែល នួន ជា ឬ ប៉ុល ពត ដែលបានសរសេររឿងនេះដាក់ក្នុងទស្សនាវដ្តី ។ យើងមិនដឹងទេ ។ ប្រហែលជាថ្ងៃណាមួយ នួន ជា អាចបញ្ជាក់ប្រាប់បាន ។ ខ្ញុំសង្ស័យថាគាត់ធ្វើដូច្នេះ ប៉ុន្តែ យើងមិនដឹងទេ ។ ប៉ុន្តែដាំ ដេង គឺជាតួអង្គមួយ តំណាងឲ្យ និងបង្រៀនយើងច្រើនអំពីផ្នត់គំនិតរបស់ខ្មែរក្រហម ។

**តើកាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលត្រូវកាត់ទោសក្នុងករណី០០១របស់តុលាការនេះ មានអ្វីជាប់ពាក់ព័ន្ធនឹងករណី០០២?**

ឌុច បានផ្តល់ភ័ស្តុតាងយ៉ាងច្រើន ដែលបង្ហាញថា នួន ជា ជាប់ឧក្រិដ្ឋ ដោយសារ ឌុច ដាក់ នួន ជា ឲ្យគ្រប់គ្រងផ្ទាល់លើស-២១ ក្រោយពី សុន សេន ទៅវាយជាមួយវៀតណាម នៅពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ ។ សក្ខីកម្មដំបូងរបស់ ឌុច ទៅលើបញ្ហានេះ ត្រូវវាយប្រហារដោយពួកមេធាវីការពារជនជាប់ចោទគឺពួកគេគ្រាន់ធ្វើតាមតួនាទីរបស់គេ ។ នោះជាអ្វីដែលពួកគេគួរធ្វើ ។ ប៉ុន្តែ ប្រសិនបើរឿងនោះបង្ហាញឲ្យឃើញដូចអ្វីដែលទំនងជាមែននោះ វាមិនល្អទាល់តែសោះ ចំពោះករណីមេធាវីការពារ នួន ជា ពីព្រោះវានាំឲ្យ នួន ជា ជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងអំពើហិង្សា ការសម្លាប់ និងទារុណកម្ម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងថែមទាំងឧក្រិដ្ឋកម្មសង្គ្រាមដែលកើតឡើងនៅស-២១ ។ ដូច្នេះ ឌុច ជាមនុស្សម្នាក់ដែលខ្ញុំគិតថាអាចនឹងមកបំភ្លឺម្តងទៀត និងផ្តល់ភ័ស្តុតាងដាក់បន្ទុកខ្លាំងប្រឆាំងនឹង នួន ជា ជាអ្នកដែលគាត់ឆ្លើយឆ្លងជាមួយញឹកញាប់ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ។

**ហេតុអ្វីបានជានៅតុលាការ លោកធ្វើសម្បថសច្ចាប្រណិធានតាមព្រះពុទ្ធសាសនា?**

ក្នុងនាមជាអ្នកនរវិទូម្នាក់ និងជាអ្នកទេសចរណ៍នៅកម្ពុជា ខ្ញុំចង់ផ្តល់កិត្តិយស និងគោរពចំពោះប្រពៃណីរបស់កម្ពុជា ហើយនៅខាងកម្ពុជានៅក្នុងតុលាការនេះ ប្រជាជនផ្តល់ការគោរពធ្វើសម្បថនៅមុខលោកតាដំបងដែក ហើយខ្ញុំគិតថាវាសំខាន់ក្នុងការគោរពតាមប្រពៃណីដែលមាននៅក្នុងប្រទេសនេះ ។ តាមពិត ខ្ញុំគិតថាវាអាចជារឿងល្អ ប្រសិនបើមនុស្សគ្រប់គ្នាត្រូវស្បថចំពោះអ្នកតា ។ វាជាសម្បថដ៏ខ្លាំងមួយ ។ ប្រហែលជាមនុស្សខ្លាចនឹងស្បថសច្ចាប្រណិធានមុខអ្នកតា ។ ប៉ុន្តែខ្ញុំត្រេកអរដែលបានស្បថដូច្នេះ ហើយខ្ញុំបានគិតពីអ្នកតា នៅពេលខ្ញុំធ្វើសក្ខីកម្ម ។ ខ្ញុំបានធ្វើអស់ពីសមត្ថភាពរក្សាសម្បថដែលខ្ញុំបានស្បថចំពោះគាត់ និងនៅក្នុងតុលាការផងដែរ ។

**តើលោកគិតថានៅពេលអនាគត តុលាការព្រហ្មទណ្ឌអន្តរការសហប្រជាជាតិ គួរតែមានដើមបណ្តឹងរដ្ឋប្បវេណី ដូចតុលាការខ្មែរក្រហមនេះដែរឬទេ?**

តុលាការនេះវិសេសណាស់ដែលមានដើមបណ្តឹងរដ្ឋប្បវេណីជាតំណាងឲ្យមានសំឡេងប្រជាជនចូល ។ មាននៅក្នុងសវនាការរបស់

ខុច និងថែមទាំងមុននឹងសំណុំរឿងក្តីចាប់ផ្តើម និងអង្គជំនុំជម្រះសាលាដំបូង ។ មានការពិភាក្សាខ្លះៗអំពីថាតើវាមានន័យអ្វីខ្លះចំពោះជនរងគ្រោះដែលត្រូវមានសំឡេង និងបញ្ចេញសំឡេងនៅក្នុងតុលាការ ។ ឧទាហរណ៍ ថាតើដើមបណ្តឹងរដ្ឋប្បវេណីម្នាក់អាចឡើងសួរសំណួរទៅជនសង្ស័យបាន ឬធ្វើបណ្តឹងដោយខ្លួនឯង ។

ដោយសារតែមានភាពស្មុគស្មាញខ្លាំង និងមានដើមបណ្តឹងរដ្ឋប្បវេណីច្រើន ក៏ក្លាយជាប្រព័ន្ធចូលគ្នាមួយដែលដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវី និងមានសហមេធាវីនាំមុខ ។ ខ្ញុំយល់រឿងនេះ ។ ម្យ៉ាងវិញទៀត ដើម្បីឲ្យដំណើរការល្អ ចាំបាច់ត្រូវមានរចនាសម្ព័ន្ធបែបនេះ ។ ប៉ុន្តែក៏មានបញ្ហាដែរ ដោយសារតែសំឡេងរបស់ជនរងគ្រោះត្រូវបានរុញទុកឆ្ងាយ ។ នៅពេលខ្ញុំនៅក្នុងបន្ទប់សវនាការ ខ្ញុំសម្លឹងមើលទៅដើមបណ្តឹងរដ្ឋប្បវេណីអង្គុយនៅក្នុងបន្ទប់ នៅមុខបន្ទប់អូឌីយ៉ូវីដេអូ ប៉ុន្តែពួកគេមិនបាននិយាយអ្វីទាំងអស់ ។

ខ្ញុំចង់បញ្ជាក់ថាដើមបណ្តឹងរដ្ឋប្បវេណីពិតជានិយាយនៅតុលាការ ។ វាសំខាន់ក្នុងការដែលត្រូវដឹង និងទទួលស្គាល់ ។ ពួកគេត្រូវបានអនុញ្ញាតឲ្យនិយាយប្រាប់រឿងរបស់ពួកគេ ។ មិនមែនបាននិយាយគ្រប់គ្នាទេ ប៉ុន្តែ មានអ្នកបាននិយាយមួយចំនួនខ្លះដែរ ។ ប៉ុន្តែ ប្រសិនបើអ្នកប្រៀបធៀបតុលាការនេះ ទៅនឹងតុលាការផ្សេងដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅអតីតប្រទេស យូហ្គោស្លាវី និងរ៉្វាន់ដា ។ ខ្ញុំគិតថាការសំខាន់គឺមើលត្រឡប់ទៅក្រោយ និងគិតពីវិធីដែលយើងអាចពង្រឹងសំឡេងរបស់ជនរងគ្រោះឲ្យកាន់តែខ្លាំង ។

***តើលោកយល់ថាមេធាវីបរទេសនៅតុលាការនោះ មានការយល់ដឹងអំពីវប្បធម៌របស់អ្នករងគ្រោះឬទេ?***

ខ្ញុំគិតថាមិនអាចនិយាយជារួមទូទៅបានទេ ។ ខ្ញុំសង្ឃឹមថាមេធាវីទាំងអស់គោរពចំពោះប្រពៃណីខ្មែរ ទំនៀមទម្លាប់ខ្មែរ ។ ជាពិសេស នៅប្រទេសកម្ពុជា ប្រសិនបើអ្នកមិននិយាយភាសាខ្មែរ វាកាន់តែពិបាក ។ អ្នកមិនសូវយល់ពីរឿងដែលកើតឡើងជុំវិញខ្លួនអ្នកនោះទេ ។ ប្រហែលជាតុលាការកូនកាត់អន្តរជាតិទាំងអស់ គួរតែមានឧទាហរណ៍ដូចជា ការបណ្តុះបណ្តាលអំពីវប្បធម៌ដែលធ្វើឡើង ។ ខ្ញុំគិតថា អាចជារឿងល្អចំពោះគ្រប់គ្នា ។ នេះអាចជាមេរៀនមួយពីតុលាការដែលនៅពេលអនាគតតុលាការផ្សេងៗប្រហែលជាអាចធ្វើដូច្នេះ ។

ទាក់ទងនឹងរឿងនេះ ខ្ញុំបាននិយាយជាមួយបុគ្គលិកអន្តរជាតិជាច្រើននៅតុលាការ ដែលយល់ដឹងអំពីវប្បធម៌ និងចង់ធ្វើតាមការយល់ឃើញបែបរបស់អ្នកស្រុក ជំនឿក្នុងស្រុក ។ មានអ្នកធ្វើដូច្នេះ ។ ចំពោះអ្នកទាំងនោះ ខ្ញុំសង្ឃឹមថាពួកគេនឹងព្យាយាមធ្វើការកែលម្អការប្រតិបត្តិរបស់ពួកគេ ។ ប៉ុន្តែគ្មានកន្លែងណាដែលមានភាពល្អឥតខ្ចោះនៅក្នុងន័យនេះនោះទេ ប៉ុន្តែមានប្រហែលអាចជាមេរៀនដែលត្រូវរៀន ។

*លោកសាស្ត្រាចារ្យ អាឡិចហ្សាន់ដឺ ហ៊ីនតុន (Alexander Hinton) បានសន្ទនាជាមួយកញ្ញា សើ សាយ្យាណា នៃវិទ្យុ វី.អូ.អេ ខ្មែរ អំពីការប្រឈមរបស់លោកជាមួយនឹង “បងធំទី២” នួន ជា នៅក្នុងសាលសវនាការ ពីថ្ងៃទី១៤-១៧ ខែមីនា ឆ្នាំ២០១៦ ។*

# ដំណឹងស្វែងរកប្អូនស្រី

ខ្ញុំបាទឈ្មោះ ហង់ ខេត ភេទប្រុស អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ សូមប្រកាសរកឈ្មោះ ហង់ សាម៉ូត ភេទស្រី ត្រូវជាប្អូនស្រីពៅ (បច្ចុប្បន្ន អាយុប្រហែល៥៤-៥៥ឆ្នាំ) មានស្រុកកំណើតនៅភូមិត្រពាំងអណ្តើក ឃុំបឹងស្រង៉ែ ស្រុកត្រាំកក់ ខេត្តតាកែវ ។ កាលពីសម័យខ្មែរក្រហម សាម៉ូត ធ្វើជាកងនារីតំបន់ ស្រុកត្រាំកក់ មានឪពុកឈ្មោះ ជ័យ ឃុន និងម្តាយ ឈឹម ណេង ។ មានបងប្អូនបង្កើត៧នាក់ (ប្រុស២ ស្រី៥នាក់) ។

បើបងប្អូនណាបានដឹងសូមទាក់ទងមកភូមិជ្រៃ ទូរស័ព្ទលេខ ០៩៧ ៣ ១៧៤ ៩៦៧ ឬ ទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣២១១៨៧៥ ។

**សូមអរគុណ!**

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ៖ ការទទួលបានមកវិញនូវប្រវត្តិសាស្ត្រអន្លង់វែង

## សេចក្តីផ្តើម

កិច្ចពិភាក្សាអន្តរជំនាន់ជាចំណុចសំខាន់សម្រាប់សិស្ស-និស្សិតចូលរួមនៃកម្មវិធីសន្តិភាពអន្លង់វែងជាលើកទី២ ចាប់ផ្តើមពីថ្ងៃទី០៨-១០ ខែមីនា ឆ្នាំ២០១៦ ។ ពីប្រធានបទនៃកិច្ចពិភាក្សាជាច្រើន អ្នកចូលរួមក្នុងកម្មវិធីសន្តិភាពអន្លង់វែងនេះ ដែលជាសិស្សនិស្សិតនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាល័យអន្លង់វែង យល់ឃើញថា ខ្លួនមានការចាប់អារម្មណ៍ក្នុងការផ្តើបទបង្ហាញទៅលើគម្រោង និងការរៀបចំដែលបង្កើតឲ្យមានកិច្ចពិភាក្សាប្រកបដោយការស្តាបនា ។ ការផ្លាស់ប្តូរយោបល់ទៅលើប្រធានបទនីមួយៗ បានធ្វើឲ្យសិស្ស-និស្សិតដែលបានចូលរួមកាន់តែចង់ដឹងពីដំណើរជីវិតរបស់អ្នកដែលបានចូលបម្រើចលនាខ្មែរក្រហម ។ ប៉ុន្តែប្រធានបទនេះក៏ត្រូវតែធ្វើឲ្យកាន់តែមានសារសំខាន់ថែមទៀតទៅលើទស្សនៈពីមុនថា អតីតសមាជិកខ្មែរក្រហមប្រហែលជាមិនសហការទេ ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីបានចំណាយពេលពេញមួយរសៀលដើម្បីផ្សារភ្ជាប់ខ្លួនទៅក្នុងកិច្ចសន្ទនាជាមួយអ្នកភូមិ សិស្សនិស្សិតបានស្នើថា ពេលវេលាបន្ថែមគួរតែបានត្រៀមទុកសម្រាប់កិច្ចពិភាក្សាផ្លាស់ប្តូរយោបល់បែបនេះ ។ សិស្ស-និស្សិតក៏បានស្វែងយល់បន្ថែមពីអ្នកភូមិ ដែលធ្វើឲ្យពួកគេមានការយល់ដឹងកាន់តែច្បាស់លាស់ពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ដោយឡែក សិស្ស-និស្សិតកាន់តែមានចាប់អារម្មណ៍ និងភ្ញាក់ផ្អើលជាមួយស្មារតីជាតិនិយម កើតចេញពីទឹកចិត្ត និងឆន្ទៈរបស់អតីតសមាជិកខ្មែរក្រហម បន្ទាប់ពីស្តាប់ពីរឿងរ៉ាវជីវិតរបស់ពួកគេ ។


សិស្ស-និស្សិត ធ្វើទស្សនកិច្ចសិក្សា នៅចេតិយរបស់ តាម៉ុក ស្ថិតនៅវត្តស្រះឈូក ភូមិស្រះឈូក ឃុំត្រពាំងប្រិយ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

របាយការណ៍នេះនឹងលើកឡើងដោយសង្ខេបពីការធ្វើបទបង្ហាញ គឺ ១) ការយល់ដឹងជាមូលដ្ឋានអំពីសន្តិភាព ជម្លោះ អំពើហិង្សា និងការផ្សះផ្សា ផ្សារភ្ជាប់ជាមួយនឹងប្រវត្តិសាស្ត្រនៃសហគមន៍អន្លង់វែង ២) របៀបធ្វើបទសម្ភាសន៍ និង ៣) របៀបសរសេរអត្ថបទចេញពីបទសម្ភាសន៍ ។ ទាំងអស់នេះគឺជាការវាស់ស្ទង់នូវអ្វីដែលសិស្សនិស្សិត បានរៀនសូត្រពីកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយអ្នកភូមិអន្លង់វែង ក៏ដូចជាអ្វីដែលសិស្សនិស្សិតបានដឹង និងចាប់អារម្មណ៍បំផុតតាមរយៈដំណើរទស្សនកិច្ចសិក្សានេះ ។ របាយការណ៍នេះក៏នឹងពិភាក្សាពីបញ្ហាមួយចំនួនដែលយើងកំពុងប្រឈមក្នុងអំឡុងពេលដំណើរទស្សនកិច្ច ។ ប្រតិកម្មជារួមទៅលើកម្មវិធីដំណើរទស្សនកិច្ចសិក្សាសន្តិភាពទៅកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែងនេះ និងត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះផងដែរ ។

កម្មវិធីដំណើរទស្សនកិច្ចសិក្សាសន្តិភាពទៅកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង បានចាប់ផ្តើមនៅថ្ងៃទីពីរ គឺថ្ងៃទី៩ ខែមីនា ឆ្នាំ ២០១៦ បន្ទាប់ពីបានចំណាយពេលថ្ងៃដំបូងរបស់ខ្លួន ធ្វើដំណើរពីទីក្រុងភ្នំពេញទៅកាន់ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ នៅថ្ងៃទីពីរនៃកម្មវិធីនេះត្រូវបានផ្តល់ជាមួយការធ្វើបទបង្ហាញដោយវាគ្មិនចំនួនពីររូប ដែលមកពីសហគមន៍អន្លង់វែង ។ គោលបំណងនៃការធ្វើបទបង្ហាញទាំងនេះគឺដើម្បីផ្តល់ឲ្យសិស្ស-និស្សិតដែលបានចូលរួមនូវៈ ១) ចំណេះដឹងមូលដ្ឋាននៃប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង, ២) ផ្តល់នូវគុណប្រយោជន៍ចំពោះអ្នកស្តាប់ ក្នុងអំឡុងពេលជួបផ្ទាល់ជាមួយអ្នកភូមិអន្លង់វែង, ៣) ការយល់ដឹងជាមូលដ្ឋាននៃសន្តិភាព, ជម្លោះ, អំពើហិង្សា និងការផ្សះផ្សា, ៤) របៀបធ្វើបទសម្ភាសន៍ និងសរសេរអត្ថបទចេញពីបទសម្ភាសន៍ ។

## ការស្តាប់រឿងរ៉ាវជីវិតរបស់វាគ្មិនពីររូប

នៅថ្ងៃដដែល វាគ្មិនពីររូប ឈ្មោះ ចក់ រ័ត្ន (ស្រី) និងឈ្មោះ នុប ភិន (ប្រុស) ត្រូវបានអញ្ជើញឲ្យចូលរួមដើម្បីចែករំលែកជាមួយសិស្ស-និស្សិតនូវបទពិសោធន៍ជីវិតរបស់ខ្លួននៅក្នុងរយៈកាលរបបខ្មែរក្រហម ចាប់តាំងពីថ្ងៃចូលរួមរបស់ខ្លួននៅក្នុងចលនាខ្មែរក្រហមដំបូង រហូតដល់សង្គ្រាមស៊ីវិលឆ្នាំ១៩៧៩-១៩៩៨ ។ ខាងក្រោមនេះជាសេចក្តីដកស្រង់ៈ

នៅពេលព្រឹក វាគ្មិន ចក់ រ័ត្ន អាយុ៥៩ឆ្នាំ ជាប្រជាជនរស់នៅក្នុងសហគមន៍អន្លង់វែង បានរៀបរាប់ថាៈ

ខ្ញុំបានចូលបដិវត្តន៍នៅស្រុកទ្រាំង ខេត្តតាកែវ ។ នៅពេលនោះខ្ញុំគ្មានជម្រើសអ្វីក្រៅពីចូលរួមជាមួយចលនាខ្មែរក្រហមនោះទេ ។ មុនឆ្នាំ១៩៧៥ ខ្ញុំបានរស់នៅជាមួយឪពុកម្តាយរបស់ខ្ញុំ ។ ខ្ញុំមិនបាន



សិស្ស-និស្សិត ធ្វើទស្សនកិច្ចសិក្សានៅផ្ទះរបស់ ប៉ុល ពត ស្ថិតនៅលើភ្នំដងរែក ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

រៀនសូត្រទេ គឺផ្ដោតតែទៅលើការងារកសិកម្ម ។ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យធ្វើជី ហើយបន្ទាប់មកឲ្យទៅលើកទំនប់, ជីកប្រឡាយ និងហូបរួម ។ នៅពេលវៀតណាមបើកការវាយប្រហារលើខ្មែរក្រហម ខ្ញុំត្រូវបានបញ្ជូនទៅអន្លង់វែង កាត់តាមកោះកុង និងភ្នំក្រវាញ ។ នៅតាមផ្លូវ ខ្ញុំឆ្លងកាត់ការវាយប្រហារដោយអាវុធជាច្រើនលើក ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនដែលទទួលរងការធ្វើទារុណកម្មនៅក្នុងរបបខ្មែរក្រហមបានទេ ។ យាយ ចា ជាមេកងរបស់ខ្ញុំ បានប្រាប់ថា ប្រជាជននៅវៀតណាមបានចូលមកក្នុងប្រទេសកម្ពុជា ។ នៅពេលនោះ មានមនុស្សជាច្រើន ហើយតួនាទីរបស់ខ្ញុំគឺដឹកអង្ករពីប្រទេសថៃមក ។ ខ្ញុំអាចបរិភោគជាលក្ខណៈឯកជននៅផ្ទះបាន ។ ក្នុងឆ្នាំ១៩៨២-៨៣ ខ្ញុំបានរត់ភៀសខ្លួនទៅប្រទេសថៃ បន្ទាប់ពីភូមិរបស់ខ្ញុំត្រូវបានវាយប្រហារ ។ សម្រាប់ឥរិយាបថរបស់សមាជិកខ្មែរក្រហមជាទូទៅ ថាតើពួកគេកាចឬក៏អត់ វាអាស្រ័យទៅលើចរិតលក្ខណៈបុគ្គល ។ ខ្ញុំមិនបានឃើញផ្នែកណាមួយល្អនៅក្នុងរបបនេះទេ ។ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការហួសកម្លាំង ហើយបានស្លាប់ខណៈពេលកំពុងធ្វើការ ។ ខ្ញុំមានការភ័យខ្លាច ។ ខ្ញុំបានឮពីការសម្លាប់ ប៉ុន្តែមិនបានឃើញផ្ទាល់ភ្នែកនោះទេ ។ ខ្ញុំជឿថា វាជាការពិត ។ ខ្ញុំមិនដែលឃើញ គេចាប់មនុស្សនោះទេ ។ អ្វីដែលសំខាន់នោះ គឺខ្ញុំជឿថា ការអប់រំនៅលើប្រវត្តិសាស្ត្រខ្មែរក្រហម គឺមានសារសំខាន់ខ្លាំងណាស់ ។ ខ្ញុំតែងតែប្រាប់កូនរបស់ខ្ញុំពីប្រវត្តិសាស្ត្រនេះ ។

នៅពេលរសៀលថ្ងៃទី២ វាគ្មិនម្នាក់ទៀតឈ្មោះ នុប ភិន អាយុ៦៣ឆ្នាំ ជាប្រជាជនរស់នៅសហគមន៍អន្លង់វែង បាននិយាយពីដំណើរជីវិតរបស់គាត់ដូចតទៅៈ

*ខ្ញុំបានចូលរួមបដិវត្តន៍ក្នុងឆ្នាំ១៩៧២ ដោយធ្វើជាទ័ពខ្មែរក្រហម ។ ខ្ញុំបានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍នៅអាយុ១៧ឆ្នាំ ពីព្រោះខ្ញុំចង់នាំយកសម្ដេចសីហនុជាទីស្រលាញ់របស់យើងមកកាន់អំណាចវិញ ។ ប៉ុន្តែនៅពេលនោះ ឪពុកម្ដាយខ្ញុំមិនចង់ឲ្យខ្ញុំទៅទេ ។ ខ្ញុំបានចូលរួមប្រយុទ្ធនៅក្នុងសមរភូមិជាច្រើន ដែលបណ្ដាលខ្ញុំរងរបួស ។ រាងកាយទាំងមូលរបស់ខ្ញុំត្រូវរបួស ប៉ុន្តែសំណាងដែរ ខ្ញុំមិនបានបាត់បង់អវយវៈណាមួយឡើយ ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចពេលចូលសមរភូមិម្ដងៗ ប៉ុន្តែពេលឮសូរកាំភ្លើង ខ្ញុំបានជម្នះដោយភាពក្លាហាន ។ ខ្ញុំពិតជានឹកឪពុកម្ដាយរបស់ខ្ញុំ ហើយមិនអាចជួបគាត់ទាល់តែសោះ ។ ពេលត្រឡប់មកស្រុកកំណើតវិញ ទើបខ្ញុំបានដឹងថាឪពុកម្ដាយខ្ញុំបានស្លាប់ទៅហើយ ។ ក្រោយថ្ងៃជម្នះ១៧ មេសា ១៩៧៥ ខ្ញុំត្រូវបានបញ្ជូនទៅកោះពូលូវៃ ហើយក្រោយឈរជើងនៅលើកោះចាស់ រហូតដល់កងទ័ពវៀតណាមបើកការវាយប្រហារ ។ ខ្ញុំបានយាមដែនសមុទ្រនៅកោះពូលូវៃថ្មី និងកោះពូលូវៃចាស់ ។ នៅឆ្នាំ១៩៧៦ កងទ័ពវៀតណាមបានវាយប្រហារ និងកាន់កាប់កោះនេះ ។ ជាលទ្ធផល កងទ័ពខ្មែរក្រហមទាំងអស់ត្រូវបានចាប់ឃុំឃាំងនៅកោះត្រល់ (កោះភូគុក ជាភាសាវៀតណាម) ។ មានអ្នកទោសខ្មែរក្រហម ៣០០ ឬ ៤០០ នាក់ជាប់នៅលើកោះនោះ ។ ខ្ញុំបានចូលបម្រើយោធាខ្មែរក្រហមនៅក្នុងកងពលពិសេសលេខ៣ ស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត ។ មាស មុត ជាមនុស្សល្អ ដែលមានសណ្ដានចិត្តល្អណាស់ ។ គាត់ពិតជាជំនាញខាងបញ្ជាកងទ័ព ។ សារទាំងអស់ត្រូវបញ្ជូនទៅកាន់កោះនេះ តាមរយៈទូរលេខ ។ នៅឆ្នាំ១៩៧៩ ខ្ញុំបានភៀសខ្លួនទៅភ្នំដងរែក ក្រោយមកបានរៀបការប្រពន្ធក្នុងអំឡុងពេលនោះ ។ មុនពេលរំសាយកងពល ខ្ញុំត្រូវបានបញ្ជូនទៅកាន់តំបន់ប្រាសាទព្រះវិហារដើម្បីការពារប្រទេសរបស់យើង ។ ការតាំងចិត្តរបស់ខ្ញុំនៅពេលនោះគឺលះបង់ជីវិតដើម្បីបុព្វហេតុជាតិ, ការពារទឹកដី, ជាជាងការអនុញ្ញាតឲ្យបរទេសកាន់កាប់ទឹកដីរបស់យើង ។ ទាក់ទងទៅនឹងប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំមិនមានអារម្មណ៍ថាសោកស្ដាយទេ ព្រោះវាជារឿងអតីតកាល ។ ជាចុងក្រោយ អ្វីដែលខ្ញុំចង់ស្នើសុំនោះគឺការពារកុំឲ្យអតីតកាលសង្គ្រាម និងអំពើប្រល័យពូជសាសន៍កើតឡើងម្ដងទៀត ។*

## ការជួបសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋាន

នៅពេលរសៀលនៃថ្ងៃទីពីរ (ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៦) សិស្ស-និស្សិត ត្រូវបានផ្ដល់ឱកាសឲ្យចូលជួបជាមួយឯកឧត្ដម ស ថាវី អភិបាលខេត្តឧត្ដរមានជ័យ និងលោក ហូ ជិនវរយុទ្ធ, អភិបាលស្រុកអន្លង់វែង ។ កិច្ចប្រជុំនេះត្រូវបានប្រារព្ធឡើងនៅក្នុងសាលាស្រុកអន្លង់វែង ។ តាងនាមឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា និងសិស្ស-និស្សិត ខ្ញុំបានធ្វើបទបង្ហាញយ៉ាងសង្ខេបពីគោលបំណងនៃកម្មវិធីដំណើរសន្តិភាពអន្លង់វែងនេះ ។ គោលបំណងចម្បង គឺដើម្បីឲ្យសិស្ស-និស្សិតចុះទៅដល់ទីតាំងប្រវត្តិសាស្ត្រ ដើម្បីលើកកម្ពស់ការយល់ដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួន, ជាពិសេសអតីតទីតាំងចុង

ក្រោយរបស់ខ្មែរក្រហមនៅតំបន់អន្លង់វែង ។ ទន្ទឹមនឹងនេះដែរ, ឯកឧត្តម ស ថាវី បានសម្ដែងការកោតសរសើរចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្ដល់ឱកាសដល់សិស្ស-និស្សិត ទាំងអស់ដែលមានចំនួនបួននាក់កំពុងសិក្សានៅវិទ្យាល័យអន្លង់វែង ដើម្បីផ្សារភ្ជាប់ខ្លួនទៅក្នុងការអប់រំប្រវត្តិសាស្ត្រអន្លង់វែងនេះ ។ លោកបានថ្លែងថា "ក្នុងនាមជាទំពាំងស្នងឫស្សី, យើងចាំបាច់ត្រូវតែធ្វើការសិក្សាបន្ថែមទៀតទៅលើប្រវត្តិសាស្ត្រអន្លង់វែងដើម្បីបង្កើនការយល់ដឹងរបស់ខ្លួនពីអតីតទីតាំងចុងក្រោយខ្មែរក្រហម ។ ខ្មែរក្រហមបានសម្រេចចិត្តបោះមូលដ្ឋានទ័ពរបស់ខ្លួននៅទីនេះ(អន្លង់វែង) ពីព្រោះតែទីតាំងនេះមានលក្ខណៈអំណោយផលទាំងភូមិសាស្ត្រ និងកងទ័ព ដែលធ្វើឲ្យមានភាពងាយស្រួល មិនត្រឹមតែអាចការពារខ្លួនឯងនោះទេ ក៏ប៉ុន្តែអាចប្រមូលផ្ដុំកម្លាំងវាយប្រហារសត្រូវចំពោះមុខ ។ ឧទាហរណ៍ជាក់ស្ដែង មូលដ្ឋានទ័ព តាម៉ុក ហ៊ុមព័ទ្ធដោយស្រះទឹកធំមួយ ដូច្នេះហើយសត្រូវប្រាកដជាមានផលវិបាកក្នុងការវាយប្រហារ ។ ឧទាហរណ៍មួយទៀតនោះ គឺមូលដ្ឋានអន្លង់វែងស្ថិតនៅជិតព្រំដែនប្រទេសថៃ ។ បើចាញ់សង្គ្រាមនោះ ទ័ព តាម៉ុក នឹងរត់ចូលទឹកដីថៃ ហើយបើទាហានរដ្ឋាភិបាលបាញ់ផ្លោងចូលក្នុងទឹកដីថៃ នឹងមានការផ្លោងតបមកវិញ ។

នៅពេលកិច្ចប្រជុំចប់ ឯកឧត្តម ស ថាវី បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមជាមួយសិស្ស-និស្សិតដែលបានចំណាយពេលមកធ្វើទស្សនកិច្ចសិក្សានៅទីតាំងប្រវត្តិសាស្ត្រទាំងនេះ និងផ្ដល់ឲ្យសិស្សនិស្សិតវិញនូវសៀវភៅប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង ។ ក្នុងឱកាសនោះ លោក ហូ ជិនវរយុទ្ធ បានស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាផ្ដល់សៀវភៅមួយចំនួនបន្ថែមទៀតជាភាសាអង់គ្លេស ទៅដល់ខេត្តឧត្តរមានជ័យ ដើម្បីឲ្យថ្នាក់ដឹកនាំខេត្តអាចប្រើប្រាស់ជាវត្ថុអនុស្សាវរីយ៍ឲ្យទៅភាគីអាជ្ញាធរថៃ ។

## ដំណើរទស្សនកិច្ចទៅកាន់ទីតាំងប្រវត្តិសាស្ត្រ

នៅព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ សិស្ស-និស្សិត បានចាប់ផ្ដើមដំណើរទស្សនកិច្ចរបស់ខ្លួនទៅកាន់ទីតាំងប្រវត្តិសាស្ត្រដែលបានជ្រើសរើស មានដូចជា ផ្ទះតាម៉ុក, ទីតាំងបញ្ចុះសព សុន សេន, ចេតិយ តាម៉ុក នៅក្នុងវត្តស្រះឈូក, ទីតាំងបូជាសព ប៉ុល ពត និងការិយាល័យប្រជុំរបស់ តាម៉ុក (នៅជ្រោយតារឿន លើភ្នំដងរែក) ។ បន្ទាប់ពីស្ដាប់បទបង្ហាញ និងការអានសៀវភៅប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង សិស្ស-និស្សិត បានចុះទៅសិក្សាស្វែងយល់ពីទីតាំងប្រវត្តិសាស្ត្រទាំងនោះ និងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងពីលទ្ធភាពក្នុងការបង្កបង្កើតទីតាំងចុងក្រោយរបស់ខ្មែរក្រហមនេះ ការប្រមូលការគាំទ្រពីប្រជាជន និងការដែលអាចបន្តធ្វើសង្គ្រាមស៊ីវិលរហូតដល់ឆ្នាំ១៩៩៨ ។ បុគ្គលិកលក្ខណៈ តាម៉ុក និងមនោគមវិជ្ជាខ្មែរក្រហម គឺជាផ្នែកនៃទ្រឹស្ដី ។ ប្រជាជនបានស្ងើចសរសើរ តាម៉ុក ពីព្រោះគាត់ពូកែខាងដាក់ខ្លួនឯងឲ្យស្មើហ្នឹងប្រជាជនគាត់ ។ គាត់គោរពរាប់អានប្រជាជនដូចកូនចៅរបស់គាត់ ដែលគាត់បានផ្ដល់ឲ្យសូម្បីតែអង្ករ, អំបិល, ក្រណាត់ រួមទាំងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍ដូចជា ផ្លូវថ្នល់, សាលារៀន និងមន្ទីរពេទ្យ ។ ក្រៅពីនេះ សិស្ស-និស្សិត ក៏បានគិតដល់អំពើសប្បុរសរបស់តា ម៉ុក ដែលសម្ដែងឲ្យឃើញពីការកិច្ចខិតខំប្រឹងប្រែងរបស់គាត់ ដើម្បីបម្រើដល់សេចក្ដីលោភលន់ក្នុងការថែរក្សាអំណាចរបស់គាត់ ។ នេះជាការលើកឡើងនៅក្នុងសម្ដីរបស់លោក អ៊ិត សារិន ដែលបានសរសេរនៅក្នុងកំណត់ហេតុ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៣ "វិន័យរបស់អង្គការខ្មែរក្រហមមិនមែនធ្វើឲ្យគោលការណ៍ណែនាំមហាជន ធ្លាក់ចុះនោះទេ ។ សមាជិកខ្មែរក្រហមម្នាក់ៗ ត្រូវតែមានភាពទន់ភ្លន់ និងអាកប្បកិរិយាសុភាព ចំពោះប្រជាជន" ។ សមាជិកខ្មែរក្រហមម្នាក់ៗ តែងតែត្រូវបានរំឭកពីពាក្យសម្ដីរបស់លោកប្រធាន ម៉ៅ សេទុង ថា "មហាជនជាត្រី ហើយយើងជាទឹក" ។ ជនបដិវត្តន៍ម្នាក់ៗ បានចាត់ទុកខ្លួនឯង ជាកូនចៅរបស់ប្រជាជន, អ្នកបម្រើរបស់ប្រជាជន" ទោះជាយ៉ាងណាក៏ដោយ លោក អ៊ិត សារិន បានសង្កេតឃើញថា ចំពោះខ្មែរក្រហមជិហររបស់ខ្លួនបានបង្ហាញពីការត្រៀមខ្លួនរួចជាស្រេចដើម្បីរៀនសូត្រពីប្រជាជន និងបម្រើប្រជាជន តែមិនដែលធ្វើតាមប្រជាជននោះទេ ។ តាម៉ុក អាចនឹងប្រកាន់ខ្ជាប់នូវការអនុវត្តនេះ ក្នុងអំឡុងពេលកាន់តំណែងរបស់ខ្លួន ជាមេបញ្ជាដ៏មានអំណាចនៅតំបន់អន្លង់វែង ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ។ ជាការពិត ភាគច្រើននៃអតីតសមាជិកខ្មែរក្រហមនៅអន្លង់វែង ពេញចិត្តការដឹកនាំរបស់គាត់ ។ ទាំងនេះបង្ហាញថា មនោគមវិជ្ជាកុម្មុយនិស្តអាចសម្រេចបាន និងមានប្រសិទ្ធភាពដើម្បីប្រមូលការគាំទ្រពីប្រជាជន ។

### ការឆ្លុះបញ្ចាំងពីគំនិតរបស់សិស្ស-និស្សិត ប្រចាំថៃ

សិស្ស-និស្សិតទាំងអស់បានបង្ហាញពីការយល់ឃើញរបស់ខ្លួនទាក់ទងនឹងដំណើរជីវិតនីមួយ ដែលជាផ្នែកមួយគួរឲ្យចាប់អារម្មណ៍បំផុត ក្នុងអំឡុងពេលដំណើរទស្សនកិច្ចសិក្សាសន្តិភាពទៅកាន់តំបន់អន្លង់វែង ។ ដូច្នេះ ទាំងនេះអាចដោះស្រាយមន្ទិលសង្ស័យ ដែលបានគិតពីមុនមកថា ខ្លួននឹងជួបការលំបាកក្នុងការទាក់ទងជាមួយយុវជន និងអ្នកភូមិនៅក្នុងសហគមន៍មួយនេះ ដែលត្រូវបានបង្កើតដោយអតីតសមាជិកខ្មែរក្រហម ។ និស្សិត រឿន សុធារី ភេទស្រី មានអាយុ ២១ឆ្នាំ និស្សិត សែន វិចិត្រ, អ្នកទាំងពីរសិក្សាផ្នែកសង្គមវិជ្ជានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានសរសេរនៅក្នុងក្រដាស់កិច្ចការប្រចាំរបស់ខ្លួនថា អ្វីដែលខ្លួនបានស្មានពីមុនមកគឺខុសទាំងស្រុង ។ អ្នកភូមិមានភាពរួសរាយរាក់ទាក់ និងគួរឲ្យស្រលាញ់ ។ សិស្ស-និស្សិតចូលរួមជាច្រើន ដូចជា និស្សិត ផាន ម៉ារ៉ាឌី សិក្សាផ្នែកសង្គមវិទ្យាក៏បានលើឡើងដូច្នេះដែរ ដែលជាគំនិតឆ្លុះបញ្ចាំងទូទៅចំពោះជនរងគ្រោះរួចផុតពីរបបខ្មែរក្រហមទាំងនោះ ។ មានអតីតទាហានខ្មែរក្រហមមួយចំនួនសុខចិត្តបូជាជីវិតរបស់ខ្លួនដើម្បីការពារបូរណភាពទឹកដីកម្ពុជា ។ ដូចអ្វីដែលបានលើកឡើងនៅក្នុងសេចក្ដីដកស្រង់ ណុប ភិន បានរំលឹកពីស្មារតីជាតិនិយម នៅពេលដែលគាត់ត្រូវបានបញ្ជូនទៅសមរភូមិមុខ ក្នុងអំឡុងពេលមានជម្លោះកម្ពុជាថៃ នៅប្រាសាទព្រះវិហារ ។ សិស្ស-និស្សិតគិតថា រឿងរ៉ាវជីវិតរបស់វាគ្មិនទាំង២ ជាព័ត៌មានសំខាន់ មានការត្រិះរិះពិចារណា និងជាការជំរុញទឹកចិត្តក្នុងជីវិត ។ យ៉ាងណាក៏ដោយ ការពន្យល់របស់ខ្លួនក៏នៅមានកម្រិតមួយចំនួនផងដែរ ។ សិស្ស-និស្សិតបានសង្កេតឃើញថា មីង ចក់ រ័ត្ន នៅតែមានអារម្មណ៍មិនស្រួលជាមួយការរៀបរាប់ពីដំណើរជីវិតរបស់ខ្លួន ខណៈដែលពូ ណុប ភិន មានអារម្មណ៍បើកចំហ និងមានភាពងាយស្រួល ។ និស្សិត ជា ម៉ាលីន ភេទស្រី អាយុ២១ឆ្នាំ ជានិស្សិតនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ សិក្សាផ្នែកប្រវត្តិវិទ្យា បានសរសេរថា ទោះបីជាមានខុបសគ្គក្នុងការនិយាយប្រាប់ពីរឿងរ៉ាវជីវិតក៏ដោយ វាគ្មិនបានដើរតួនាទី ជាអ្នករំលឹករស់រវើកសម្រាប់ប្រជាជនកម្ពុជាគ្រប់វ័យដែលកំពុងព្យាយាមសិក្សាពីប្រវត្តិសាស្ត្រនេះ និងជួយការពារកុំឲ្យវាកើតមានឡើងម្ដងទៀត ។ បន្ថែមពីលើនេះ សិស្ស-និស្សិតក៏ទទួលបានឱកាសដើម្បីចុះទៅជួបផ្ទាល់ជាមួយអ្នកភូមិពីកន្លែងមួយទៅកន្លែងមួយ ដែលជាផ្នែកមួយនៃបេសកកម្មអប់រំរបស់ខ្លួន ។ សិស្ស-និស្សិតទាំង១២នាក់ ក៏បានធ្វើបទសម្ភាសន៍ប្រជាជនរស់នៅសហគមន៍អន្លង់វែងទាំងប្រុស និងស្រីចំនួន១២នាក់ដែរ ។

### សេចក្ដីសន្និដ្ឋាន

ការជួបសន្ទនាដោយផ្ទាល់ ជាចំណុចសំខាន់នៃដំណើរទស្សនកិច្ចមួយសម្រាប់សិស្ស-និស្សិតដែលបានចូលរួម ។ កិច្ចសន្ទនានេះបានបង្កើននូវការយល់ដឹងកាន់តែច្បាស់លាស់ពីរបបខ្មែរក្រហម សង្គ្រាមស៊ីវិល (១៩៧៩-១៩៩៨) និងរយៈកាលបន្ទាប់មក ។ ដោយសារតែភាពរីករាយ និងចង់ដឹងការចូលរួមដំណើរទស្សនកិច្ចសិក្សារបស់សិស្ស-និស្សិតត្រូវបានរៀបចំយ៉ាងល្អ និងចាប់ផ្ដើមកិច្ចសន្ទនាក្នុងលក្ខណៈស្ថាបនា ។ វាគ្មិនទាំងពីររូប នៅថ្ងៃទី២ បានផ្ដល់ឲ្យសិស្ស-និស្សិត នូវកម្លាំង និងការលើកទឹកចិត្ត ដើម្បីបន្តកិច្ចពិភាក្សាបន្ថែមទៀតជាមួយប្រជាជនផ្សេងទៀតនៅក្នុងសហគមន៍ ។ ខណៈពេលដែលសិស្ស-និស្សិតចូលរួមភាគច្រើនហាក់ដូចជាកាន់តែចាប់អារម្មណ៍ក្នុងរៀបរាប់ថា ទូទៅថា តា ម៉ុក បានធ្វើកិច្ចការងារល្អសម្រាប់អ្នកភូមិ និងអ្នកផ្សេងទៀត ដូចជា លោក អ៊ិត សារិន បានជឿថា មនោគមវិជ្ជាកុម្មុយនីស្ដខ្មែរក្រហម នៅតែត្រូវបានប្រើប្រាស់ដើម្បីទាក់ទាញយកចិត្តប្រជាជន ដែលនៅក្រោមការគ្រប់គ្រងរបស់តាម៉ុក នៅអន្លង់វែង ។

សិស្ស-និស្សិត មានការចាប់អារម្មណ៍ជាមួយការអត្ថាធិប្បាយរបស់លោកលោក ភិន ចំពោះបេសកកម្មយោធារបស់គាត់ដើម្បីការពារប្រាសាទព្រះវិហារ ។ គាត់លើកឡើងថា គាត់បានត្រៀមខ្លួនរួចជាស្រេច ដើម្បីបូជាជីវិតរបស់ខ្លួនការពារបូរណភាពទឹកដីកម្ពុជា ។ ជាការពិតណាស់ ភិន គ្រាន់តែជាកងទ័ពម្នាក់តែប៉ុណ្ណោះ ។ អ្វីដែលសំខាន់ជាងនេះទៀតនោះគឺ សិស្ស-និស្សិតចូលរួមមានសេចក្ដីពេញចិត្តចំពោះអ្នកតំណាងអាជ្ញាធរមូលដ្ឋាន ដែលរកពេលវេលាសមស្របមួយក្នុងកាលវិភាគដ៏មមាញឹករបស់គាត់ ដើម្បីផ្ដល់ឲ្យនូវការស្វាគមន៍យ៉ាងកក់ក្ដៅ និងការពន្យល់ដ៏មានអត្ថន័យពីសហគមន៍អន្លង់វែង ។ សិស្ស-និស្សិតចូលរួម បានចែករំលែកអត្ថបទរបស់ខ្លួនចំពោះរឿងរ៉ាវជីវិតរបស់អ្នកភូមិ ដល់ទស្សនាវដ្ដីប្រចាំខែរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា "ការស្វែងរកសេចក្ដីពិត" ។ **លី សុខឃាង**

# រសាត់តាមខ្យល់

**(តពីលេខមុន)**



ជាមួយនឹងសំពត់ដែលគាត់ស្លៀកស្ទើរជាប់ស្ទើររបូតពីខ្លួន ពុទ្ធោ ពេលនេះគឺគាត់ក្លាយទៅជាមនុស្សវិកលចរិតទៅហើយ ដើរបណ្តើរ គាត់ ស្រែកយំបណ្តើរ ដៃទាំងពីរលើកសំពះឡើងលើហាក់ដូចជាកំពុងតែអង្វរលន់តួអ្នកណាម្នាក់ៈ «មិត្តលន់! យកប្តីមីងទៅរៀនសូត្រ ចុះម៉េចក៏យូរម្ល៉េះ? ដល់អន្កាលទៅទើបប្តីមីងបានត្រឡប់មកវិញ? អាណោកូនម៉ែ អាបុង ស្រីមុំកូនមាសម្តាយ តើកូនៗមានកំហុសអីបានជាត្រូវគេយកទៅសម្លាប់?» ។ ពេលដែលបងសុខា កំពុងតែអង្វរលួងលោមយកដៃទៅជូតទឹកភ្នែកជូនគាត់ ខ្ញុំនៅបានឮគាត់ស្រែកដង្ហោយទៀតថាៈ «ក្លួយទុយ ម៉េចបានជាក្លួយបញ្ជាឲ្យគេយកប្អូនៗទៅសម្លាប់? មិត្តទុយ ជាប្រធានភូមិកងសៅចុងក្រោយ (ត្រូវជាក្លួយបង្កើតខាងប្តីគាត់) ប្អូនៗមានកំហុសអី? ក្លួយអីក៏ចិត្តដាច់ម្ល៉េះ ក្លួយមិនអាណិតមីងទេឬ?» ។ មិនថាតែរូបខ្ញុំម្នាក់ទេ ប្រជាជនអ្នករួមដំណើរដែលស្នាក់នៅក្បែរៗនោះច្រើនណាស់រន្ធត់ក្តុកក្តួលក្នុងចិត្តនឹកអាណិតអាសូរដល់រូបគាត់ដែលរងគ្រោះអស់ម្តាយ អស់ប្តី អស់កូនពីខ្លួនក្លាយជានាងបងាចាពិតៗ ពេលនោះម្នាក់ៗស្ទើរតែទប់ទឹកភ្នែកពុំបានឡើយ ។

បីថ្ងៃក្រោយមកក្នុងដំណើរធ្វើរដើង យើងក៏បានមកដល់មាត់ទន្លេពាមជីកងដោយសុវត្ថិភាព ។ ខ្ញុំសែនរំភើបក្នុងចិត្តយ៉ាងខ្លាំង ពេលដែលបានឃើញកំពង់ដង្កោរស់ឆ្ងាយសន្ទឹមឯត្រើយម្ខាងសាជាថ្មី នៅនឹងកំពង់ចម្លងពាមជីកងមានទូកអ្នកកោះអណ្តែតជាច្រើនមកចតចាំទទួលចម្លងបងប្អូនសាច់ញាតិទៅត្រើយម្ខាង ។

បរិយាកាសជុំវិញនៅមាត់ទន្លេពាមជីកងរសៀលថ្ងៃនោះពោរពេញទៅដោយភាពត្រេកអរសប្បាយរីករាយក្នុងការត្រឡប់វិលមកភូមិកំណើតជួបជុំបងប្អូន ឪពុកម្តាយដែលបែកឃ្លាតជាងបីឆ្នាំកន្លងមកនេះ ។ ជាមួយ គ្នានេះដែរ ក៏មានបរិយាកាសសោកនាដកម្មជាច្រើនបានកើតឡើង ពេលដែលបងប្អូនប្រជាជនបានជួបគ្នាជាថ្មី ឱបគ្នាទ្រហោយំខ្សឹបខ្សួលសម្តែងការសោកស្តាយចំពោះសាច់ញាតិក្រុមគ្រួសារដែលរងគ្រោះបាត់បង់ជីវិតក្នុងរបបដ៏សាហាវព្រៃផ្សៃពុំដែលមានក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។

ខ្ញុំសែនប្រហូកប្រហល់ក្នុងចិត្ត ពេលដែលក្រុមគ្រួសារឆាវ៉ាក់នាំគ្នាជញ្ជូនអីវ៉ាន់ចុះទូកដើម្បីឆ្លងទៅត្រើយម្ខាង ។ ភូមិស្វាយតាហែនដែលបងស្រ៊ាង បងសារុំ និងវិរដ្ឋលរស់នៅ ស្ថិតនៅជិតកង្កើយពីកំពង់ចម្លងពាមពីកងនេះ ហើយមុនអ្វីៗទាំងអស់ បេះដូងខ្ញុំនៅប្រាថ្នាចង់ឃើញនាងវិរដ្ឋល ជាថ្មីសិន ។

ខ្ញុំក៏មកជម្រាបអ្នកមីងម្តាយឆាវ៉ាក់ និងគ្រួសារបងស្រីគាត់ថាសូមឲ្យពួកគាត់អញ្ជើញទៅមុនចុះ ខ្ញុំចង់ទៅសាកសួរសុខទុក្ខបងៗនៅស្វាយតាហែន និងក្បាលកោះអណ្តែតពីរបីថ្ងៃសិន ចាំខ្ញុំធ្វើដំណើរទៅភូមិព្រៃជ្រីងតាមក្រោយ ។

ក្រោយពីពេលដែលទូកពួកគាត់បានចាកចេញពីកំពង់ទៅ ខ្ញុំដែលមានតែកូនបង្វេចតូចមួយស្ពាយនៅនិងស្មា ក៏ប្រញាប់រូតដំណើរតម្រង់ទៅភូមិស្វាយតាហែនភ្លាម ។ ពេលមកដល់ផ្ទះឪពុកម្តាយបងស្រ៊ាង ដោយក្តីរំភើបផង អរផងក្នុងចិត្តខ្ញុំហាក់ប្រហូកប្រហល់រកស្មានមិនត្រូវ ជាមួយគ្នានោះបេះដូងខ្ញុំផ្តើមលោះយ៉ាងញាប់ខុសចង្វាក់ ។

ខ្ញុំបានបោះជំហានដើរចូលទៅ ខ្ញុំឃើញបងស្រ៊ាង ស្ទុះពី

ក្រោមផ្ទះតម្រង់មក ខ្ញុំលើកដៃសំពះជម្រាបសួរគាត់ គាត់ស្រវាឱបខ្ញុំទាំងក្តីនឹករលឹក "អាប្អូន...អញនឹកអែ្ហងណាស់" ។ ខ្ញុំជម្រាបសួរបងរ៉ុ និងចាស់ៗប្អូនប្រាំនាក់ទៀតដែលកំពង់អង្គុយជុំគ្នានៅលើគ្រែរនាបឫស្សីក្រោមផ្ទះ ។

ក្រោយពីសម្តែងការនឹករលឹក និងសួរសុខទុក្ខគ្នាទៅវិញទៅមករួចហើយ ក្រសែភ្នែកខ្ញុំរំពៃរកមើលជាញឹកញយជាមួយចម្ងល់ក្នុងចិត្តថា ហេតុអ្វីក៏បានជាមិនឃើញស្រមោលនាងរំដួល ។ ដើម្បីកុំឲ្យពួកគាត់ចាប់ អារម្មណ៍ ខ្ញុំក៏ផ្តើមសួរបងសារ៉ុំពីពូផន និងមីងណារុង តើពួកគាត់បានអញ្ជើញមកដល់ក្បាលកោះវិញហើយឬនៅ? ។ ពេលនោះខ្ញុំសែនក្តុកក្តួលខ្លោចផ្សាក្នុងចិត្តគ្រាដែលបងសារ៉ុំ បានប្រាប់ខ្ញុំពីដំណឹងមរណភាពរបស់ពូផន ។ មីងណារុង បានចូលមកប្រាប់ថា គ្រាន់តែបានចេញដំណើរពីភូមិទួលសង្កែផុតឆ្ងងផុតកំពង់ថ្មមកដល់ទឹកដីតាំងគោក ល្ងាចថ្ងៃដដែលនោះពូផន ក៏បានធ្វើមរណកាលទៅ ។ ក្រោយពីទុកដាក់សពពូផន នៅនឹងទឹកដីតាំងគោករួចហើយ មីងណារុង ដែលមានផ្ទៃពោះកាន់តែជិតគ្រប់ខែហើយនោះ បានអញ្ជើញមកកោះអណ្តែតដើម្បីជម្រាបតាប៉ូ យាយជន ដែលជាឪពុកម្តាយពូផនរួចហើយបានមីងណារុងបន្តដំណើរទៅស្រុកកំណើតគាត់ឯភូមិព្រៃកដើមចន្ទន៍ស្រុកកំពង់សៀម ។

បន្តិចក្រោយមក បងស្រ៊ាង និងបងសារ៉ុំ បាននាំខ្ញុំទៅលេងផ្ទះគាត់ដែលសង់ពីឈើប្រក់ស្លឹកផ្ទាល់ និងដីនៅជ្រុងម្ខាងក្នុងបរិវេណជាមួយគ្នានឹងផ្ទះឪពុកម្តាយគាត់ដែរ ។ ពេលដែលបងស្រ៊ាង ឆាក់កង់ចេញទៅក្រៅបាត់ទៅ បងសារ៉ុំ បាននាំខ្ញុំទៅអង្គុយលេងនៅលើគ្រែឫស្សីតូចមួយក្បែរពាងទឹកក្រោមម្លប់ដើមត្របែកមួយដើមខាងក្រោយផ្ទះ ។ វិនាទីដែលខ្ញុំប្រុងនឹងសួរគាត់រក រំដួល នោះ គាត់បាននិយាយមកកាន់ខ្ញុំថាៈ "អាក្អូនឯងមកដល់ថ្ងៃនេះ ត្រូវពេលល្អណាស់" ។ នៅពេលដែលខ្ញុំកំពុងតែងឿងឆ្ងល់នឹងពាក្យសំដីគាត់ បងសារ៉ុំ បានបន្តទៀតថាៈ "រំដួល ត្រូវរៀបការនៅព្រឹកថ្ងៃស្អែកនេះហើយ" ។ គ្រាន់តែបានឮសម្តីបងសារ៉ុំ ប៉ុណ្ណោះមាត់ចុងក្រោយនេះ ដើមទ្រូងខ្ញុំប្រែជាតឹងស្ទើរប្រេះធ្លាយមួយរំពេច បេះដូងថ្លើមប្រម៉ាត់ខ្ញុំកំពុងតែស្ថិតក្នុងភាពយ៉ាងល្ហិតល្ហៃល្ហិងល្ហើយ និងអស់សង្ឃឹម ថ្ងៃស្អែក រំដួល ចូលរោងការ ក្នុងត្រចៀកខ្ញុំហាក់ដូចជាឮសូរតែពាក្យដដែលៗនេះ ។

ខ្ញុំខំទប់ចិត្តទប់អារម្មណ៍ និងខំធ្វើទឹកមុខធម្មតាដើម្បីកុំឲ្យបងសារ៉ុំ ចាប់ភ្លឹក ស្ងាត់មួយស្របក់ខ្ញុំក៏បានសួរទៅគាត់វិញថាៈ "ចុះ រំដួល ទៅណាបានជាមិនឃើញ" ។ ខ្ញុំចោលភ្នែកទៅបរិវេណខាងក្រៅផ្ទះ ឃើញប្រុសៗប្អូនប្រាំនាក់ ខ្លះនាំគ្នាប្រៀកផាងដូងកាប់ជាក្បាច់សម្រាប់តុបតែង ខ្លះរែកទឹកចាក់ពាង និងខ្លះទៀតកំពុងដំឡើងរោងការស្របពេលជាមួយគ្នានោះខ្ញុំបានឮបងសារ៉ុំ តបមកខ្ញុំវិញថាៈ "រំដួល ចេញទៅផ្ទះគូដណ្តឹងវានៅឯចុងភូមិប្រហែលជាជិតត្រឡប់មកវិញហើយ" ។

បងសារ៉ុំ និយាយមិនទាន់ទាំងផុតពីមាត់ស្រួលបួលផង ខ្ញុំបានឃើញ រំដួល ជិះកង់ត្រឡប់មកវិញល្មម ក្រោយពីបញ្ឈរកង់ស្រួលបួលហើយ នាងក៏ដើរតម្រង់មករកខ្ញុំ និងបងសារ៉ុំមកដល់នាងបាននិយាយថា បងស្រ៊ាង បានទៅប្រាប់នាងពីការមកដល់របស់ខ្ញុំនាងបានសួរសុខទុក្ខខ្ញុំ ។

ខ្ញុំសែនរំភើបក្នុងចិត្តឥតឧបមា គ្រាដែលបានជួបនាងសាជាថ្មី ។ ផែនថ្ពាល់ទាំងគូរក្រហមរលោង ច្រមុះសមស្រួចដែលកែវភ្នែកខ្ញុំបានថតផ្តិតជាប់ទុកក្នុងក្រអៅបេះដូងកាលពីជាងបីឆ្នាំមុននោះនៅតែល្អ នៅតែស្រស់ដដែល ។ នាងញញឹមមករកខ្ញុំយ៉ាងស្រស់ពោរពេញទៅដោយមន្តស្នេហ៍ បង្ហាញឲ្យឃើញស្នាមខួចលើផែនថ្ពាល់ខាងស្តាំរបស់នាង ។

ខ្ញុំក្រោកចេញពីគ្រែ មកឈរផ្អែកពាងទឹកទុកកន្លែងឲ្យ រំដួល អង្គុយបន្តិចក្រោយមកបងសារ៉ុំ ក៏បានក្រោកដើរចេញពីទីនោះទៅទុកឱកាសឲ្យខ្ញុំ និងរំដួល សំណេះសំណាលគ្នាតែពីរនាក់ ។ ខ្ញុំសម្លឹងចំរង្គង់ភក្ត្រនាងដោយក្រសែភ្នែកសោកស្តាយនាងងាកចេញពីភ្នែកខ្ញុំ ខ្ញុំក៏ផ្តើមនិយាយទៅនាងថាៈ "សំណាងណាស់ដែលខ្ញុំមកដល់ត្រូវចំថ្ងៃស្អែក រំដួល ចូលរោងការ ខ្ញុំនឹងនៅចូលរួមថ្ងៃសុភមង្គលរបស់រំដួល រហូតដល់ចប់ចុងចប់ដើម" ។

រំដួល ងើបមុខឡើងសម្លឹងមករកខ្ញុំដោយក្រសែភ្នែកយ៉ាងមុតស្រួច នាងមិនតបមកខ្ញុំវិញមួយម៉ាត់សោះ នាងបែរជាក្រោកពីគ្រែដើរតម្រង់ចូលទៅក្នុងផ្ទះ ពេលដែលនាងត្រឡប់មកវិញនៅនឹងដៃនាងមានកាន់តូចសំបុត្រតូចមួយ នាងបានហុចកូនសំបុត្រនោះមកឲ្យខ្ញុំ ។ ខ្ញុំស្គាល់ច្បាស់ណាស់ គឺជាកូនសំបុត្ររបស់ខ្ញុំដែលខ្ញុំបានសរសេរដោយផ្ទាល់ដៃលាក់ទុកក្នុងជាលស្មៅរបស់នាង ពេល

ដែលយើងនាំគ្នាទៅប្រូតស្មៅគោនៅជីចម្ការថ្នាំងមាត់ទន្លេត្បូង កាលពីជាងបីឆ្នាំមុន ។

ខ្ញុំរំភើបក្នុងចិត្តយ៉ាងខ្លាំង ដោយមិននឹកស្មានថានាងបានរក្សាកូនសំបុត្រខ្ញុំទុករហូតមកដល់ថ្ងៃនេះសោះ ខ្ញុំទទួលកូនសំបុត្រពីដៃនាងជាមួយនឹងដង្ហើមធំយ៉ាងវែង រំដួល ងើបមុខសម្លឹងទៅលំហមេឃដ៏ធំល្វឹងល្វើយក្នុងចិត្ត នាងប្រហែលជាកំពុងតែច្របូលច្របល់ដូចខ្ញុំដែរ ។

ស្ងាត់មួយស្របក់ រំដួល ផ្ដើមពោលមកកាន់ខ្ញុំថាៈ «ស្ដាយណាស់ មិននឹកស្មានថាយើងបានជួបគ្នាជាថ្មី តែជាតិនេះអ្វីៗហួសអស់ទៅហើយ សល់តែពាក្យមួយមាត់គឺស្ដាយ ស្ដាយអស់មួយជីវិត» ។ ខ្ញុំឈោងដៃទៅក្ដិចត្រួយត្របែកមួយត្រួយមកខាំបន្ទប់កុំឲ្យបេះដូងដ៏ស្ងោកស្រពោនរីងស្ងួតហួតហែងរបស់ខ្ញុំ រញ្ជួយដោយក្ដីសោកសង្រេងខ្លាំងពេក ។ មុនពេលដែលនាងចាកចេញពីខ្ញុំទៅ ខ្ញុំនៅបានឮនាងពោលមកកាន់ខ្ញុំមួយម៉ាត់ទៀតថាៈ «ហួសហើយជាតិនេះ» ។ ខ្ញុំនៅឈរទ្រឹងតែម្នាក់ឯងតាមសម្លឹងដំណើរនាងរហូតឆ្ងាយផុតក្រសែភ្នែក ។

ស្អែកឡើងជាថ្ងៃដែលរំដួលចូលរោងការ ពេញមួយថ្ងៃនោះខ្ញុំបានជួយក្នុងពិធីមង្គលការនាងយ៉ាងអស់ពីដៃពីជើង ។ បងប្អូនញាតិមិត្តអ្នកភូមិផងរបងជាមួយ ជាពិសេស បងប្អូនអ្នកភូមិក្បាលកោះអណ្ដែតបានអញ្ជើញមកចូលរួមយ៉ាងច្រើនកុះករ ។ នេះជាលើកដំបូងបង្អស់ហើយបន្ទាប់ពីថ្ងៃរំដោះរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យប្រល័យពូជសាសន៍ពិធីមង្គលការរបស់ រំដួល នៅនឹងភូមិស្វាយតាហែននេះ បានប្រព្រឹត្តទៅតាមបែបបទទំនៀមទម្លាប់ប្រពៃណីតាំងពីដើមរហូតដល់ចប់ ។

យប់ឡើងមានពិធីរាំវង់ ដែលប្រគុំឡើងដោយទ្រខ្មែរមួយដើមនិងស្គរដៃមួយ ។ ឆ្ងាយពីនោះបន្តិចខ្ញុំឈរបាំងក្នុងទីងងឹត ឈរមើលកូនក្រមុំ និងកូនកម្លោះឡើងរាំបើកឆាក ។ រហូតដល់យប់ជ្រៅបន្តិចដោយនឿយហត់អស់កម្លាំងខ្លាំងពេក ខ្ញុំក៏ចូលទៅក្នុងផ្ទះបងសារុំ ប្រះខ្នងទៅលើគ្រែធ្មេចភ្នែកសម្ងំមួយស្របក់ក្រោយមកខ្ញុំក៏លង់លក់ក្នុងដំណេកស្កប់ស្កល់ ។ ខ្ញុំបានភ្ញាក់ដឹងខ្លួនឡើងវិញនៅពេលដែលបងសារុំ បានមកអង្រួនដាស់ខ្ញុំៈ «អាក្អូន! ក្រោកឡើងទៅបងដៃបាចផ្កាស្លាឲ្យពរប្អូនស្រីផង» ។ ពេលដែលខ្ញុំកំពុងតែឈានជើងឡើងដណ្ដើរទៅលើផ្ទះ ខ្ញុំបានឮភ្លេងលេងបទបាយខុនចងដៃយ៉ាងពិរោះលាយឡំនឹងសំឡេងមាត់ទ្រហឹងខ្ញៀវខ្ញា ។ ឡើងទៅដល់ចំពេលដែលភ្ញៀវទាំងអស់គ្នាកំពុងតែបាចផ្កាស្លាស្រោចទៅលើគូស្វាមីភរិយាថ្មីយ៉ាងសប្បាយរីករាយ ។

បងសារុំ ហុចផ្កាស្លាមួយស្នែងមកឲ្យខ្ញុំដែលអង្គុយឆ្ងាយបន្តិចចំពីមុខ រំដួល និងស្វាមី ខ្ញុំមិនបានបេះផ្កាស្លា ចេញពីស្នែងទេ តែខ្ញុំបោះទៅទាំងស្នែងតែម្ដង ។ រំដួល ងើបមុខឡើងញញឹមមករកខ្ញុំក្រាដែលផ្កាស្លាទាំងស្នែងបានធ្លាក់ចូលទីក្នុងរង្វង់ដៃនាងដែលកំពុងតែក្រាបសំពះផ្ទឹមរង់ចាំទទួលពរជ័យសិរីសួស្ដីពីមេបាចាស់ទុំទាំងប្រុសស្រី ។ ព្រឹកស្អែកឡើងខ្ញុំក៏បានជម្រាបលាបងស្រ៊ាង បងសារុំ និងក្រុមគ្រួសារគាត់ទាំងអស់ ដើម្បីបន្តដំណើរទៅមុខទៀត ។ ខ្ញុំបានផ្ដាំតាមបងសារុំ សូមឲ្យគាត់លា រំដួល និងប្ដីជំនួសខ្ញុំផង ព្រោះគេទាំងពីរនាក់មិនទាន់ភ្ញាក់ពីដំណេកនៅឡើយ ។ បងស្រ៊ាង និងបងសារុំ បានជូនដំណើរខ្ញុំរហូតដល់មាត់ទន្លេ គាត់ទាំងពីរចេះតែពោលដដែលៗថា គាត់អាណិតខ្ញុំណាស់! ខ្ញុំក៏បានតបទៅគាត់វិញថា សូមបងកុំអាណិតខ្ញុំអី ទុកឲ្យខ្ញុំអាណិតខ្លួនឯងបានហើយ ។ បងសារុំ មិនចង់ឲ្យខ្ញុំទៅណាទេ តែខ្ញុំសូមទោសគាត់ហើយជម្រាបគាត់ថា ចេញពីស្វាយតាហែននេះទៅ ខ្ញុំចូលទៅកោះអណ្ដែតជម្រាបសួរសុខទុក្ខអ៊ុំៗ ពូមីង និងឪពុកម្ដាយពូជន ផង រួចទើបខ្ញុំបន្តដំណើរទៅភូមិព្រៃជ្រឹង ឃុំព្រែករំដេង ។ បងសារុំ បានសួរខ្ញុំទៀតថា ចុះចេញពីព្រែករំដេងទៅណាទៀត? ខ្ញុំថាចេញពីព្រៃរំដេងទៅ ខ្ញុំខ្លួនឯងក៏មិនដឹងប្រាកដថានឹងត្រូវទៅកាន់ទីណាដែរ ។ ជាមួយនឹងបង្ហេចតូចមួយស្ពាយជាប់នៅនឹងស្មាដដែល ខ្ញុំលើកដៃសំពះជម្រាបលាបងស្រ៊ាង និងបងសារុំ ចុះកំពង់ឆ្លងទូកទៅកោះអណ្ដែតទាំងក្ដុកក្ដួលក្នុងចិត្ត ។

តាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងអ្វីបន្តិចបន្តួចសោះពីរំដួល និងប្ដី ។ ដប់ឆ្នាំក្រោយមកនា ពាក់កណ្ដាលឆ្នាំ១៩៨៩ ខ្ញុំបានជួបបងស្រ៊ាងម្ដងនៅភ្នំពេញ ជួបដោយចៃដន្យពេលដែលគាត់ចូលទៅស្រស់ស្រូបអាហារពេលព្រឹកនៅក្នុងភោជនីយដ្ឋានមួយខាងក្រោយវត្តសំពៅមាស ។ បងស្រ៊ាង ធាក់កង់ពីខេត្តកំពង់ចាម ទៅទិញជ្រូកពីព្រំដែនវៀតណាមយកមកលក់ ។ ចំណែកមីងណារុង វិញ បានវិញត្រឡប់ទៅរស់នៅស្រុកកំណើតនៅភូមិព្រែកដើមចន្ទន៍ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ក្រោយពីបាន

កូនស្រីមួយដែលមានមុខមាត់សម្បុរសម្បកដូច ពូផន បេះបិទ គាត់បានចូលបម្រើការងារនៅមន្ទីរពេទ្យខេត្តកំពង់ចាម ។ ឆ្នាំ១៩៨៦ ខ្ញុំបានជួបគាត់ម្តងនៅមុខសាលាបឋមសិក្សាទួលស្វាយព្រៃ ពេលដែលគាត់ធាក់កង់ឆ្ពោះទៅសាលារៀន ។ កាលនោះគាត់មករៀនបន្តយកឯកទេសផ្នែកសម្ភព ។ ខែកក្កដា ឆ្នាំ១៩៨៩ ក្នុងឱកាសបំពេញបេសកកម្មការងារមួយនៅខេត្តកំពង់ចាម ខ្ញុំបានឆ្លៀតចូលទៅរកគាត់ដល់មន្ទីរពេទ្យ តែគួរឲ្យស្តាយបំផុតដោយមិនបានជួប ។

## រសាត់តាមខ្យល់

សប្តាហ៍ដំបូងដែលខ្ញុំបានមករួមរស់នៅជាមួយក្រុមគ្រួសារអ្នកមីងម្តាយឆាវ៉ាក់ រដ្ឋអំណាចភូមិព្រៃជ្រឹង ក៏ដូចជាក្នុងឃុំព្រែករំដេងទាំងមូលមិនទាន់បានរៀបចំស្រួលបួលនៅឡើយទេ ។ ប្រជាជនដែលបានរស់រានមានជីវិត ហើយបានវិលត្រឡប់មកភូមិកំណើតវិញនោះ ម្នាក់ៗមានតែបាតដៃទទេ គ្រប់គ្រួសារទាំងអស់ត្រូវប្រឈមមុខនឹងការរស់នៅយ៉ាងលំបាក និងជីវភាពខ្វះខាតពីមួយថ្ងៃទៅមួយថ្ងៃ ។

មានប្រជាជនច្រើនណាស់នាំគ្នាសម្រុកចូលទៅក្រុងភ្នំពេញទាំងតាមផ្លូវទឹក និងផ្លូវគោក ដើម្បីទៅយកអង្ករ អំបិលតាមឃ្លាំងនានាឬយករបស់ដ៏យកភណ្ឌផ្សេងៗទៀតឲ្យតែប្រទះភ្នែក ។ មានបុរសជាមេគ្រួសារខ្លះ ត្រូវឃ្លាតពីប្រពន្ធកូនដើម្បីទៅប្រកបមុខរបរជួញដូរ ដោយធាក់កង់ឌុបអីវ៉ាន់ ឆ្លងពីខេត្តមួយទៅខេត្តមួយ ហើយអ្នកខ្លះទៀតទៅរកស៊ីរត់ពន្ធនៅព្រំដែនខ្មែរ-ថៃ ដោយយកមាសទៅទិញជាសារុង សូត្រ ថ្នាំពេទ្យ បារី និងរបស់របរប្រើប្រាស់គ្រប់ជំពូកយកមកលក់ ដោយចំណាយពេលធាក់កង់ទៅមករហូតដល់ទៅពីរសប្តាហ៍ក្នុងដំណើរផ្សងព្រេងពោរពេញទៅដោយគ្រោះថ្នាក់ដូចជាជួបក្រុមចោរបាញ់សម្លាប់ប្លន់យកមាស ជួបពួកទាហានខ្មែរក្រហម និងមានជាន់គ្រាប់មីនបង្កប់ផ្ទុះស្លាប់ជាដើម ។

វិទ្យុផ្សាយសំឡេងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅបានផ្សាយរាល់ថ្ងៃអំពាវនាវរកបងប្អូនប្រជាជនដែលស្ម័គ្រចិត្តចូលបម្រើការងារតាមក្រសួងមន្ទីរនានាដើម្បីរៀបចំស្ថាប័នរដ្ឋឡើងវិញ ។ ខ្ញុំបានជួបបងម៉ៅ អាយុទ្ធ ជាថ្មីនៅនឹងភូមិកំណើតរបស់គាត់ភូមិអូរឡោង រាល់ៗពេលដែលខ្ញុំបានទៅលេង គាត់តែងតែបបួលខ្ញុំឲ្យចូលទៅទី ក្រុងភ្នំពេញជាមួយគាត់ដើម្បីរកការងារធ្វើនឹងគេ ។ ប្រហែលមួយខែបន្ទាប់មក ស្រាប់តែបាត់ស្រមោលបងម៉ៅ អាយុទ្ធពីអូរឡោង ក្រោយមកតាមវិទ្យុមានផ្សាយនូវបទចម្រៀងថ្មីៗជាច្រើនរបស់គាត់ ។

ទន្ទឹមនឹងការប្រឈមមុខយ៉ាងលំបាករបស់ប្រជាជនក្នុងការដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃនោះ នៅតាមបណ្តោយព្រំប្រទល់ដែនខ្មែរ-ថៃ មានកើតចលនាខ្មែរតស៊ូរំដោះជាតិជាច្រើនក្រុមប្រដាប់ដោយអាវុធដូចជា ក្រុមសេរីកា ពួកខ្មែរសេរី រណសិរ្សជាតិរំដោះប្រជាជនខ្មែរជាដើម និងមានក្រុមតស៊ូមួយក្រុមទៀតគឺពួកទាហានខ្មែរក្រហមដែលសេសសល់ ។

ចលនាខ្មែរតស៊ូទាំងនោះ ខ្លះបានរួមសហការណ៍ជាមួយពួកខ្មែរក្រហម ខ្លះទៀតដាច់ខាតមិនរួមសហការណ៍ជាមួយខ្មែរក្រហមទេ តែពួកគេប្រយុទ្ធតស៊ូប្រឆាំងនឹងសត្រូវរួម គឺបណ្តេញខ្មាំងយួនឈ្លានពានលេបទឹកដីឲ្យចេញផុតពីកម្ពុជា និងកម្ទេចរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបន្តុបឡើងដោយរដ្ឋាភិបាលយួនហាណូយ ។ នៅតាមទីរួមខេត្តនានា ក៏មានចលនាខ្មែរតស៊ូខ្លះកើតឡើងដែរ ពួកគេបង្កប់ធ្វើសកម្មភាពពីស្រុកមួយទៅស្រុកមួយដោយប្រើរូបភាពឃោសនាភូតភរកុហកប្រជាជនថាៈ «កម្លាំងចលនាខ្មែរតស៊ូក្រុមនេះឬក្រុមនោះ បានវាយបណ្តេញកងទ័ពយួនឈ្លានពានមកដល់ត្រឹមនេះត្រឹមនោះហើយ» ។

វត្តព្រៃជ្រឹងកាលពីរបបប៉ុល ពតត្រូវបានប្រែក្លាយទៅជាកន្លែងធ្វើឃាតមនុស្សរាប់ពាន់រាប់ម៉ឺននាក់យ៉ាងសាហាវព្រៃផ្សៃនោះ គេឃើញមានសាកសពជនរងគ្រោះនៅតាមរណ្តៅរួមនានានៅមិនទាន់បាត់ធុំក្លិនស្អុយនៅឡើយ ។ នៅនឹងវត្តព្រៃជ្រឹងនេះ ពួកនិរតីបានដឹកជញ្ជូនប្រជាជនទាំងអ្នកចាស់អ្នកថ្មីតាំងឡានៗយកមកសម្លាប់នៅពេលយប់ ហើយមុនពេលសម្លាប់ ពួកវាបានចាក់មេក្រូនូវបទចម្រៀងបដិវត្តន៍យ៉ាងខ្លាំងៗទាំងបួនទិស ដើម្បីកុំឲ្យសម្រែករបស់ជនរងគ្រោះឮសូរទៅក្រៅវត្ត ។

ប៉ុន្មានខែចុងក្រោយនេះ ឧបាសក ឧបាសិកាចំណុះជើងវត្តទាំងនៅក្នុងភូមិអូរឡោង និងឃុំព្រែករំដេងជាប់នោះ បាននឹងកំពុងតែមមាញឹករៀបចំជួសជុលព្រះវិហារព្រះបដិមាដើម្បីនឹងធ្វើបុណ្យឆ្លងព្រះវិហារនៅពេលខាងមុខ ។

ខ្ញុំ និងលោកពូ យៀត (ឪពុកមារបស់ឆាវ៉ាក់) មានអតីតភាព

ជាគ្រូបង្រៀនបានជួយឆ្លាក់អក្សរចារលើ ផ្ទាំងថ្មគោរព និងឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះ សូមឲ្យបានជួបតែនឹងសុគតិភព ។ ផ្ទាំងថ្មដីបួន ខ្ញុំ និងលោកពូ យៀត បានយកមកដាក់នៅមាត់អណ្ដូងមួយក្បែរច្រកចូលខាងជើងវត្តដែលមានសាកសពជនរងគ្រោះនៅក្នុងអណ្ដូងនោះស្ទើរតែពេញ រួចផ្ទាំងថ្មបន្តបន្ទាប់ដាក់តាមរណ្ដៅធំៗជាងដប់រណ្ដៅទៀតជាប់គ្នាតាមរបងខាងកើត និងខាងត្បូងវត្តដែលនៅធំក្លិនស្អុយ និងនៅឃើញមានសម្លៀកបំពាក់របស់ជនរងគ្រោះនៅរាយប៉ាយពាសពេញរណ្ដៅ ។ ខាងក្រោយជាប់របងវត្តជាប់នឹងដីចម្ការស្វាយតាច្រឹក មានរណ្ដៅសាកសពរួមធំៗបួនទៀតដែលពួកវាបានសម្លាប់ចុងក្រោយកំពុងតែឡើងហើមប្រេះដី មានរណ្ដៅមួយទៀតដែលថ្មីបំផុត នៅឆ្ងាយបន្តិចពីនោះ យប់ឡើងមានឆ្កែចចកចេញពីក្នុងព្រៃមកកកាយទាញស៊ីជាចំណី ។

មីងស្រស់ កូនស្រីពៅរបស់ដូនណយ និងក្រមុំៗក្នុងភូមិជាច្រើននាក់ទៀត បាននាំគ្នាយកក្រណាត់មកកាត់ជាទង់ព្រលឹងពណ៌សសម្រាប់ដោតនៅតាមរណ្ដៅសាកសពរួម កាប់ស្រទបស្លឹកចេកខ្ចាស់ធ្វើជាកន្ទោងសម្រាប់ដាក់បាយសម្លចំណីចំណុកដែននៅថ្ងៃបុណ្យ ។ ថ្ងៃបុណ្យឆ្លងព្រះវិហារវត្តព្រៃជ្រីង មានប្រជាជនមកពីតំបន់ជិតឆ្ងាយចូលរួមយ៉ាងច្រើនកុះករ ។ តាមរណ្ដៅសាកសពរួម ទង់ព្រលឹងត្រូវខ្យល់បក់រវិចៗ មានសំណែនបាយសម្ល បង្អែម និងដុតទៀនធូបហុយទ្រគោល លាយឡំនឹងសំណោកយំសោកស្រែកដង្ហោយហៅរកឪពុកម្ដាយបងប្អូនក្រុមគ្រួសារដែលត្រូវបានពួកវាយកមកសម្លាប់នៅទីនេះ លាន់ឮគួរឲ្យអាណោចអាធ័ម ។

ពេញមួយយប់នោះ មានបញ្ចេះម៉ាស៊ីនភ្លើងភ្លឺព្រោងព្រាត និងមានប្រគុំតន្ត្រីរាំវង់ទល់ភ្លឺ ក្រុមភ្លេងបងសៀង (ជាងវ៉ៃប៉ោត នៅអូរឡោង) កំពុងតែល្បីដែលអ្នកភូមិអ្នកស្រុកនិយមហៅគាត់ថា “សិន ស៊ីសាមុត” នោះបាន ចាប់ផ្ដើមលេងតាំងពីក្បាលព្រលប់ ។ អ្នកស្រុកទាំងក្មេងចាស់ ប្រុសស្រីបាននាំគ្នាឡើងរាំលេងកំសាន្តយ៉ាងកកកុញ ។ នៅនឹងជ្រុងម្ខាង អ្នកមីង ស៊ីដេន ភរិយាអតីតអភិបាលខេត្តកោះកុង ឈរញញឹមមើលកូនស្រីក្រមុំទាំងប្រាំនាក់របស់គាត់ដែលកំពុងតែឈានជើងបន្ទន់ខ្លួនលើកដៃទាំងគូរពត់ពែនចាក់ក្បាច់រាំវង់យ៉ាងសែនសមឥតខ្ចោះ ។

គ្រាន់តែចប់បទរាំវង់ភ្លាម ភ្លេងលេងចង្វាក់ឡាំលាវ តាច្រឹកដែលឈរញាក់ដៃញាក់ជើងយូរហើយ បានងាកនិយាយទៅកាន់ប្រពន្ធគាត់ថាៈ “មួយជីវិតហើយ ខ្ញុំមិនដែលរាំទេ តែពេលនេះសប្បាយពេកបានរួចផុតពីស្លាប់ សប្បាយដោយបានរស់ឡើងវិញ ខ្ញុំសូមឡើងរាំឡាំលាវនឹងគេមួយបទហើយ យាយវាឯងកុំថាអីថាវ៉ាន់ណា” ។ បុណ្យឆ្លងព្រះវិហារនៅវត្តព្រៃជ្រីងរួច សភាពការណ៍នៅអូរឡោង និងព្រែករំដេង មានសភាពប្លែកគួរឲ្យកត់សម្គាល់ ។ ប្រជាជនតាមភូមិនានាមានការព្រួយបារម្ភ និងនាំគ្នាចាប់ផ្ដើមប្រុងប្រយ័ត្នយ៉ាងខ្លាំង ។ ដោយថ្មីៗនេះមានកងទ័ពប្រដាប់អាវុធនៃចលនាតស៊ូមួយក្រុមបានធ្វើដំណើរឆ្លងកាត់ទៅមក និងមានការចាត់តាំងរដ្ឋអំណាចភូមិឃុំដោយសម្ងាត់ ។ ប៉ុន្មានថ្ងៃក្រោយមកទៀត រដ្ឋអំណាចថ្មីដែលត្រូវបានចាត់តាំងឡើង ដោយចលនាតស៊ូមួយក្រុមនោះ បានកោះហៅប្រមូលប្រជាជនទូទាំងឃុំឲ្យមកចូលរួមប្រជុំនៅវត្តស្វាយតានាន់ ។

នាព្រឹកថ្ងៃនោះ មានប្រជាជនជាច្រើននាក់មកពីភូមិនានាទូទាំងឃុំព្រែករំដេង បានមកចូលរួមប្រជុំនៅនឹងវត្តស្វាយតានាន់ ។ លោកពូយៀត តាប៉ាង តាតឹក និងរូបខ្ញុំ ក៏មានវត្តមាននៅក្នុងឱកាសប្រជុំនោះដែរ ។

យើងអង្គុយផ្ទាល់នឹងដី អង្គុយបន្តកន្ទុយគ្នាជាជួរក្រោមម្លប់ស្វាយដ៏ត្រឈុំត្រឈៃពីមុខព្រះវិហារជ្រុងខាងកើត ។ មិត្តហេងប្រធានឃុំព្រែករំដេងដែលត្រូវបានចាត់តាំងឡើងដោយក្រុមចលនាខ្មែរតស៊ូ បានឡើងបើកអង្គប្រជុំ និងបានណែនាំប្រជាជនទាំងអស់ឲ្យបានស្គាល់កម្លាំងចលនាតស៊ូដែលកំពុងតែធ្វើសកម្មភាពក្នុងស្រុកស្រីសន្ធរទាំងមូល គឺជាកម្លាំងចលនាតស៊ូរបស់ទ្រង់ចក្រពង្សជាកូនរបស់សម្ដេចសីហនុ ។

ក្នុងបរិវេណជុំវិញព្រះវិហារ មានកងទ័ពចលនាតស៊ូជាច្រើននាក់ប្រដាប់ដោយអាវុធ ក្នុងសម្លៀកបំពាក់ ខោរខេបរខាកមិនខុសពីកងទ័ពខ្មែរក្រហមដែលបាក់ទ័ពកំពុងតែស្ពាយកាំភ្លើងដើរចុះដើរឡើងការពារសន្តិសុខ ។ ខ្ញុំអង្គុយជាប់តាប៉ាង គ្រាន់តែតំណាងចលនាខ្មែរតស៊ូរបស់ទ្រង់ចក្រពង្ស ឡើងមានមតិភ្លាម តាតឹក បានឱនមកខ្សិបដាក់ត្រចៀកតាប៉ាងថាៈ “ឱ! លោកបង កម្មយើងមកដល់ហើយ ចុះពេលនេះចក្រពង្ស ចក្រពត្តិស្អីទៀត ហើយ” ។

ចលនាខ្មែរតស៊ូមួយក្រុមនេះ បានប្រកាសអំពាវនាវសូមឲ្យ

ប្រជាជនក្នុងស្រុកស្រីសន្ធរទាំងមូល ចូលរួមចំណែកឧបត្ថម្ភគាំទ្រ តស៊ូប្រយុទ្ធ វាយកម្ចាត់បណ្តេញកងទ័ពយួនឈ្លានពានលេបទឹកដី ចេញឲ្យអស់ពីកម្ពុជា វាយកម្ទេចរបបអាយ៉ងយួនសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីឈានទៅបង្កើតរបបរាជានិយមមួយក្រោមការដឹកនាំរបស់សម្តេចព្រះនរោត្តម សីហនុ ។

ដើម្បីក្តាប់កម្លាំងប្រជាជនឲ្យបានណែនក្នុងដៃ ចលនាតស៊ូមួយក្រុមនេះ នៅបានចាត់តាំងតំណាងរដ្ឋអំណាចភូមិឃុំរបស់ខ្លួន និងបានប្រកាសសូមឲ្យប្រជាជនទាំងអស់មុននឹងធ្វើដំណើរចេញទៅរកស៊ីឆ្ងាយជិត ត្រូវសុំលិខិតអនុញ្ញាតធ្វើដំណើរឲ្យបានត្រឹមត្រូវពីរដ្ឋអំណាចជាមុនសិន ។

ថ្ងៃបន្តបន្ទាប់មកទៀត ខ្ញុំសំគាល់ឃើញនៅមានកងទ័ពរបស់ទ្រង់ចក្រពង្សធ្វើសកម្មភាពទាំងយប់ទាំងថ្ងៃចុះឡើងខ្វែងខ្វាត់ ទាំងក្នុងភូមិទាំងក្នុងព្រៃនាមឆ្ងាយខាងក្រោយភូមិ ។

ថ្ងៃមួយ មានកាណូតដឹកជញ្ជូនកងទ័ពវៀតណាមជាច្រើនកងចូលមកសុំចតនៅទីងកំពង់មាត់ទន្លេអូរឡេង ។ ពួកកងទ័ពវៀតណាមចាប់ផ្តើមពង្រាយគ្នាតាំងពីដើមភូមិ តាមបណ្តោយទន្លេតូចទល់មុខភូមិចុងកោះអណ្តែត និងតាមបណ្តោយផ្លូវលំកណ្តាលភូមិរហូតទៅដល់ផ្សារព្រែករំដេង ។

ក្នុងឱកាសជាមួយគ្នានោះដែរ កងទ័ពប្រដាប់អាវុធចលនាខ្មែរតស៊ូបានដកកម្លាំងរបស់ខ្លួនតាមក្បួនយុទ្ធសាស្ត្រ ដកថយចូលទៅពួនសម្ងំលាក់ខ្លួនក្នុងព្រៃនាមខាងក្រោយភូមិ ហើយបានប្រកាសឲ្យប្រជាជនធ្វើការប្រុងប្រយ័ត្ន និងរកជម្រករៀងៗខ្លួន ព្រោះនឹងមានការវាយប្រយុទ្ធគ្នាជាមួយកងទ័ពយួនឈ្លានពាននាពេលខាងមុខ ។

គ្រាន់តែបានឮសេចក្តីប្រកាសអាសន្ននេះភ្លាម អ្នកស្រុកអ្នកភូមិភ័យស្លន់ស្លោ ម្នាក់ៗស្ថិតក្នុងភាពយ៉ាងតក់ក្រហល់ នាំគ្នាប្រមូលកូនចៅរត់រកជម្រកយ៉ាងរួសរាន់ ។ ប្រមាណជាងកន្លះម៉ោងក្រោយមក កងទ័ពខ្មែរតស៊ូបានចេញពីព្រៃនាមមកដាក់ពង្រាយគ្នា ខ្លះពួនក្រោមផ្ទះអ្នកស្រុក ខ្លះលាក់ខ្លួនក្នុងចម្ការចេក ខ្លះឈរកៀកនឹងគល់ខ្នុរ គល់ល្មុត ត្រៀមចាំឱកាស និងផ្ទុះអាវុធ ។

បន្តិចក្រោយមក ការប្រយុទ្ធគ្នាយ៉ាងសាហាវបានផ្ទុះឡើងជាមួយនឹងស្នូរកាំភ្លើងដៃបាញ់តទល់គ្នា លាន់ឮយ៉ាងទ្រហឹងស្ទើរបែកក្រដាសត្រចៀក ស្នូរគ្រាប់កាំភ្លើងបេសែសិបរបស់កងទ័ពខ្មែរតស៊ូបាញ់ផ្ទក់តម្រង់ទៅរកកងទ័ពយួនផ្ទុះរញ្ជួយពេញភូមិ មានទាំងផ្សែងភ្លើងឆេះយ៉ាងខ្មៅខ្មួលខ្មាញ់ ។

**(តទៅលេខក្រោយ)**

**ប៉ុក ប៉ុនសូម៉ាឌ**

# ដំណឹងប្រកាសរកបងប្អូន

ខ្ញុំបាទឈ្មោះដើម ជា ពេជ្រ ជាអតីតទាហានជើងទឹក លន់នល់ (ពីឆ្នាំ១៩៧០ - ៧៥) ប៉ុន្តែបច្ចុប្បន្នបានកែមកឈ្មោះ ជា សុវណ្ណបុ



ជា ពេជ្រ

ជា ប៉ុម ។ ខ្ញុំបាទមានស្រុកកំណើតនៅភូមិសៀមរាប ស្រុកកំពង់កន្ទួត ខេត្តកណ្តាល ។ បច្ចុប្បន្នខ្ញុំបាទរស់នៅប្រទេសបារាំង ។ ខ្ញុំបាទសូមប្រកាសស្វែងរកបងប្អូនដែលមានរាយនាមដូចតទៅ គឺ ៖ ១) ម្តាយឈ្មោះ រស់ ស្តើង ២) ម្តាយមីងឈ្មោះ ជា រិន (ហៅ នាង) ៣) ឪពុកធំឈ្មោះ ជា ប៉ាត និង ម៉ែន ម៉ុម ៤) បងប្រុសឈ្មោះ ម៉ែន ធូមឌឿន និង ម៉ែន សុគន ៥) ប្អូនប្រុស ជា ប៉ូច

អាស្រ័យហេតុនេះ បើមានបងប្អូនញាតិមិត្តណា បានស្គាល់ ឬមានដំណឹងពីឈ្មោះដូចដែលបានរាយនាមខាងលើនេះ សូមមេត្តាទាក់ទងមកកាន់ខ្ញុំបាទ ជា សុវណ្ណ អាសយដ្ឋាន 50, RUE DES CYCLAMENS, 01100 GEOVREISSET ប្រទេសបារាំង ទូរស័ព្ទ (+៣៣) ០៤ ៧៤ ៤៩ ០០ ៥៧ ។ **សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ ញាណ សុជាតិ ទូរស័ព្ទលេខ ០៧០ ៩៨៨ ៦៦៦ ឬ អ៊ីម៉ែល ៖ truthsocheat@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 196, 2016 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.